ក្រសួងអភិវឌ្ឍន៍ជនបទ

# សេចក្តីព្រាងចុងក្រោយ
# គោលការណ៍ណែនាំថ្នាក់ជាតិ
# ស្តីពី
# កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យសម្រាប់ ជនពិការ និងមនុស្សចាស់





ខែសីហា ឆ្នាំ ២០១៦

# បញ្ជីរាយនាមអក្សរកាត់

| | |
|---|---|
| BCC | ការផ្លាស់ប្តូរការប្រព្រឹត្ត |
| CFPs | ជនបង្គោលឃុំ |
| CSP | ផែនការអនាម័យសហគមន៍ |
| CBR | ស្តារលទ្ធភាពពលកម្មតាមសហគមន៍ |
| CLTS | សហគមន៍ដឹកនាំអនុវត្តន៍អនាម័យ |
| CSES | ការអង្កេតសេដ្ឋកិច្ច សង្គមកម្ពុជា |
| DPOs | អង្គការតំណាងជនពិការ |
| DAC | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| DoSVY | ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក |
| HI | អង្គការជនពិការអន្តរជាតិ |
| LPPRPD | ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់ជនពិការ |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MIPAA | ផែនការសកម្មភាពអន្តរជាតិម៉ាឌ្រីត ស្តីពីមនុស្សចាស់ |
| NHE | |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| OPAs | សមាគមមនុស្សចាស់ |
| ODF | ការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល |
| PoSVY | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត |
| RWSSH | វិស័យផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ |
| RECU | ការទៅដល់ ចូល ការផ្លាស់ទីជុំវិញ ការប្រើប្រាស់ |
| TOR | ក្របខ័ណ្ឌការងារ |
| UNCRPD | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ |
| VFPs | ជនបង្គោលភូមិ |
| WASH | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ |

# មាតិកា


១. សេចក្តីផ្តើម និងទិដ្ឋភាពទូទៅ ....................................................................................... 6

១.១ ការកំណត់និយមន័យកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានការ ដាក់បញ្ចូលជនពិការ និងមនុស្សចាស់ ....................................................................................... 6

១.២ ការប្រើប្រាស់វិធីសាស្ត្រសិទ្ធិមនុស្សជាមូលដ្ឋានចំពោះកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូល ....................................................................................... 7

១.៣ ទិដ្ឋភាពទូទៅ ....................................................................................... 7

១.៤ សេចក្តីផ្តើមអំពីជនពិការ និងមនុស្សចាស់នៅកម្ពុជា ....................................................................................... 8

២. សកម្មភាពបីសំខាន់ៗសម្រាប់ការដាក់បញ្ចូលជនពិការ និងមនុស្សចាស់ទៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ ....................................................................................... 12

២.១ សកម្មភាពទី១៖ ធានាឲ្យមានការចូលរួមពីជនពិការ និង មនុស្សចាស់ក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ ....................................................................................... 12

២.២ សកម្មភាពទី២៖ ការកំណត់រកជនពិការ និងមនុស្សចាស់នៅនៅពេលចាប់ផ្តើមដំបូងនៃវដ្តកម្មវិធី ផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ ....................................................................................... 16

២.៣ សកម្មភាពទី៣៖ ការវាយតម្លៃរបាំងដែលរាំងស្ទះដល់ការលើកកម្ពស់ការដាក់បញ្ចូលជនពិការ និងមនុស្សចាស់ទៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ ....................................................................................... 18

៣ .សហគមន៍ដឹកនាំអនុវត្តអនាម័យ (CLTS)៖ វិធីសាស្ត្រដែលមានការដាក់បញ្ចូល ....................................................................................... 26

៣.១ មុនពេលបំផុស ....................................................................................... 27

៣.២ នៅពេលបំផុស ....................................................................................... 28

៣.៣ ក្រោយពេលបំផុស ....................................................................................... 29

៣.៤ ការពិនិត្យតាមដានសកម្មភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ....................................................................................... 30

៣.៥ ដំណើរការផ្ទៀងផ្ទាត់បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល .................................... 31
៤. ការធ្វើទីផ្សារអនាម័យ៖ វិធីសាស្ត្រដែលមានការដាក់បញ្ចូល.................................................32
៤.១ ការធ្វើការជាមួយអាជីវកម្មអនាម័យ និងភ្នាក់ងារលក់ .................................................. 32
៤.២ ការរៀបចំផែន និងយុទ្ធសាស្ត្រការទីផ្សារ.............................................................. 33
៥. ទីកន្លែងលាងសម្អាតដៃដែលមានការបង្កលក្ខណៈងាយស្រួល.............................................36
៦. ទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត (BCC)៖ វិធីសាស្ត្រដែលរាប់បញ្ចូលជនគ្រប់រូប................39
៦.១ ព័ត៌មានដែលអាចទទួលបាន........................................................................... 40
៧. ការផ្គត់ផ្គង់ទឹកស្អាត៖ វិធីសាស្ត្រដែលមានការដាក់បញ្ចូល.................................................43
៨កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័វាយតម្លៃការការពិនិត្យតាមដាន និង . យសម្រាប់ ការដាក់បញ្ចូលជនពិការ និងមនុស្សចាស់...................................................47
៨.១ របៀបពិនិត្យតាមដានការដាក់បញ្ចូល និងការបង្កលក្ខណៈងាយស្រួល............................ 48
៨.២ របៀបធ្វើការវាយតម្លៃ៖ សំណួរមគ្គុទ្ទេសក៏សម្រាប់ការវាយតម្លៃអំពីទិដ្ឋភាពក្នុងការដាក់បញ្ចូលរបស់ កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ ................................................ 52

## បញ្ជីតារាង

តារាងទី 1៖ច្បាប់/ក្របខ័ណ្ឌ ................................................................................. 10
តារាងទី 2៖របាំង និងដំណោះស្រាយសម្រាប់ការលាងសម្អាតដៃ ........................................ 37

## បញ្ជីប្រអប់

ប្រអប់ទី 1៖ការទៅដល់ ចូល ការផ្លាស់ទី ការប្រើប្រាស់ ..................................................... 22
ប្រអប់ទី 2៖ គោលការណ៍ប្លង់រចនាជាសកល ......................................................................... 23
ប្រអប់ទី 3៖ ការវិភាគរបាំងដោយមានការចូលរួម ............................................................. 24

ប្រអប់ទី 4៖ ការស្ដាបនាបរិស្ថានដែលមានការបង្កលក្ខណៈងាយស្រួលនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ........ 46
ប្រអប់ទី 5៖ ការត្រួតពិនិត្យលើការបង្កលក្ខណៈងាយស្រួលនិងសុវត្ថិភាព ........ 48
ប្រអប់ទី 6៖ ដណ្ដើរនៃការចូលរួម ........ 50
ប្រអប់ទី 7៖ រឿងរ៉ាវនៃការផ្លាស់ប្ដូរដ៏គួរឱ្យកត់សម្គាល់បំផុត ........ 51

## បញ្ជីដ្យាក្រាម

ដ្យាក្រាមទី 1៖ រចនាសម្ព័ន្ធអង្គការជនពិការក្នុងប្រទេសកម្ពុជា ........ 14

# ១. សេចក្តីផ្តើម និងទិដ្ឋភាពទូទៅ

## ១.១ ការកំណត់និយមន័យកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលជនពិការ និងមនុស្សចាស់

**កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូល**កើតឡើងនៅពេលដែលសហគមន៍ទាំងមូលបានដាក់បញ្ចូលជនពិការ មនុស្សចាស់ ស្ត្រីមានផ្ទៃពោះ ជនជាតិភាគតិច និងក្រុមដែលត្រូវបានគេមើលរំលងឲ្យទទួលបានផលប្រយោជន៍ និង ចូលរួមដោយស្មើភាពគ្នា នូវរាល់កម្មវិធីនិងដំណើរការទឹកស្អាតនិងលើកកម្ពស់អនាម័យ។ វិធីសាស្ត្រដែលមានការដាក់បញ្ចូលទៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យ ជំរុញឲ្យមានការយល់ដឹងនិងចូលរួមពីរាល់ក្រុមដែលមិនត្រូវបានគេយកចិត្តទុកដាក់។ ហេតុដូច្នេះ **ការដាក់បញ្ចូលធានាថាគ្រប់គ្នាអាចចូលរួមបានយ៉ាងពេញលេញ**។ ការដាក់បញ្ចូល មិនត្រឹមតែធ្វើឲ្យប្រសើរឡើងនូវការទទួលបានសេវាប៉ុណ្ណោះទេ ប៉ុន្តែវាបានគាំទ្រឲ្យមនុស្សមានការចូលរួម នៅក្នុងដំណើរការកាន់តែទូលំទូលាយ ដើម្បីធានាថាសិទ្ធិនិងតម្រូវការរបស់ពួកគេត្រូវបានទទួលស្គាល់។

ការដាក់បញ្ចូលគឺជាមូលដ្ឋានគ្រឹះក្នុងការផ្តល់សេវាទឹកស្អាត និង ការលើកកម្ពស់អនាម័យប្រកបដោយប្រសិទ្ធភាព ដោយធានាថាទឹកស្អាត និងការលើកកម្ពស់អនាម័យ បានបង្កលក្ខណៈងាយស្រួលសម្រាប់មនុស្សគ្រប់រូប និងប្រើប្រាស់ងាយស្រួល ហើយវាមិនមែនសម្រាប់តែជនពិការនោះទេ ប៉ុន្តែគឺសម្រាប់មនុស្សគ្រប់គ្នានៅក្នុងគ្រួសារ និងសហគមន៍ រួមមាន មនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ កុមារ និងអ្នកដែលមានជម្ងឺ ឬ របួស។

កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូល មានគោលបំណងបំពេញសេចក្តីត្រូវការមនុស្សគ្រប់ៗគ្នា។ វាធ្វើទៅបានដោយការធានាថាគ្រប់គ្នា មានឱកាសចូលរួមនៅក្នុងផែនការ និងការធ្វើសេចក្តីសម្រេចចិត្ត និងអាចទទួលបានសេវា និងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ។ គោលការណ៍ណែនាំនេះផ្តោតជាពិសេសទៅលើជនពិការនិងមនុស្សចាស់ អាស្រ័យដោយមនុស្សទាំងពីរក្រុមនេះអាចនឹងមានហានិភ័យដែលត្រូវបានគេមើលរំលង ឬផាត់ចេញពីកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ។ ជនពិការនិងមនុស្សចាស់តែងតែជួបបទពិសោធន៍ស្រដៀងគ្នាអំពីឧបសគ្គក្នុងការទទួលបានទឹកស្អាត និងលើកកម្ពស់អនាម័យនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ មនុស្សចាស់អាចនឹងមានភាពទន់ខ្សោយ និងមានការលំបាកក្នុងការបម្លាស់ទី ដែលធ្វើឲ្យពួកគេពឹងផ្អែកទាំងស្រុងទៅលើអ្នកដទៃក្នុងការប្រើប្រាស់ទឹកស្អាត បង្គន់អនាម័យ ឬ បំពេញសេចក្តីត្រូវការពាក់ព័ន្ធនឹងអនាម័យ ហើយទាំងនេះគឺស្រដៀងគ្នានឹងជនពិការគ្រប់វ័យផងដែរ។ តួអង្គនៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យគប្បីចាត់វិធានការជាក់លាក់ដើម្បីដាក់បញ្ចូលក្រុមទាំងនេះ និងពិនិត្យតាមដានថាពួកគេពិតជាត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យប្រាកដមែន។

| |
|---|
| ចាំបាច់ត្រូវចងចាំថា ជនពិការមានបទពិសោធន៍ក្នុងជីវិតខុសៗគ្នា ហើយជនពិការមួយចំនួនអាចងាយរងគ្រោះជាង ឬរងការផាត់ចេញខ្លាំងជាងជនពិការដទៃទៀត។ ឧទាហរណ៍ដូចជា ស្ត្រីពិការអាចមានការប្រឈមធ្ងន់ធ្ងរទៅនឹងភាពក្រីក្រ អំពើហិង្សា និង មានសេចក្តីត្រូវការបន្ថែមផ្នែកទឹកស្អាត និងអនាម័យ ច្រើនជាងបុរសពិការ។ |

## ១.២ ការប្រើប្រាស់វិធីសាស្ត្រសិទ្ធិមនុស្សជាមូលដ្ឋានចំពោះកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូល

**ជំហានតូចៗតែមានតម្លៃ៖** អ្នកអាចចាប់ផ្តើមប្រើប្រាស់គំរូសិទ្ធិសម្រាប់ជនពិការ ឬមនុស្សចាស់តាមរយៈសកម្មភាពតូចៗដោយផ្អែកលើវិធីណាដែលអាចធ្វើទៅបាន និងមានភាពពាក់ព័ន្ធខ្លាំងបំផុតចំពោះក្រុមការងារ និងកម្មវិធីរបស់អ្នក។ គោលការណ៍ណែនាំទាំងនេះផ្តល់នូវឧទាហរណ៍អំពីសកម្មភាពតូចៗក្នុងការធ្វើឲ្យជនពិការ និងមនុស្សចាស់ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ ដោយប្រើប្រាស់វិធីសាស្ត្រ និងគោលការណ៍សិទ្ធិជាមូលដ្ឋាន។

គោលការណ៍ណែនាំនេះប្រើប្រាស់វិធីសាស្ត្រសិទ្ធិមនុស្សជាមូលដ្ឋានក្នុងការដាក់បញ្ចូលជនពិការ និងមនុស្សចាស់ ទៅក្នុងកម្មវិធីទឹកស្អាត និងលើកកម្ពស់អនាម័យ។ ការប្រើប្រាស់វិធីសាស្ត្រសិទ្ធិមនុស្សជាមូលដ្ឋានសម្រាប់ពិការភាព និងមនុស្សចាស់ទៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ បានទទួលស្គាល់ថារាល់ប្រជាជនទាំងអស់មានសិទ្ធិចូលរួមយ៉ាងសកម្មនៅក្នុងកម្មវិធីអភិវឌ្ឍន៍ ដោយស្មើភាពគ្នាជាមួយនឹងជនមិនពិការ ដោយមិនប្រកាន់អាយុ។ វិធីសាស្ត្រសិទ្ធិមនុស្សជាមូលដ្ឋាន ក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ ប្រើប្រាស់គោលការណ៍ស្នូល ចំនួន៦ ដូចតទៅ៖

- សមភាព និង ការមិនរើសអើង
- **ការចូលរួម** និងការផ្តល់ភាពអង់អាច និង
- តម្លាភាព និងគណនេយ្យភាព

វិធីសាស្ត្រសិទ្ធិមនុស្សជាមូលដ្ឋាន មានន័យថាការលើកកម្ពស់គោលការណ៍ស្នូលរបស់សិទ្ធិមនុស្ស ដោយកសាងនូវសមត្ថភាពរបស់ "មន្ត្រីមានសមត្ថកិច្ច" (ស្ថាប័ននានា រដ្ឋាភិបាល) ដើម្បីបំពេញកាតព្វកិច្ច ហើយស្របពេលជាមួយគ្នានោះ ក៏កសាងសមត្ថភាពរបស់ "ម្ចាស់សិទ្ធិ" (ឧ. មនុស្សចាស់ ឬ ជនពិការ) ដើម្បីទាមទារនូវសិទ្ធិរបស់ពួកគេ។ ការអនុវត្តន៍វិធីសាស្ត្រសិទ្ធិជាមូលដ្ឋាន មានលក្ខណៈលើសពីការបន្ថែមជនពិការ ឬ មនុស្សចាស់ទៅក្នុងក្រុមគោលដៅរបស់កម្មវិធីអភិវឌ្ឍន៍។ [1] ទាំងនេះគឺសំដៅចំពោះកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យដែលធ្វើការជាមួយរដ្ឋាភិបាលក៏ដូចជាសហគមន៍ដើម្បីសម្រេចបានលទ្ធផលនៃកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យឲ្យកាន់តែប្រសើរឡើង។ គោលការណ៍ណែនាំទាំងនេះ ប្រែក្លាយគោលការណ៍សិទ្ធិមនុស្សទាំងនេះទៅជាការអនុវត្តន៍។

## ១.៣ ទិដ្ឋភាពទូទៅ

ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើតគោលការណ៍ណែនាំទាំងនេះ ដើម្បីជួយដល់អ្នកពាក់ព័ន្ធ ទីភ្នាក់ងាររដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅតាមជនបទនៅក្នុងប្រទេសកម្ពុជាដើម្បីការរៀបចំនិងអនុវត្តកម្មវិធី ដែលមានអត្ថប្រយោជន៍សម្រាប់មនុស្សគ្រប់រូបនៅក្នុងសហគមន៍។ ទស្សនៈវិស័យគឺដើម្បីឱ្យអ្នកពាក់ព័ន្ធទាំងអស់ដែលធ្វើការងារលើវិស័យការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅតាមជនបទ ទទួលយកមកប្រើប្រាស់នូវវិធីសាស្ត្រដែលមានការដាក់បញ្ចូលនៅក្នុងរាល់កម្មវិធីរបស់ពួកគេ។ គោលការណ៍ណែនាំនេះមានគោលបំណងគាំទ្រចំពោះការប្តេជ្ញាដាក់បញ្ចូល ដែលមានបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ២០១៤-២០២៥។ គោលការណ៍ណែនាំនេះផ្តោតលើ កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅតាមគ្រួសារ និងសហគមន៍។ ទិដ្ឋភាពការដាក់បញ្ចូល

[1] អង្គការ CBM និងBMZ; វិធីសាស្ត្រសិទ្ធិមនុស្សជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍ពិការភាព (ឆ្នាំ២០១២)
http://www.cbm.org/article/downloads/54741/A_human_rights-based_approach_to_disability_in_development.pdf

កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅតាមសាលារៀនត្រូវបានគ្របដណ្តប់នៅក្នុងកញ្ចប់អប្បបរមាសម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅតាមសាលារៀន។

**ផែនការយុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ២០១៤-២០២៥** បានកំណត់អាទិភាពឲ្យមានការអភិវឌ្ឍន៍សេវាផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យសម្រាប់ *"ប្រជាពលរដ្ឋដែលក្រីក្របំផុត និងទទួលបានការយកចិត្តទុកដាក់តិចបំផុត"* ហើយបានបញ្ជាក់ថា ៖

*"គម្រោង និងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ នឹងពិចារណាទៅលើសេចក្តីត្រូវការរបស់ជនពិការនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃវដ្តគម្រោង/កម្មវិធីរបស់ពួកគេ និងបញ្ចូល "អង្គការតំណាងជនពិការទៅក្នុងដំណើរការពិគ្រោះយោបល់ គណៈកម្មាធិការ ឬ ក្រុមប្រឹក្សាភិបាល"។*

កម្មវិធីក៏តម្រង់ទិសផងដែរចំពោះការអភិវឌ្ឍន៍ និងផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅតាមជនបទ ដើម្បីឱ្យអនុលោមទៅតាមច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ[2]។

គោលការណ៍ណែនាំមានគោលបំណងជួយដល់គម្រោង និងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យក្នុងការអនុវត្តបទបញ្ញត្តិទាំងនេះរបស់យុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ២០១៤-២០២៥។

## ១.៤ សេចក្តីផ្តើមអំពីជនពិការ និងមនុស្សចាស់នៅកម្ពុជា

ជនពិការត្រូវបានប៉ាន់ប្រមាណថាមានចំនួនប្រមាណ ១៥% នៃប្រជាជនទូទាំងសកលលោក និង ២០% នៃប្រជាជនដែលក្រីក្រជាងគេបំផុតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ [3] កត្តានេះបានធ្វើឲ្យជនពិការគឺជាក្រុមជនភាគតិចដ៏ធំជាងគេបំផុត និងជាក្រុមមួយក្នុងចំណោមក្រុមដែលបាត់បង់ប្រយោជន៍ជាងគេបំផុតផងដែរ។

នៅកម្ពុជា មានការលំបាកក្នុងការទទួលបានទិន្នន័យដែលមានភាពសុក្រឹត្យអំពីប្រេវ៉ាឡង់នៃពិការភាព។ កត្តានេះគឺដោយសារមានការប្រមូលព័ត៌មានតាមមធ្យោបាយខុសៗគ្នា។ ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជានៅឆ្នាំ២០០៩ បានបង្ហាញថាប្រេវ៉ាឡង់ពិការភាពមានចំនួន ៦,៣% នៃប្រជាជនសរុប[4] ដោយឡែកជំរឿនឆ្នាំ២០១៣ បានរកឃើញតែ ២,១% នៃប្រជាជនសរុបដែលមានពិការភាព ដោយអត្រាពិការភាពនៅតាមតំបន់ជនបទ មានកម្រិតខ្ពស់ជាងនៅតាមតំបន់ទីក្រុង។ [5] បើទោះជាដូច្នេះក្តី ភ្នាក់ងារមួយចំនួនបានប៉ាន់ប្រមាណថា ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសនៅលើពិភពលោកដែលអាចនឹងមានអត្រាពិការភាពខ្ពស់ជាងគេ ដោយសារប្រទេសកម្ពុជាគឺជាប្រទេសដែល

---

[2] យុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ២០១៤ - ២០១៥។ ៦.១.៨ ភាពក្រីក្រ ជនជាតិភាគតិច និងភាពងាយរងគ្រោះ

[3] អង្គការសុខភាពពិភពលោក និងធនាគារពិភពលោក (ឆ្នាំ២០១១)។ របាយការណ៍ពិភពលោកស្តីពីពិការភាព ទំព័រ ២៩។ ទាញយកពី http://www.who.int/disabilities/world_report/2011/en/index.html.

[4] ការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជាឆ្នាំ២០០៩ របស់វិទ្យាស្ថានជាតិស្ថិតិ។ទាញយកពី http://www.nis.gov.kh/nis/CSES/Final%20Report%20CSES%202009.pdf

[5] របាយការណ៍បញ្ចប់ ការអង្កេតចន្លោះជំរឿនប្រជាសាស្ត្រកម្ពុជាឆ្នាំ២០១៣ របស់វិទ្យាស្ថានជាតិស្ថិតិ។ ថ្ងៃទី៣ ខែវិច្ឆិកា បានទាញយកពី http://countryoffice.unfpa.org/cambodia/drive/CIPS_Report_English_Final.pdf

មានប្រវត្តិឆ្លងកាត់សង្គ្រាម មានកម្រិតក្រីក្រខ្ពស់ និងមានសុខភាពទន់ខ្សោយ។[6]ការកើនឡើងនូវគ្រោះថ្នាក់ចរាចរណ៍គឺជាមូលហេតុចម្បងដែលបណ្តាលឲ្យមានពិការភាពនៅក្នុងប្រទេសកម្ពុជា។ មានភាពខុសប្លែកគ្នារវាងតំបន់ជនបទ និងតំបន់ទីក្រុង ៖ នៅទីក្រុង មូលហេតុចម្បងដែលបណ្តាលឲ្យមានពិការភាពរួមមាន គ្រោះថ្នាក់ចរាចរណ៍ និងវ័យជរា ដោយឡែកនៅជនបទគឺកង្វះអាហារូបត្ថម្ភ និងជម្ងឺ។[7]

ជំរឿនឆ្នាំ២០០៨បានបង្ហាញឱ្យដឹងថា ៦,៣៤% នៃប្រជាជនកម្ពុជា មានអាយុលើស៦០ឆ្នាំ។ ចំនួននេះអាចនឹងកើនឡើង ហើយរំពឹងថានឹងមានចំនួនកើនឡើងជិតបីដងនៅទសវត្សរ៍ខាងមុខ។[8] ស្ត្រីមានចំនួនច្រើនជាងបុរស ក្នុងនោះ បើធៀបទៅនឹងស្ត្រីចំនួន១០០នាក់ បុរសវ័យចំណាស់មានតែ៦៩នាក់ ប៉ុណ្ណោះ។ ជាធម្មតា មនុស្សចាស់នៅកម្ពុជា ត្រូវបានគេគិតថាមានក្រុមគ្រួសាររបស់ពួកគេជាអ្នកថែទាំ ហេតុដូច្នេះ ភាគច្រើនវាបានធ្វើឲ្យពួកគេក្លាយជាក្រុមដែលបានមើលរំលងនៅក្នុងការអភិវឌ្ឍន៍។ មានមនុស្សចាស់ជរាជាច្រើនដែលមានបទពិសោធន៍លំបាកទាក់ទងនឹងដំណាក់កាលអាយុ ដូចជា ការចុះអន់ខ្សោយគំហើញ លំបាកក្នុងការបម្លាស់ទី ដែលនាំឲ្យមានការលំបាកក្នុងការទទួលបានទឹកស្អាត និង អនាម័យ។ បុរសនិងស្ត្រីវ័យជរាគឺជាជនដែលងាយរងគ្រោះទាំងជម្ងឺឆ្លងនិង ជម្ងឺមិនឆ្លង ហើយចាំបាច់ត្រូវតែមានការអនុវត្តន៍ការប្រព្រឹត្តអនាម័យទៀងទាត់។ មានមនុស្សចាស់ជាច្រើន ដែលភាគច្រើនគឺជាស្ត្រី ជាអ្នកមើលថៃចៅៗរបស់ពួកគាត់ អាស្រ័យដោយកូនរបស់ពួកគាត់បានធ្វើចំណាកស្រុក។ មនុស្សចាស់ប្រមាណ ២៥% រស់នៅក្រោមបន្ទាត់ភាពក្រីក្រ និងមិនអាចមានលទ្ធភាពក្នុងការចំណាយលើសេវាទឹកស្អាតឡើយ។[9] ផ្ទុយមកវិញ ការអភិវឌ្ឍន៍សហគមន៍ ជាញឹកញាប់គឺបានផាត់ចេញមនុស្សចាស់ចេញ ហើយការចូលរួមរបស់ពួកគេ មិនត្រូវបានមើលឃើញឡើយ។ ឧទាហរណ៍ ជាធម្មតាកម្មវិធីយេនឌ័រផ្តោតគោលដៅចំពោះកុមារី និងស្ត្រីក្នុងវ័យបន្តពូជ។ ស្រដៀងគ្នានេះដែរ កម្មវិធីពិការភាពហាក់មាននិន្នាការផ្តោតទៅលើក្រុមយុវវ័យ បើទោះបីជាមានការកើនឡើងនូវពិការភាព នៅពេលដែលមនុស្សមានវ័យចាស់ក៏ដោយ។

កន្លងមក ជនពិការនៅក្នុងប្រទេសកម្ពុជា ទទួលរងបទពិសោធន៍ក្នុងការមាក់ងាយនិងការរើសអើង។[10]ជាញឹកញាប់ជនពិការត្រូវបានគេផាត់ចេញពីសកម្មភាព និងសេវាកម្មកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ។ ស្ត្រីនិងកុមារីពិការប្រឈមនឹងការមិនយកចិត្តទុកដាក់ និងគ្មានអំណាចនៅក្នុងគ្រួសារនិងសហគមន៍ ហើយអាចនឹងមិនទទួលបានសុវត្ថិភាពអនាម័យ និងទឹកស្អាត ឬចូលរួមនៅក្នុងសេចក្តីសម្រេចចិត្តអំពីទឹកស្អាតនិងលើកកម្ពស់អនាម័យ។

តារាងខាងក្រោមនេះ កំណត់អំពីច្បាប់ និងក្របខ័ណ្ឌនានារបស់កម្ពុជាស្តីពីពិការភាព និងមនុស្សចាស់ព្រមទាំងរបៀបដែលច្បាប់ និងក្របខ័ណ្ឌទាំងនេះពាក់ព័ន្ធទៅនឹងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ៖

[6]រកឃើញដោយ អង្គការសហប្រជាជាតិ គណៈកម្មការសេដ្ឋកិច្ច និងសង្គមប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិច (UNESCAP)៖ ឆ្ពោះទៅរកការចូលរួមយ៉ាងពេញលេញ និងដោយស្មើភាពគ្នារបស់ជនពិការនៅក្នុងតំបន់ ESCAP។ ថ្ងៃទី៣ ខែវិច្ឆិកា បានទាញយកពី http://wwda.org.au/wp-content/uploads/2013/12/pathfinders1.pdf

[7]Travis, R (ឆ្នាំ២០០៧) គេហទំព័រ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ឆ្នាំ២០០៨) ផែនការយុទ្ធសាស្ត្រជាតិស្តីពីជនពិការរាប់បញ្ចូលជនពិការដោយសារមីន និងកាកសំណល់ពីសង្គ្រាម។ ភ្នំពេញទំព័រ៥

[8]វិទ្យាស្ថានស្ថិតិជាតិ (ឆ្នាំ២០១២)។ ការអង្កេតប្រជាសាស្ត្រមនុស្សចាស់នៅកម្ពុជា ឆ្នាំ២០១២។

[9] របាយការណ៍ប្រទេសកម្ពុជា ឆ្នាំ២០១៤

[10]Thomas, P(នាយកដ្ឋានសម្រាប់ការអភិវឌ្ឍអន្តរជាតិ) (២០០៥) ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍នៅកម្ពុជា៖ ការបង្កលក្ខណៈឱ្យជនពិការអាចដើរតួនាទីបាន។ ការយល់ដឹងអំពីពិការភាព និងការសិក្សាស្រាវជ្រាវ។ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៥បានទាញយកពី http://r4d.dfid.gov.uk/PDF/Outputs/Disability/PolicyProject_cambodia.pdf , p.6

## តារាងទី 1៖ច្បាប់/ក្របខ័ណ្ឌ

| | ច្បាប់/ក្របខ័ណ្ឌ | តើមានន័យដូចម្តេចសម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ |
|---|---|---|
| កិច្ចព្រមព្រៀងអន្តរជាតិ | ផែនការសកម្មភាពអន្តរជាតិម៉ាឌ្រីត ស្តីពីមនុស្សចាស់ (MIPAA) | ប្រទេសកម្ពុជាគឺជាប្រទេសហត្ថលេខីលើផែនការសកម្មភាពអន្តរជាតិស្តីពីមនុស្សចាស់ (MIPAA) ដែលលើកកម្ពស់លទ្ធភាពទទួលបានស្មើគ្នាចំពោះទឹកស្អាត (និងចំណីអាហារមានសុវត្ថិភាព) សម្រាប់មនុស្សចាស់ និងលើកទឹកចិត្តឱ្យមានការវិនិយោគលើផ្នែកអនាម័យសម្រាប់សហគមន៍ពហុជំនាន់។ |
| ច្បាប់អន្តរជាតិ | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (UNCRPD) | ក្នុងនាមជាជារដ្ឋភាគីមួយ រាជរដ្ឋាភិបាលកម្ពុជា (ចាប់តាំងពីឆ្នាំ២០១៣) ត្រូវបន្តផ្តល់លទ្ធភាពទទួលបានដែលចាំបាច់ និងការគាំទ្រតម្រូវការរបស់ជនពិការដើម្បីឲ្យពួកគេសម្រេចបាននូវសក្តានុពល និង រួមចំណែកចំពោះជីវិតរស់នៅក្នុងសង្គម សេដ្ឋកិច្ច និង វប្បធម៌របស់សហគមន៍ពួកគេ ព្រមទាំងការអភិវឌ្ឍន៍ជាតិរបស់ពួកគេ។ អនុសញ្ញានេះបានបញ្ជាក់ថា អង្គភាពដែលទទួលខុសត្រូវចំពោះបរិយាកាសមួយដែលត្រូវបានបង្កើតឡើង រាប់បញ្ចូលអង្គភាពផ្តល់សេវាទឹកស្អាត និងលើកកម្ពស់អនាម័យ មានតួនាទីកាត់បន្ថយរបាំងផ្នែកអាកប្បកិរិយា ស្ថាប័ន និងបរិស្ថាន (សូមមើលមាត្រា៩ និង ១៩)។ |
| ច្បាប់ជាតិ | ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ (ឆ្នាំ២០០៩) | ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ចែងអំពីសិទ្ធិជនពិការក្នុងការទទួលបានការងារដោយគ្មានការរើសអើងទាំងក្នុងវិស័យសាធារណៈ និងឯកជនរួមទាំងវិស័យទឹកស្អាតនិងលើកកម្ពស់អនាម័យនៅក្នុងប្រទេសកម្ពុជា។ វាទាមទារឲ្យនយោជកត្រូវចាត់វិធានការសមស្រប ដើម្បីសម្រួលដល់ជនពិការនៅឯកន្លែងការងារ។ |
| ផែនការយុទ្ធសាស្ត្រជាតិ | ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ ២០១៤-២០១៨ | ផែនការនេះបានចែងថារដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការចាត់វិធានការដកចេញនូវឧបសគ្គនានា និងធានាឲ្យមាន" បរិកាសមួយដែលមិនបង្កឱ្យមានពិការភាព" និង ការដាក់បញ្ចូលទៅក្នុងគ្រប់វិស័យទាំងអស់ រាប់បញ្ចូលកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យ។ ផែនការនេះសង្កត់ធ្ងន់ថាគ្រប់គ្នាមានតួនាទីធ្វើការរួមគ្នា ដើម្បីសម្រេចបាននូវសង្គមមួយ ដែលជនពិការមានលទ្ធភាពអតិប្បរមាក្នុងការប្រើប្រាស់សក្តានុពលរបស់ពួកគេពេញលេញ។ |
| យុទ្ធសាស្ត្រជាតិ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ | "ការលើកកម្ពស់សុខុមាលភាពមនុស្សចាស់ និងជនពិការ" ត្រូវបានទទួលស្គាល់ថាជា "គោលនយោបាយនិងសកម្មភាពអាទិភាពសំខាន់មួយ" នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨។ ផែនការនេះក៏លើកកម្ពស់ផងដែរ ចំពោះការបែងចែកថវិកាឱ្យបានគ្រប់គ្រាន់ សម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យ ដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់ អាចមានលទ្ធភាពទទួលបានទឹកស្អាតដែលអាចទទួលទានបាន និង អនាម័យ។ |
| ច្បាប់ជាតិ | គោលនយោបាយជាតិសម្រាប់មនុស្សចាស់ ឆ្នាំ២០០៣ | គោលនយោបាយនេះរំលេចអំពីការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគាំទ្រមនុស្សចាស់តាមរយៈវិស័យសង្គម សុខភាព និងសេដ្ឋកិច្ច។ គោលនយោបាយនេះបានបង្កើតបទបញ្ញត្តិសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសជូន |

| | | |
|---|---|---|
| | | ដល់វិស័យសុខាភិបាលអំពីការថែទាំមនុស្សចាស់។ |
| ច្បាប់ជាតិ | គោលនយោបាយ និងយុទ្ធសាស្ត្រជាតិស្តីពីការថែទាំមនុស្សចាស់ និងជនពិការ ឆ្នាំ១៩៩៩ | គោលនយោបាយជាតិនេះលើកកម្ពស់គោលនយោបាយដើម្បីធ្វើឲ្យប្រសើរឡើងនូវសុខភាពរបស់មនុស្សចាស់ និងជនពិការតាមរយៈការអប់រំសុខភាព ដែលរួមមាន ចំណីអាហារ រាងកាយ និងអនាម័យបរិស្ថាន។ |

**និយមន័យកម្សោយអវៈយវៈ៖** កម្សោយអវៈយវៈ គឺជាបញ្ហានៅក្នុងការបំពេញមុខងាររបស់រាងកាយ ឬ ការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធរាងកាយ ឧទាហរណ៍ដូចជា ខ្វិន ឬ ពិការភ្នែក។[11]

**និយមន័យពិការភាព៖** ពិការភាពសំដៅដល់បញ្ហាប្រឈមទាំងឡាយណាដែលបានជួបប្រទះអាស្រ័យដោយបញ្ហាកម្សោយអវៈយវៈរបស់បុគ្គលម្នាក់ សកម្មភាពប្រចាំថ្ងៃ (ដូចជា ការដើរ ឬ ការទទួលទាន) និង តាមរយៈការរើសអើងដែលជួបប្រទះនៅក្នុងជីវិត (ដូចជា ការមាក់ងាយ និង ការជួបប្រទះការរើសអើងក្នុងការទទួលបានព័ត៌មានការងារ ឬ ហេដ្ឋារចនាសម្ព័ន្ធ)។ ទាំងនេះគឺជា "ឧបស័គ្គដែលមិនបង្កលក្ខណៈអំណោយផល"។ បទពិសោធន៍នៃពិការភាព គឺបណ្តាលពីទំនាក់ទំនងនៃកត្តាលក្ខខណ្ឌសុខភាព បរិស្ថាន និងកត្តាបុគ្គល។ កត្តាទាំងនេះមានភាពខុសគ្នាយ៉ាងខ្លាំង អាស្រ័យដោយមិនមែនរាល់ជនពិការទាំងអស់សុទ្ធសឹងតែមានការបាត់បង់ប្រយោជន៍ស្មើៗគ្នានោះទេ។ កត្តាបុគ្គលខុសៗគ្នារួមមាន យេនឌ័រ ទ្រព្យសម្បត្តិ ជាតិពន្ធុ សាសនា អាយុ វប្បធម៌ និងធនធានដែលមាន។[12]

**និយមន័យមនុស្សចាស់៖** ជាទូទៅមនុស្សចាស់ត្រូវបានកំណត់និយមន័យទៅតាមប្រភេទនៃចរិកលក្ខណៈ មួយចំនួនដែលរួមមាន អាយុ ការប្រែប្រួលតួនាទីនៅក្នុងសង្គម (ធ្វើការងារតិចជាងមុន) និងការប្រែប្រួលសមត្ថភាពបំពេញមុខងារ។ ចរិកលក្ខណៈផ្នែកអាយុ មានភាពខុសគ្នាទៅតាមវប្បធម៌ និងប្រទេសផ្សេងៗគ្នា។ នៅក្នុងប្រទេសមួយចំនួនមនុស្សដែលមានអាយុ៥០ឆ្នាំ ត្រូវបានកំណត់ថាជាមនុស្សចាស់ ដោយឡែកប្រទេសខ្លះទៀត កំណត់យកអាយុ៦៥ឆ្នាំ[13] និងសម្រាប់ប្រទេសកម្ពុជាគឺកំណត់យកអាយុចាប់ពី ៦០ឆ្នាំឡើងទៅ។

[11]អង្គការសុខភាពពិភពលោក (២០១១) របាយការណ៍ស្តីពីពិការភាពសកល។

[12]អង្គការ WaterAid (ឆ្នាំ២០១២) តើរបាយការណ៍ពិភពលោក ស្តីពីពិការភាពមានន័យយ៉ាងដូចម្តេចសម្រាប់វិស័យទឹកស្អាត និងលើកកម្ពស់អនាម័យ

[13]អង្គការសុខភាពពិភពលោក។ ការកំណត់និយមន័យមនុស្សចាស់។ អង្គការសុខភាពពិភពលោកនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ឆ្នាំ២០១០ http://www.who.int/healthinfo/survey/ageingdefnolder/en/index.html (ទទួលបាននៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០)

## ២. សកម្មភាពបីសំខាន់ៗសម្រាប់ការដាក់បញ្ចូលជនពិការ និងមនុស្សចាស់ទៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ

ផ្នែកនេះ នឹងផ្តល់ការណែនាំឱ្យយើងបានស្គាល់អំពីគោលការណ៍មូលដ្ឋានមួយចំនួន និងថាតើគោលការណ៍ទាំងនេះផ្សារភ្ជាប់នឹងការអនុវត្តយ៉ាងដូចម្តេចខ្លះ។ ផ្នែកនេះ បង្ហាញឱ្យឃើញថាវិធីសាស្ត្រសិទ្ធិមនុស្សគឺជាគោលការណ៍គ្រឹះនៃសកម្មភាពសំខាន់ៗចំនួនបីក្នុងការអនុវត្តន៍កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ ដែលមានការបង្ហាញលក្ខណៈងាយស្រួល៖

- សកម្មភាពទី១៖ គោលការណ៍សំខាន់ៗនៃការចូលរួម
- សកម្មភាពទី២៖ វិធីក្នុងការកំណត់ជនពិការ និងមនុស្សចាស់នៅក្នុងពេលដើមដំបូងនៃវដ្តកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ
- សកម្មភាពទី៣៖ របាំងទាំងបួនប្រភេទនៃការចូលរួមនៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ និងដំហានសំខាន់ៗក្នុងការដោះស្រាយរបាំងទាំងនោះ

### ២.១ សកម្មភាពទី១៖ ធានាឲ្យមានការចូលរួមពីជនពិការ និង មនុស្សចាស់ក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ

ការចូលរួមជួយរំលេចអំពីតម្រូវការរបស់ជនពិការ និងមនុស្សចាស់ ដែលត្រូវដាក់ចូលទៅក្នុងដំណើរការកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ ក្នុងលក្ខណៈមួយដែលធ្វើឱ្យពួកគេអាចជះឥទ្ធិពលលើការសម្រេចចិត្តដោយផ្ទាល់។ ការធ្វើបែបនេះ អាចជួយកាត់បន្ថយការមាក់ងាយទៅលើជនពិការ និងមនុស្សចាស់ ក៏ដូចជាអាចជួយធានាបានថា ហេដ្ឋារចនាសម្ព័ន្ធ និងដំណើរការកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យបានបំពេញសេចក្តីត្រូវការសម្រាប់មនុស្សគ្រប់គ្នា។

គួរបង្កើតឱ្យមានភាពជាដៃគូជាមួយជនពិការនិងមនុស្សចាស់ដើម្បីផ្តល់សិទ្ធិអំណាចឲ្យពួកគេមានសិទ្ធិក្នុងការទទួលបានសេវាទឹកស្អាត និងលើកកម្ពស់អនាម័យ។ ភាពជាដៃគូនេះ អាចបង្កើតឡើងបានតាមរយៈ៖

- ការធ្វើការជាមួយអង្គការដែលជាតំណាង ឬចងក្រងដោយជនពិការដូចជាអង្គការជនពិការនិងក្រុមជួយខ្លួនឯងសម្រាប់ជនពិការ និងជាមួយសមាគមមនុស្សចាស់ (OPAs) និងសហព័ន្ធសមាគមមនុស្សចាស់ នៅកម្រិតសហគមន៍និងស្រុក។
- កិច្ចសហប្រតិបត្តិការ និង/ឬ ភាពជាដៃគូជាមួយគ្រួសារជនពិការ និងមនុស្សចាស់ បណ្តាញគាំទ្រនានា អ្នកផ្តល់សេវាពាក់ព័ន្ធនឹងពិការភាព និង មេដឹកនាំសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលមានជំនាញធ្វើការជាមួយមនុស្សចាស់និងជនពិការរួចស្រាប់ហើយ ឱ្យពួកគេមានតួនាទីក្នុងការគាំទ្រដល់ការពង្រឹងសិទ្ធិអំណាចរបស់ជនពិការ និងមនុស្សចាស់នៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ។

#### ការធ្វើជាដៃគូជាមួយអង្គការជនពិការ

ផែនការយុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ២០១៤-២០២៥ ចែងថាកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ ចាំបាច់ត្រូវតែរួមបញ្ចូលអង្គការជនពិការ (DPOs) ក្នុង *"គ្រប់ដំណើរការនៃការប្រឹក្សា គណៈកម្មការ និងក្រុមប្រឹក្សាភិបាល"*។ ផ្នែកនេះ នឹងលើកឡើងអំពីតួនាទីរបស់អង្គការជនពិការ និងរចនា

សម្ព័ន្ធរបស់អង្គការទាំងនេះនៅក្នុងប្រទេសកម្ពុជា។ ជម្រើសទីពីរសម្រាប់ការធ្វើជាដៃគូជាមួយវិស័យពិការភាព គឺតាមរយៈកម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍ (CBR)។ ចំណុចនេះនឹងមានអធិប្បាយលម្អិតនៅខាងក្រោម។ ផ្នែកនេះក៏លើកឡើងអំពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធផ្សេងៗផងដែរ។

**តើអ្វីជាអង្គការជនពិការ?**

អង្គការជនពិការគឺជាអង្គការតំណាង ឬជាក្រុមជនពិការ ដោយក្នុងនោះមនុស្សភាគច្រើនក្នុងជួរបុគ្គលិក ក្រុមប្រឹក្សាភិបាល និង អ្នកស្ម័គ្រចិត្ត គឺជាជនពិការ ហើយមានអ្នកតំណាងជនពិការនៅគ្រប់កម្រិតរបស់អង្គការ។ នៅប្រទេសកម្ពុជា មានអង្គការជនពិការនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ខ័ណ្ឌ/ស្រុក និងឃុំ សង្កាត់ ដែលបានផ្សាភ្ជាប់គ្នាជាបណ្តាញ។

សមាជិកអង្គការជនពិការ ក៏អាចរួមមានសមាជិកគ្រួសាររបស់ជនពិការផងដែរ ដោយអ្នកទាំងនេះអាចជាសមាជិកពេញសិទ្ធិ ឬជាសមាជិកជំនួយ អាស្រ័យទៅតាមបរិបទ ឬ អង្គភាពខុសៗគ្នា។ គោលបំណងចំបងរបស់អង្គការទាំងនេះគឺដើម្បីលើកកម្ពស់សិទ្ធិអំណាច និងស្វែងរកមតិគាំទ្រ សិទ្ធិ និង ផលប្រយោជន៍របស់សមាជិក ក៏ដូចជាជួយពង្រឹងចំណេះដឹងរបស់ពួកគេអំពីសិទ្ធិ និងសមត្ថភាពឆ្ពោះទៅសម្រេចទទួលបានការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។

ឧបសម្ព័ន្ធទី ១ មានព័ត៌មានទំនាក់ទំនងរបស់អង្គការជនពិការនៅកម្ពុជាដែលអាចជួយអ្នកក្នុងការប្រាស្រ័យទាក់ទងជាមួយអង្គការជនពិការនៅតាមបណ្តាខេត្ត និងនៅមូលដ្ឋាន។ មានមធ្យោបាយជាច្រើនក្នុងការធ្វើការជាមួយអង្គការជនពិការ។ អង្គការជនពិការមួយចំនួនអាចៈ

- ធ្វើជាដៃគូជាមួយអង្គការធ្វើការផ្នែកកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ ក្នុងការវិភាគស្ថានភាព វិភាគរបាំង ការត្រួតពិនិត្យលើការបង្កលក្ខណៈងាយស្រួល និង សុវត្ថិភាពវិភាគលើដំណោះស្រាយ និងលើកកម្ពស់ការយល់ដឹងដល់អ្នកដឹកនាំសហគមន៍។
- ផ្តល់ដំបូន្មាន និងណែនាំអំពីការដាក់បញ្ចូលពិការភាពទៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ រួមទាំងការប្រើប្រាស់ពាក្យពេចន៍ឲ្យបានត្រឹមត្រូវ។
- ផ្តល់ព័ត៌មានអំពីស្ថានភាព បទពិសោធន៍ និងទិន្នន័យអំពីជនពិការ។
- ប្រើប្រាស់បណ្តាញរបស់ពួកគេដើម្បីចែកចាយព័ត៌មាន ឬផ្សាភ្ជាប់ជនពិការទៅនិងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យរបស់អ្នក។
- ផ្តល់វគ្គបណ្តុះបណ្តាលនិងការកសាងសមត្ថភាពជាមួយក្រុមការងាររបស់អ្នក ទាក់ទងនិងសិទ្ធិជនពិការ
- ផ្តល់ឲ្យអ្នកនូវព័ត៌មានបញ្ជូនដល់អ្នក ន័យថា ប្រសិនបើក្រុមការងាររបស់អ្នកបានកំណត់ឃើញថាមានសមាជិកក្នុងគ្រួសារណាមួយជាជនពិការ អ្នកអាចបញ្ជូនពួកគេទៅទទួលសេវាគាំទ្រ។

ជាការសំខាន់ដែលត្រូវចងចាំថាអង្គការជនពិការអាចមានសមត្ថភាព និងធនធានមានកម្រិតកំណត់។ ក្នុងករណីមួយចំនួន ពួកគេមិនដែលបានទទួលវគ្គបណ្តុះបណ្តាល ឬមិនមានបទពិសោធន៍អំពីកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យពីមុនមកឡើយ។ ប៉ុន្តែ នេះមិនមែនមានន័យថាពួកគេមិនជំនាញដ៏មានតម្លៃនោះដែរ។ អង្គការជនពិការមួយចំនួន ប្រហែលជាចង់រៀនសូត្របន្ថែមទៀតអំពីកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ។ អង្គការជនពិការទាំងអស់សុទ្ធតែមានអាទិភាពជាយុទ្ធសាស្ត្ររបស់ខ្លួន ហេតុនេះ ជាការសំខាន់ណាស់ដែលត្រូវប៉ះប៉ូវសងទៅពួកគេវិញ សម្រាប់ពេលវេលាដែលពួកគេបានផ្តល់ឲ្យអ្នក។ សរុបសេចក្តីមក អង្គការជនពិការគឺជាអង្គការតំណាងរបស់ជនពិការ។ ដូច្នេះ ប្រសិនបើកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ ចង់ធានាឲ្យមានការចូលរួមរបស់ជនពិការ អ្នកពាក់ព័ន្ធរបស់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ ចាំបាច់ត្រូវសហការឱ្យបានកាន់តែច្រើនថែមទៀតជាមួយអង្គការជនពិការដើម្បីជួយកសាងសមត្ថភាពគ្នាទៅវិញទៅមកក្នុងវិស័យទាំងពីរ។

## ការផ្សារភ្ជាប់ជាមួយនិងកម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍

យុទ្ធសាស្រ្តមួយទៀតក្នុងការភ្ជាប់ទំនាក់ទំនងជាមួយវិស័យពិការភាព គឺតាមរយៈកម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍។ កម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍គឺជាយុទ្ធសាស្រ្តមួយដែលបានយកមកអនុវត្តនៅកម្ពុជាតាំងពីដើមទស្សវត្សឆ្នាំ១៩៩០ មកម្លេះ។ កម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍គឺជាយុទ្ធសាស្រ្តមួយសម្រាប់ស្តារលទ្ធភាពពលកម្ម ផ្តល់សមភាពផ្នែកឱកាស កាត់បន្ថយភាពក្រីក្រ និងដាក់បញ្ចូលជនពិការទៅក្នុងសង្គម។ ពេលខ្លះកម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍អាចដាក់បញ្ចូលនូវសេវាទឹកស្អាត និងការលើកកម្ពស់អនាម័យផងដែរ។ គម្រោងស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍ គឺអនុវត្តនៅកម្រិតសហគមន៍ ដោយមានសេវាបញ្ជូនទៅថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិតាមការចាំបាច់ និងតាមការគួរ។ ជាការសំខាន់ផងដែរ ដែលត្រូវស្គាល់អំពីកម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍ដែលមានក្នុងតំបន់គោលដៅរបស់អ្នក ដើម្បីឱ្យអ្នកអាចបញ្ជូនជនពិការទៅទទួលសេវាពីកម្មវិធីទាំងនោះបាន។ កម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍អាចជួយអ្នកក្នុងការកំណត់រកជនពិការដែលមានក្នុងសហគមន៍ ព្រោះពួកគេមានបញ្ជីសម្រង់ឈ្មោះ។

**រចនាសម្ព័ន្ធអង្គការជនពិការនៅកម្ពុជា**




ដ្យាក្រាមទី 1៖ រចនាសម្ព័ន្ធអង្គការជនពិការក្នុងប្រទេសកម្ពុជា

## សមាគមមនុស្សចាស់ (OPA's) និងសហព័ន្ធសមាគមមនុស្សចាស់

សមាគមមនុស្សចាស់គឺជាអង្គការថ្នាក់មូលដ្ឋានដឹកនាំដោយមនុស្សចាស់ ដែលធ្វើការដើម្បីឆ្លើយតបជាមួយបញ្ហាសង្គម បញ្ហារូបវន្ត បញ្ហាសេដ្ឋកិច្ច និងបញ្ហាសុខភាព ក៏ដូចជាដើម្បីធ្វើឱ្យសុខុមាលភាពរបស់មនុស្សចាស់ និងក្រុមគ្រួសាររបស់ពួកគាត់មានភាពប្រសើរឡើង តាមរយៈសកម្មភាពសុខុមាលភាពសង្គម និងការអភិវឌ្ឍន៍ជនបទ។ សមាគមមនុស្សចាស់ ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩៨ មកម្ល៉េះ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញសេចក្តីណែនាំឱ្យបង្កើតសមាគមមនុស្សចាស់មួយកន្លែង នៅក្នុងឃុំ សង្កាត់នីមួយៗទូទាំងប្រទេស។ សមាគមមនុស្សចាស់ត្រូវបានបង្កើតឡើង ដើម្បីបំពេញចន្លោះខ្វះខាតផ្នែកការគាំទ្រសង្គមសម្រាប់មនុស្សចាស់ ដែលនៅរស់រានមានជីវិតក្រោយសង្គ្រាមស៊ីវិល និងអស្ថេរភាពនយោបាយ ដែលធ្វើឲ្យចុះទន់ខ្សោយយ៉ាងខ្លាំងទៅលើស្ថាប័នបែបប្រពៃណី ដូចជាគ្រួសារ តំបន់ និងសហគមន៍។ សមាគមមនុស្សចាស់ផ្តល់ឱកាសឱ្យមនុស្សចាស់បានមកជួបជុំគ្នា ប្រាស្រ័យទាក់ទងគ្នា និងជួយមនុស្សចាស់ណាដែលងាយរងគ្រោះជាងគេបំផុតនៅក្នុងសហគមន៍។ សមាគមមនុស្សចាស់ គឺជាវេទិកាមួយសម្រាប់សមាជិកសហគមន៍ដែលត្រូវបានគេជាត់ចេញ អាចលើកឡើងនូវបញ្ហារបស់ខ្លួនមានលទ្ធភាពទទួលបានសេវាកាន់តែប្រសើរឡើង និងចូលរួមយ៉ាងសកម្មជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និង ទីភ្នាក់ងារក្នុងស្រុកដទៃទៀត។ សមាគមមនុស្សចាស់ដែលមានចាប់ពី៥ក្រុមឡើងទៅ អាចបង្កើតទៅជាសហព័ន្ធមួយ ដែលជាការប្រមូលផ្តុំសមាគមមនុស្សចាស់មករួមគ្នាដើម្បីលើកឡើងអំពីបញ្ហារបស់មនុស្សចាស់ និងរួមចំណែកក្នុងការអភិវឌ្ឍន៍សហគមន៍។

សមាគមមនុស្សចាស់គឺជាដៃគូដ៏សំខាន់ និងជាធនធានក្នុងការអភិវឌ្ឍន៍ និងអនុវត្តកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលមនុស្សចាស់។ សមាគមមនុស្សចាស់ជួយធានាបានថាសម្លេងរបស់មនុស្សចាស់ស្តីពីទឹកស្អាត និងការលើកកម្ពស់អនាម័យត្រូវបានលើកឡើង ហើយចំណេះដឹងរបស់ពួកគាត់ត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំគម្រោងអភិវឌ្ឍន៍សហគមន៍។ សមាគមមនុស្សចាស់ផ្តល់យន្តការមួយសម្រាប់ការអនុវត្តសេវាទឹកស្អាត និងលើកកម្ពស់អនាម័យ និងដើរតួជាដំណរភ្ជាប់ទៅកាន់មនុស្សចាស់នៅក្នុងសហគមន៍របស់ពួកគាត់ រួមទាំងជនចាស់ជរាដែលងាយរងគ្រោះ និងទន់ខ្សោយជាងគេបំផុតផងដែរ។

## តួនាទីនិងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋាភិបាលចំពោះជនពិការ និងមនុស្សចាស់

មានស្ថាប័នរដ្ឋាភិបាលមួយចំនួនដែលអាចជាដៃគូជាមួយកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានលក្ខណៈរួមបញ្ចូលផងដែរ។ ស្ថាប័នរដ្ឋាភិបាលដែលទទួលខុសត្រូវលើបញ្ហាទាក់ទងជាមួយពិការភាព និងមនុស្សចាស់នៅក្នុងប្រទេសកម្ពុជាមានដូចខាងក្រោម៖

**នៅថ្នាក់ជាតិ៖**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទទួលខុសត្រូវក្នុងការសម្របសម្រួល និងអនុវត្តកម្មវិធីទាក់ទងនឹងកិច្ចការសង្គម អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយក្នុងនោះ អាណត្តិរបស់ក្រសួង រួមមាន៖

- ពង្រឹងសុខុមាលភាពសម្រាប់ជនរងគ្រោះ និងជនងាយរងគ្រោះ និងកិច្ចការគ្រួសារ
- ពង្រឹងសុខុមាលភាពកុមារ និងយុវនីតិសម្បទា
- ពង្រឹងសុខុមាលភាពជនពិការ
- ពង្រឹងសុខុមាលភាពមនុស្សចាស់
- ពង្រឹងសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ
- ពង្រឹងសុខុមាលភាពអតីតយុទ្ធជន
- ពង្រឹងសមត្ថភាពស្ថាប័ន និងពង្រឹងភាពជាដៃគូ

ក្រុមប្រឹក្សាសកម្មភាពជនពិការ គឺជាយន្តការសម្របសម្រួល និងពិគ្រោះយោបល់ថ្នាក់ជាតិ លើបញ្ហាពិការភាព ហើយអាណត្តិរបស់ក្រុមប្រឹក្សារួមមាន៖

- ផ្តល់ការពិគ្រោះយោបល់ផ្នែកបច្ចេកទេសលើបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម
- ជួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រពាក់ព័ន្ធ និងពិការភាព និងការស្តារលទ្ធភាពពលកម្ម
- លើកកម្ពស់ការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម

**នៅថ្នាក់ក្រោមជាតិ៖**

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជាសេនាធិការរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលខុសត្រូវក្នុងការសម្របសម្រួល និងអនុវត្តកិច្ចការសង្គម អតីតយុទ្ធជន និងយុវនីតិសម្បទានៅថ្នាក់ក្រោមជាតិ ដើម្បីជួយដល់ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក។

## ២.២ សកម្មភាពទី២៖ ការកំណត់រកជនពិការ និងមនុស្សចាស់នៅពេលចាប់ផ្តើមដំបូងនៃវដ្តកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ

ផ្នែកនេះផ្តល់នូវវិធីសាស្ត្របែបអនុវត្តជាក់ស្តែងក្នុងការកំណត់រកជនពិការ និងមនុស្សចាស់។ បញ្ហាលំបាកមួយដែលអ្នកផ្តល់សេវាទឹកស្អាត និងការលើកកម្ពស់អនាម័យ ច្រើនតែជួបប្រទះគឺការកំណត់រកជនពិការ និងមនុស្សចាស់នៅក្នុងអំឡុងពេលធ្វើផែនការ ដើម្បីអាចដាក់បញ្ចូលពួកគាត់ទៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យ។

ផ្នែកនេះផ្តល់ជូនអ្នកអាននូវសំណួរគន្លឹះ និងព័ត៌មានសំខាន់ៗមួយចំនួន ក្នុងការកំណត់រកជនពិការ និងមនុស្សចាស់ ដោយប្រើប្រាស់៖

១. ការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ
២. កិច្ចប្រជុំ និងការពិគ្រោះយោបល់ជាមួយសហគមន៍
៣. ការអង្កេតគ្រួសារ/ដំណើរការប្រមូលទិន្នន័យ

នៅក្នុងវិធីសាស្ត្រនីមួយៗខាងលើនេះ ប្រសិនបើគេសួរសំណួរសួរថា "តើមាននរណាម្នាក់មានពិការភាពដែរឬទេ?" នោះគេនឹងបានចំនួនជនពិការតិចជាងចំនួនពិត។ ការសិក្សាស្រាវជ្រាវបានបង្ហាញថា ជារឿយៗ អ្នកដឹកនាំសហគមន៍ និងសមាជិកសហគមន៍តែងឆ្លើយថា "ទេ" ចំពោះសំណួរនេះ ដោយសារហេតុផលផ្សេងៗជាច្រើន (ដូចជាការមាក់ងាយ ការដែលមិនសូវស្គាល់ពាក្យ "ពិការភាព" ឬ គិតថាពាក្យនេះគ្រាន់តែសំដៅចំពោះជនពិការប្រភេទជាក់លាក់ណាមួយ)។

វិធីសាស្ត្រមួយទៀតដើម្បីដោះស្រាយបញ្ហានេះគឺដកពាក្យ "ពិការភាព" ចេញ និងជំនួសមកវិញដោយសួរថា តើមាននរណាម្នាក់នៅក្នុងគ្រួសារ ឬ សហគមន៍មានការលំបាកក្នុងការដើរ ស្តាប់ មើល ឬចងចាំ ដែរឬទេ។ ខាងក្រោមនេះគឺជាសំនួរចំនួន៤ ដែលអ្នកសួរនៅអំឡុងពេលសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ ការប្រជុំជាមួយសហគមន៍ និងការស្ទាបស្ទង់មតិគ្រួសារ ដើម្បីកំណត់ថាតើមាននរណាមានកម្សោយអវៈយវៈ ឬ មិនមាន៖

*១. តើអ្នកមានការលំបាកក្នុងការមើល ដែរឬទេ បើទោះបីជាពាក់វ៉ែនតាក៏ដោយ?*
*២. តើអ្នកមានការលំបាកក្នុងការស្តាប់ ដែរឬទេ បើទោះបីជាប្រើឧករណ៍ជំនួយការស្តាប់ក៏ដោយ?*
*៣. តើអ្នកមានការលំបាក្នុងការដើរ ឬ ឡើងជណ្តើរ ដែរឬទេ?*

*៤. តើអ្នកមានការលំបាកក្នុងការចងចាំ ឬ ផ្តោតអារម្មណ៍ ដែរឬទេ?*

ប្រសិនបើមនុស្សម្នាក់ឆ្លើយថា "បាទ/ចាស" ចំពោះសំនួរណាមួយខាងលើ អ្នកត្រូវសួរថា តើពួកគេរងការលំបាកបែបនេះញឹកញាប់កម្រិតណា ដើម្បីឱ្យដឹងថាតើវាគឺជាពិការភាពអចិន្ត្រៃយ៍ (ឬគ្រាន់តែជារបួសរយៈពេលខ្លី)៖

*តើអ្នកមានការលំបាកបែបនេះ ញឹកញាប់កម្រិតណា៖ គ្រាន់តែពេលខ្លះ? ឬ គ្រប់ពេល?*

យើងនឹងពិភាក្សាបន្ថែមអំពីរបៀបប្រើប្រាស់សំណួរទាំងនេះ និងឱកាសដើម្បីផ្សព្វផ្សាយអំពីសិទ្ធិជនពិការ និងមនុស្សចាស់ដូចខាងក្រោម៖

**ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ**

ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗគឺជាមធ្យោបាយមួយដ៏ល្អក្នុងការកំណត់រកជនពិការ និងមនុស្សចាស់ទាំងនៅក្នុងការសម្ភាសន៍វិភាគស្ថានភាពធម្មតា (ដូចជា ជាមួយអ្នកដឹកនាំសហគមន៍ និងសមាគមមនុស្សចាស់) និងក្នុងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានបន្ថែមជាមួយវិស័យពិការភាព (អង្គការជនពិការ និងកម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍)។ គំនិតរួមមាន៖

- អ្នកដឹកនាំសហគមន៍៖ នៅពេលធ្វើផែនការកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជាមួយគ្នា ដោយដាក់បញ្ចូលសំណួរទាក់ទងនិងជនពិការ និងមនុស្សចាស់។ ឧទាហរណ៍ សួរសំណួរថាតើមានមនុស្សចាស់ និងជនពិការចំនួនប៉ុន្មាននាក់នៅក្នុងសហគមន៍របស់ពួកគេ ហើយអ្នកទាំងនោះរស់នៅទីកន្លែងណា និងមានកម្មវិធីអ្វីខ្លះដើម្បីគាំទ្រពួកគាត់។
- អង្គការជនពិការនៅមូលដ្ឋាន៖ សួរសំណួរថា តើមានជនពិការប៉ុន្មាននាក់ ដែលបានចូលរួមនៅក្នុងបណ្តាញ និងកំពុងរស់នៅក្នុងតំបន់ដែលមានកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ។
- សមាគមមនុស្សចាស់នៅមូលដ្ឋាន៖ សុំឲ្យសមាគមមនុស្សចាស់កំណត់រកមនុស្សចាស់នៅក្នុងសហគមន៍របស់ពួកគេ ហើយនិងសេចក្តីត្រូវការជាក់លាក់នៅក្នុងក្រុម។
- អ្នកផ្តល់សេវាពិការភាព ឬ ស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍ (ដូចជា មណ្ឌលស្តារលទ្ធភាពពលកម្ម)៖ សួរថាតើមានជនពិការប៉ុន្មាននាក់នៅក្នុងបណ្តាញរបស់ពួកគេ និង កំពុងរស់នៅក្នុងតំបន់សហគមន៍ដែលមានកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ។

**កិច្ចប្រជុំសហគមន៍**

ពេលកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍ ដើម្បីធ្វើផែនការជាមួយគ្នា ជាការសំខាន់ណាស់ដែលត្រូវអញ្ជើញជនពិការ មនុស្សចាស់ និងអង្គការតំណាងរបស់ពួកគាត់ (អង្គការជនពិការ និងសមាគមមនុស្សចាស់) ឲ្យមកចូលរួមផងដែរ។ ប្រសិនបើពួកគេមិនបានចូលរួមនៅក្នុងការប្រជុំចាំបាច់ត្រូវពិភាក្សាជាមួយសហគមន៍ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ពួកគេ និងស្វែងរកដំណោះស្រាយ ធ្វើយ៉ាងណាបង្កើនការចូលរួមរបស់ពួកគេ។ នេះគឺជាឱកាសសម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យដើម្បី៖

- សុំការជួយជ្រោមជ្រែងពីសហគមន៍ដើម្បីស្វែងរកទីកន្លែងដែលជនពិការ និង មនុស្សចាស់រស់នៅ។ សួរអ្នកចូលរួមនូវសំនួរនីមួយៗ ក្នុងចំណោមសំណួរទាំងបួនអំពីសមាជិកសហគមន៍របស់ពួកគេ។ សួរសហគមន៍អំពីមូលហេតុដែលពួកគេមិនអាចចូលរួមកិច្ចប្រជុំ។ ស្វែងរកឲ្យឃើញនូវទីកន្លែងដែលពួកគាត់រស់នៅ និងសុំឲ្យអ្នកដឹកនាំសហគមន៍ជួយអ្នករៀបចំការប្រជុំជាមួយពួកគាត់នៅពេលណាមួយ។

- លើកកម្ពស់ការយល់ដឹងដល់សហគមន៍អំពីសិទ្ធិជនពិការ និងមនុស្សចាស់ និងអំពីសារៈសំខាន់ក្នុងការដាក់បញ្ចូលជនពិការ និងមនុស្សចាស់នៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យតាំងពីដើមដំបូង។

**ស្ទាបស្ទង់មតិគ្រួសារ**

ការលំបាកដែលពាក់ព័ន្ធមួយទៀត គឺការវាស់វែងថាតើកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យពិតជាបានដាក់បញ្ចូលជនពិការ និងមនុស្សចាស់តាមរយៈការបំបែកទិន្នន័យទៅតាមប្រភេទរបស់វា។

ក្នុងករណីកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យធ្វើការស្ទាបស្ទង់មតិគ្រួសារ ដើម្បីប្រមូលទិន្នន័យមូលដ្ឋានទាក់ទងនឹងអ្នកចូលរួមនៅក្នុងកម្មវិធី ឬសហគមន៍របស់ពួកគេ ការស្ទាបស្ទង់មតិនោះអាចនឹងសួរថា "តើមាននរណាពិការនៅក្នុងគ្រួសារ ដែរឬទេ? មាន/គ្មាន"។

វិធីសាស្ត្រមួយផ្សេងទៀត ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ គឺត្រូវជៀសវាងប្រើពាក្យ "ពិការភាព" និងដោយឡែក ត្រូវសួរជំនួសដោយពាក្យថា តើមាននរណាម្នាក់នៅក្នុងគ្រួសារមានការលំបាកក្នុងការបំពេញមុខងារជាមូលដ្ឋាន ដូចជា ការដើរ ការស្តាប់ ការចងចាំ ឬ ការមើល ដែរឬទេ។ សូមមើលសំនួរទាំង៤នៅក្នុងប្រអប់ខាងលើ។ អ្នកអាចកត់ត្រាអំពីភាពកម្សោយអវយវៈ អាយុ និងភេទរបស់អ្នកនោះ។ ការធ្វើបែបនេះ អនុញ្ញាតិឱ្យអ្នកអាចចែកទិន្នន័យទៅតាមប្រភេទពិការភាព នៅក្នុងការសិក្សាមូលដ្ឋានរបស់អ្នក។ បន្ទាប់មក អ្នកអាចប្រៀបធៀបលទ្ធភាពទទួលបានសេវាទឹកស្អាត និងលើកកម្ពស់អនាម័យរបស់អ្នកមានកម្សោយអវយវៈណាមួយជាមួយអ្នកដទៃទៀតនៅក្នុងសហគមន៍ដែលមានអាយុ និងភេទដូចគ្នា តែជាអ្នកមិនមានកម្សោយអវៈយវៈ។

## ២.៣ សកម្មភាពទី៣៖ ការវាយតម្លៃរបាំងដែលរាំងស្ទះដល់ការលើកកម្ពស់ការដាក់បញ្ចូលជនពិការ និងមនុស្សចាស់ទៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ

ផ្នែកនេះមានបំណងជួយអង្គការទាំងឡាយ ក្នុងការអនុវត្តន៍ជំហានដំបូង ដើម្បីកំណត់ឱ្យឃើញថាតើមានអ្វីខ្លះដែលរារាំងមិនឱ្យមនុស្សចាស់ និងជនពិការអាចចូលរួម និងអាចមានលទ្ធភាពទទួលបានសេវាពីកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ។ តាមធម្មតា គេតែងហៅបញ្ហានេះថាជា "របាំង" ក្នុងការទទួលបានសេវាទឹកស្អាត និងលើកកម្ពស់អនាម័យ។ បន្ទាប់មកទៀត ជំហានទី២ គឺកំណត់រកដំណោះស្រាយ ឬ "កត្តាបង្កលក្ខណៈអំណោយផល" ដើម្បីទទួលបានសេវាទឹកស្អាត និងលើកកម្ពស់អនាម័យ។

មានរបាំងចំនួនបួនប្រភេទដែលនាំឲ្យប្រជាជនមិនអាចទទួលបានសេវាទឹកស្អាត និងលើកកម្ពស់អនាម័យ៖

- អាកប្បកិរិយា
- បរិស្ថានរូបវន្ត
- ទំនាក់ទំនង និងព័ត៌មាន
- ដំណើរការ និងគោលនយោបាយរបស់ស្ថាប័ន

គេអាចចៀសវាង ឬជំនះរបាំងទាំងនេះបានដោយប្រើយុទ្ធសាស្ត្រមួយចំនួន។ កត្តាសំខាន់បំផុតនៅក្នុងយុទ្ធសាស្ត្រទាំងនេះ គឺការចូលរួមរបស់ជនពិការ មនុស្សចាស់ និង/ឬ អង្គការតំណាង (អង្គការជនពិការ និង សមាគមមនុស្សចាស់)។ ពួកគេអាចជួយកំណត់រក និង វិភាគលើរបាំងនានា និងរកដំណោះស្រាយថ្មីៗ។

ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួន ស្តីពីរបាំងមួយចំនួនដែលច្រើនកើតមាននៅក្នុងប្រទេសកម្ពុជា ព្រមជាមួយដំណោះស្រាយដើម្បីជំនះរបាំងទាំងនេះ។ ករណីទាំងនេះគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ហើយជាការសំខាន់ណាស់ដែលត្រូវតែប្រើប្រាស់ដំណើរការដែលមានលក្ខណៈចូលរួម ដើម្បីវាយតម្លៃរបាំង និង កំណត់រកដំណោះ

ស្រាយនៅក្នុងសហគមន៍។ នៅចុងបញ្ចប់នៃផ្នែកនេះ មានមគ្គុទេសន៍ណែនាំអំពីសកម្មភាពបែបចូលរួម ដើម្បីកំណត់រករបាំង និង ដំណោះស្រាយជាមួយសហគមន៍នៅក្នុងអំឡុងពេលនៃដំណើរការកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ។

**របាំងទី១៖ អាកប្បកិរិយា**

អាកប្បកិរិយារបស់មនុស្សចំពោះជនពិការ និង មនុស្សចាស់អាចជាបញ្ហាមួយក្នុងចំណោមបញ្ហាធំៗបំផុតដែលរារាំងមិនឱ្យពួកគេចូលរួម និង ទទួលបានផលប្រយោជន៍ពីកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ។

អាកប្បកិរិយាដែលគេច្រើនសង្កេតឃើញមួយចំនួនមាន ដូចជា៖

- ជនពិការ និងមនុស្សចាស់មិនមានសមត្ថភាព
- មនុស្សមានពិការភាពដោយសារបានប្រព្រឹត្តខុសកាលពីជាតិមុន (កម្មពៀរ) ឬ ត្រូវបណ្តាសារ
- ពិការភាពអាចឆ្លងតាមរយៈការប្រើប្រាស់បរិក្ខារួមគ្នា
- ជនពិការគឺជាមនុស្សដែលមានគ្រោះថ្នាក់ អសីលធម៌ និង/ឬ មិនអាចមើលចិត្តផ្ទះ
- ការមើលថែមនុស្សចាស់គឺជាតួនាទីរបស់ក្រុមគ្រួសារពួកគាត់ផ្ទាល់ ឬ វត្តអារាមប៉ុណ្ណោះ

អាកប្បកិរិយាទាំងនេះអាចនាំឲ្យកើតមានជាការព្រព្រឹត្តជាក់ស្តែងក្នុងលក្ខណៈរើសអើងចំពោះជនពិការ និង មនុស្សចាស់ ព្រមទាំងផាត់ពួកគេចេញ ដូចជា៖

- ការផាត់ពួកគេចេញពីការសម្រេចចិត្តនៅក្នុងក្រុមគ្រួសារ និងសហគមន៍
- ការផាត់ពួកគេចេញពីការចូលរួមក្នុងសង្គមនៅក្នុងសហគមន៍របស់ពួកគេ និងនៅក្នុងក្រុមគ្រួសារ
- ការផាត់ពួកគេចេញពីការប្រើប្រាស់សេវាទឹកស្អាតសាធារណៈដែលអ្នកដទៃប្រើប្រាស់
- ការលាក់បាំងជនពិការដោយសារការអាម៉ាស និង ខ្លាចពួកគេនាំផលប៉ះពាល់ជាអវិជ្ជមានមកលើឋានៈគ្រួសារ។

*ដំណោះស្រាយដើម្បីឆ្លើយតបជាមួយរបាំងទី១៖ ការជម្រុញឲ្យមានអាកប្បកិរិយាវិជ្ជមាន*

- កម្មវិធីគួរដាក់បញ្ចូលជនពិការ និងមនុស្សចាស់នៅក្នុងសកម្មភាពធ្វើផែនការ ការអនុវត្តន៍ និងការវាយតម្លៃទាំងអស់ដែលអាចធ្វើបាន រួមទាំងធ្វើឱ្យមានការចូលរួមពីអ្នកតំណាងអង្គការជនពិការ និងសមាគមមនុស្សចាស់ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលមានជំនាញក្នុងការធ្វើការជាមួយក្រុមទាំងនេះរួចហើយ។ ត្រូវពិចារណាយកចិត្តទុកដាក់ផងដែរទៅលើសេចក្តីត្រូវការផ្សេងៗគ្នារបស់មនុស្សនៅក្នុងក្រុមទាំងនេះ (ឧ. ស្រ្តីពិការគ្រប់គ្រងអនាម័យពេលមានរដូវរបស់ពួកគេប្រកបដោយប្រសិទ្ធភាព)។
- កម្មវិធីបណ្តុះបណ្តាល ឬ សិក្ខាសាលាសម្រាប់មន្ត្រីគម្រោង អ្នកដឹកនាំសហគមន៍ មន្ត្រីស្ថាប័ន (សាលារៀន មណ្ឌលសុខភាព) ទាក់ទងនឹងការយល់ដឹងអំពីពិការភាព។ វគ្គបណ្តុះបណ្តាលដែលមានប្រសិទ្ធភាពបំផុត គឺមានការចូលរួមពីតំណាងអង្គការជនពិការ សមាគមមនុស្សចាស់ និងតំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលមានជំនាញក្នុងការធ្វើការជាមួយក្រុមដែលមិនត្រូវបានគេយកចិត្តទុកដាក់ទាំងអស់នេះ។
- ការផ្តួចផ្តើមគំនិតផ្នែកការប្រាស្រ័យទាក់ទងដែលជួយលើកកម្ពស់ជនពិការ និងមនុស្សចាស់ជាវិជ្ជមានព្រមទាំងលើកកម្ពស់ការយល់ដឹងរបស់គ្រួសារ សហគមន៍ និងសាធារណៈជន អំពីបញ្ហាពិការភាព និងមនុស្សចាស់ (ដូចជានៅតាមរោងមហោស្រព ព្រឹត្តិការណ៍អប់រំសាធារណៈ ប្រព័ន្ធផ្សព្វផ្សាយសង្គមជាដើម)។

- ការបើកទូលាយសម្រាប់ជនពិការតាមរយៈអន្តរទំនាក់ទំនងដូចជា កន្លែងធ្វើការ និង កិច្ចប្រជុំដែលមានលក្ខណៈរួមបញ្ចូល ឬ សកម្មភាពរួមគ្នាជាមួយអង្គការជនពិការ តាមរយៈការបង្ហាញរូបភាពជនពិការនៅក្នុងសម្ភារៈផ្សព្វផ្សាយអំពីកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យ ដើម្បីលើកកម្ពស់សមត្ថភាពរបស់ជនពិការ ឱ្យស្របគ្នាជាមួយជនមិនពិការ ។
- មន្ត្រីគម្រោងធ្វើជាជនគំរូក្នុងការប្រកាន់ឥរិយាបទវិជ្ជមានចំពោះជនពិការ និងមនុស្សចាស់។

**របាំងទី២ និងទី៣៖ បរិស្ថានរូបវន្ត និងទំនាក់ទំនង និង ព័ត៌មាន**

បរិស្ថាននរូបវន្តអាចធ្វើឱ្យជនពិការ ឬ មនុស្សចាស់អាច ឬ មិនអាចចូលរួម និងទទួលបានសេវាទឹកស្អាត និងលើកកម្ពស់អនាម័យបាន។ ឧទាហរណ៍អំពីផលប៉ះពាល់នៃរបាំងមិនឱ្យគេអាចទទួលបានសេវាទឹកស្អាត និងលើកកម្ពស់អនាម័យរួមមាន៖

- បង្គន់សង់ខ្ពស់ផុតពីដី និងមានតែកាំជណ្តើរសម្រាប់ដើរឡើង នៅតាមសាលារៀន ឬ កន្លែងធ្វើការ អាចរារាំងមិនឱ្យបុគ្គលទាំងឡាយដែលមានការលំបាកក្នុងការដើរ ឬ អ្នកប្រើរទេះរុញទៅសាលារៀន ឬទៅធ្វើការ និងមានផលប៉ះពាល់ដល់សមត្ថភាពពួកគេក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាទូទៅ។
- ទីកន្លែងផ្តល់សេវាទឹកស្អាត និងការលើកកម្ពស់អនាម័យដែលមិនបានបង្កលក្ខណៈងាយស្រួល និងនៅឆ្ងាយ អាចបង្ខំឲ្យអ្នកដែលមានពិការភាពផ្នែករាងកាយ ឬ អ្នកមានកម្សោយគំហើញ ឬ អ្នកដែលមានការលំបាកក្នុងការបម្លាស់ទី ត្រូវលូននៅលើកម្រាលឥដ្ឋ ដើម្បីបន្ទោរបង់ ឬ បន្ទោរបង់នៅក្រៅបង្គន់ និង/ឬ ប្រើប្រាស់ដៃរបស់ពួកគេដើម្បីរកមាត់បង្គន់។ ចំណុចនេះ បង្កឱ្យមានបញ្ហាខ្វះ អនាម័យ និងអាចបង្កឲ្យមានហានិភ័យដល់សុខភាព និងសុវត្ថិភាពរបស់ជនពិការ និងមនុស្សចាស់ ក៏ដូចជាប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងអារម្មណ៍នៃការឱ្យតម្លៃចំពោះខ្លួនឯងរបស់ពួកគេផងដែរ។
- អណ្តូងស្នប់សហគមន៍ដែលមានផ្ទៃខឿនខ្ពស់នៅជុំវិញ ធ្វើឱ្យជនពិការ និងមនុស្សចាស់មិនអាចទៅដងទឹកដោយខ្លួនឯងបាន។

ចំណុចនេះក៏ដូចគ្នាផងដែរសម្រាប់ទំនាក់ទំនង និងព័ត៌មាន៖

- វិធីក្នុងការបញ្ជូនសារប្រាស្រ័យទាក់ទងអាចជួយជម្រុញការចូលរួមផង ហើយក៏អាចបង្កើតរបាំងមិនឱ្យគេអាចចូលរួមបានផងដែរ។ ឧទាហរណ៍ អ្នកដែលមានកម្សោយគំហើញអាចនឹងត្រូវបានផាត់ចេញប្រសិនបើព័ត៌មានផ្លាស់ប្តូរឥរិយាបទ ស្តីពីអនាម័យមួយ មានតែក្នុងទម្រង់ជាសម្ភារៈសម្រាប់មើល ប៉ុន្តែមិនមានផ្តល់សារដូចគ្នានេះជាសម្លេងផងដែរនោះ។
- នៅកម្រិតសហគមន៍ ជាទូទៅក៏មានកង្វះខាតព័ត៌មានអំពីការអនុវត្តទឹកស្អាត និងអនាម័យប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សចាស់ និងជនពិការផងដែរ។

*ដំណោះស្រាយដើម្បីឆ្លើយតបចំពោះរបាំងផ្នែករូបវន្ត ទំនាក់ទំនង និងព័ត៌មាន៖*

- ការចែករំលែកធនធាន (ឧ. ការរចនាបច្ចេកទេសដែលបង្កឲ្យមានលក្ខណៈងាយស្រួល បច្ចេកទេសទំនាក់ទំនង និងកញ្ចប់ឧបករណ៍ផ្សព្វផ្សាយ) ដើម្បីគាំទ្រដល់ការបង្កើតដំណោះស្រាយ។
- ផ្តល់វគ្គបណ្តុះបណ្តាល និងការគាំទ្រដល់បុគ្គលិកដែលទើបធ្វើការលើកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានលក្ខណៈរួមបញ្ចូលជាលើកដំបូង។ នេះគឺជាដំណើរការដ៏សំខាន់ខ្លាំងណាស់ ហើយត្រូវបន្តធ្វើដោយជាប់លាប់ អាស្រ័យដោយកម្មវិធីត្រូវស្វែងយល់អំពីស្ថានភាពរបស់ជនពិការ និងមនុស្សចាស់ក្នុងចំណោមប្រជាជនគោលដៅ តាមរយៈការវិភាគរបាំងគ្រប់ជ្រុងជ្រោយ ព្រមទាំងត្រូវយល់ដឹងអំពីបញ្ហានានាដែលជនពិការ និងមនុស្សចាស់កំពុងជួបប្រទះ។ ឆ្លងតាមរយៈ

ដំណើរការទាំងមូលនេះ បុគ្គលិករបស់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ នឹងមានការយល់ដឹងកាន់តែច្រើនអំពីកត្តាបង្កលក្ខណៈងាយស្រួល និងបញ្ហាប្រឈមព្រមទាំងគំនិតយល់ខុសនានា ហេតុនេះចាំបាច់ត្រូវតែមានការបន្តគាំទ្រ។

- ប្លង់បច្ចេកទេសកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យដែលមានលក្ខណៈបង្កភាពងាយស្រួល ចាំបាច់ត្រូវតែបង្កើតឡើងនៅមុនការសាងសង់ជាក់ស្តែង ដើម្បីធានាយ៉ាងណាអាចឆ្លើយតបនឹងប្លង់ការរចនាជាសាកលក្នុងការអនុវត្តន៍ជាក់ស្តែង។ វិធីមួយដើម្បីអាចសម្រេចការងារនេះបាន គឺត្រូវយកគោលការណ៍ RECU មកអនុវត្ត។ វិធីមួយទៀត គឺត្រូវប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យលើលទ្ធភាពទទួលបាន និងសុវត្ថិភាព។ សូមមើលទំព័រ៤៨ ឬ អាននៅគេហទំព័រភ្ជាប់ខាងក្រោម៖ http://www.inclusivewash.org.au/resource-library-inclusive-wash-training-materials.

*ដំណោះស្រាយដើម្បីឆ្លើយតបចំពោះរបាំងផ្នែកទំនាក់ទំនង៖*

- ដាក់សញ្ញាបង្ហាញទីតាំងកន្លែងឱ្យបានច្បាស់លាស់ និង មាននៅច្រើនកន្លែង នៅត្រឹមភ្នែកដើម្បីឱ្យងាយមើលឃើញ ហើយជាការល្អគួរតែជាអក្សរផុស ដែលអាចស្ទាបអានដឹង។ ត្រូវផ្តល់ និងបង្ហាញព័ត៌មានតាមទម្រង់ និងវិធីសាស្ត្រផ្សេងៗ រួមទាំងព័ត៌មានដែលអាចមើលឃើញ ព័ត៌មានជាសម្លេង និងព័ត៌មានជាភាសាធម្មតា (ឧ. ខិតប័ណ្ណ ផ្ទាំងរូបភាព រូបភាពតំណាងឲ្យខ្លឹមសាររឿង ការផ្សព្វផ្សាយតាមវិទ្យុ ជាដើម) អំពីកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ។
- ដាក់ឲ្យមានតំណាងជនពិការ និងមនុស្សចាស់នៅក្នុងសម្ភារៈទំនាក់ទំនង ដើម្បីបង្ហាញឲ្យឃើញថាថាពួកគេជាផ្នែកមួយរបស់សហគមន៍ និងគួរតែត្រូវបានដាក់បញ្ចូល។
- ធ្វើឲ្យមានការចូលរួមពីសមាគមមនុស្សចាស់ ក្នុងការផ្សព្វផ្សាយសារទំនាក់ទំនងទៅកាន់មនុស្សចាស់នៅក្នុងសហគមន៍របស់ពួកគាត់
- រាល់ព័ត៌មានជាលាយលក្ខណ៍អក្សរទាំងអស់ ដែលប្រើប្រាស់នៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ ត្រូវតែគិតអំពីលទ្ធភាពទទួលបានព័ត៌មាន ដោយត្រូវប្រើប្រាស់៖ អក្សរទំហំធំ និងពណ៌ចំណាំង ៧០% ឬ លើសពីរនេះ ត្រូវប្រើប្រាស់ភាសាងាយស្រួលអាន ព័ត៌មានជារូបភាព និងសម្លេង និងសញ្ញាដែលគេអាចយល់បានតាមរយៈការស្ទាប។ សូមមើលផ្នែកទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត សូមមើលទំព័រ ៣៨។

**របាំងទី៤៖ ដំណើរការ និងគោលនយោបាយរបស់ស្ថាប័ន**

ដំណើរការ និងគោលនយោបាយរបស់ស្ថាប័ន គឺជាផ្នែកដ៏សំខាន់ក្នុងការផ្តល់បរិយាកាសអំណោយផលសម្រាប់មនុស្សចាស់ និងជនពិការ នៅក្នុងវិស័យទាំងអស់ដែលបានលើកឡើងខាងលើ។ របាំងក្នុងការទទួលបានសេវាទឹកស្អាត និងលើកកម្ពស់អនាម័យ អាចបណ្តាលមកពីមូលហេតុដូចជា៖

- បទដ្ឋានអាគារ ដែលត្រូវបានសាងសង់ឡើងទៅតាមសេចក្តីត្រូវការរបស់ជនមិនពិការ (ពោលគឺ មិនបានអនុវត្តតាមគោលការណ៍ប្លង់ការរចនាជាសកល សូមមើលប្រអប់ខាងក្រោម) និង
- ខ្វះខាតធនធានចាត់តាំងសម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ និងខ្វះខាតការបណ្តុះបណ្តាលបុគ្គលិកស្តីពីការប្រើប្រាស់វិធីសាស្ត្រដាក់បញ្ចូលនៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ ដែលនាំឲ្យបុគ្គលិកមើលរំលងជនពិការ និងមនុស្សចាស់ដោយអចេតនា។
- ខ្វះខាតចំណេះដឹងស្តីអំពីគោលការណ៍ប្លង់ការរចនាជាសាកល និងខ្វះខាតយុទ្ធសាស្ត្រផ្នែកអង្គភាពដើម្បីដាក់ជនពិការ គឺជារបាំងដ៏គួរឲ្យកត់សម្គាល់។

## ប្រអប់ទី ១៖ការទៅដល់ ចូល ការផ្លាស់ទី ការប្រើប្រាស់

**សង្វាក់ចលនាដែលមិនអាចផ្តាច់ពីគ្នាបាន (RECU)**

ការទៅដល់ ចូល ការផ្លាស់ទី ការប្រើប្រាស់(RECU) គឺជាគោលការណ៍មួយដែលអាចជួយអ្នកប្រកបវិជ្ជាជីវៈផ្នែកផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ ដែលធ្វើការលើការរចនាប្លង់ទីកន្លែង ឱ្យពិចារណាលើរបៀបដែលមនុស្សទៅដល់ ចូល ធ្វើចលនា និងប្រើប្រាស់កន្លែងផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ៖

- **ការទៅដល់៖** អ្វីខ្លះដែលមនុស្សត្រូវការប្រើប្រាស់ ក្នុងការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយនៅក្នុងសហគមន៍ ដើម្បីចេញពីផ្ទះរបស់ខ្លួន ទៅដល់សេវាផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ។ ឧទាហរណ៍ រងតទ្ទិពលពីផ្លូវ ដំណភ្ជាប់ផ្លូវ ជម្រាល ប្រព័ន្ធការដឹកជញ្ជូន ស្លាកសញ្ញា ពណ៌ចំណាំង និងផ្ទៃតជួសម្រាប់ជនពិការភ្នែកស្ទាបធ្វើដំណើរ។
- **ចូល៖** មានសមត្ថភាពចូលទៅក្នុងកន្លែងផ្គត់ផ្គង់ទឹកស្អាត និង លើកកម្ពស់អនាម័យដែលជននោះមានបំណងប្រើប្រាស់។ ឧទាហរណ៍ ត្រូវរងតទ្ទិពលពីជណ្តើរជម្រាលធ្លាក់បង្កាន់ដៃទទឹងទ្វារ និង ដៃទ្វារ។
- **ការផ្លាស់ទី៖** សមត្ថភាពអាចផ្លាស់ទីនៅក្នុងកន្លែងផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ៖ ឧ. ត្រូវរងតទ្ទិពលដោយច្រករបៀង ធ្នឹមទ្វារ ទទឹងទ្វារ កន្លែងសម្រាក ស្លាកសញ្ញា និងទំហំ (ឧ. ត្រូវឲ្យផ្ទៃខាងក្នុងមានទំហំយ៉ាងតិច១៥០០មម x ១៥០០មម ដើម្បីឲ្យអ្នកជិះរទេះរុញអាចបត់ត្រលប់ក្រោយ ឬ បត់ចុះឡើងបាន)។
- **ការប្រើប្រាស់៖** សមត្ថភាពអាចប្រើប្រាស់សេវា និងកន្លែងផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យបាន៖ ឧ. ត្រូវរងតទ្ទិពលពីទំហំ និង ប្លង់រចនាគ្រឿងសង្ហារិមផ្ទៃខាងក្នុង និងការប្រាស្រ័យទាក់ទង ឧ. កម្ពស់រ៉ូប៊ីណេទឹក ប្រភេទរ៉ូប៊ីណេទឹក ស្លាកសញ្ញា។

*ដំណោះស្រាយចំពោះរបាំងទី៤៖*

- បង្កើតប្លង់រចនា និងគោលការណ៍ណែនាំអំពីការបង្កលក្ខណៈងាយស្រួល និងបណ្តុះបណ្តាលអ្នកម៉ៅការសំណង់នៅមូលដ្ឋាន។
- វគ្គបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងអំពីពិការភាព និងមនុស្សចាស់ សម្រាប់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលរបស់អង្គការ ដើម្បីស្ថាបនាការគាំទ្រវិធីសាស្ត្រដែលមានការដាក់បញ្ចូលក្នុងគោលបំណងឲ្យមានការបែងចែកកញ្ចប់ថវិកាសម្រាប់សកម្មភាពទាំងនេះ។
- ពិនិត្យឡើងវិញលើវដ្តគម្រោង និងដំណើរការ និងធ្វើការកែសម្រួលប្រសិនបើចាំបាច់។
- បង្កើតយុទ្ធសាស្ត្រស្ថាប័នសម្រាប់វិធីសាស្ត្រការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យដែលមានលក្ខណៈរួមបញ្ចូលសម្រាប់ជនពិការ។
- ពិចារណាកែសម្រួលហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យដែលមានស្រាប់ជាបណ្តើរៗ ដើម្បីធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធនោះកាន់តែបង្កលក្ខណៈងាយស្រួល អនុលោមតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD)។

## ប្រអប់ទី 2៖ គោលការណ៍ប្លង់រចនាជាសកល

**គោលការណ៍ប្លង់រចនាជាសកល**[14]

ប្លង់រចនាសកល មានន័យថា ផលិតផល បរិស្ថាន កម្មវិធី និងសេវា អាចត្រូវបានប្រើប្រាស់ដោយមនុស្សទាំងអស់ បានយ៉ាងច្រើនបំផុតតាមដែលអាចធ្វើបាន ដោយពុំចាំបាច់កែសម្រួល ឬ ការរចនាជាពិសេសឡើយ (អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ)។ ការធានាឱ្យបាននូវបទដ្ឋានលទ្ធភាពទទួលយកបាន តាមរយៈការយកគោលការណ៍ប្លង់រចនាមកប្រើប្រាស់ នឹងនាំឲ្យមានបរិស្ថានកាន់តែមានសុវត្ថិភាពថែមទៀតសម្រាប់មនុស្សទាំងអស់គ្នា រួមទាំងកុមារ ស្ត្រីមានផ្ទៃពោះ មនុស្សដែលមានទម្ងន់ធ្ងន់ មនុស្សចាស់ អ្នកជំងឺ ឬអ្នកមានកម្សោយអវយវៈបណ្តោះអាសន្ន អ្នករបួស និងជនពិការ។

ការអនុវត្តតាមគោលការណ៍ប្លង់រចនាជាសកលទាំងប្រាំពីរចំណុចនេះនឹងជួយឲ្យអ្នកប្រកបវិជ្ជាជីវៈអាចឆ្លើយតបតាមសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់បានច្រើននាក់បំផុតតាមដែលធ្វើបាន។

**គោលការណ៍ទី១៖ ការប្រើប្រាស់ដោយស្មើភាពគ្នា**

ការរចនាដែលមានប្រយោជន៍ និងអាចដាក់លក់ជូនដល់មនុស្សមានសមត្ថភាពផ្សេងៗគ្នាជាច្រើន។

**គោលការណ៍ទី២៖ មានភាពបត់បែនក្នុងការប្រើប្រាស់**

ការរចនាដែលអាចសម្របតាមចំណូលចិត្តនិងសមត្ថភាពរបស់បុគ្គលផ្សេងៗគ្នាជាច្រើន។

**គោលការណ៍ទី៣៖ សាមញ្ញ និងងាយស្រួលប្រើប្រាស់**

ការរចនាដែលមានភាពងាយស្រួលយល់ មិនថាអ្នកប្រើប្រាស់នោះមានបទពិសោធន៍ ចំណេះដឹង ជំនាញ ឬ មានការផ្តោតអារម្មណ៍កម្រិតណាឡើយ

**គោលការណ៍ទី៤៖ ព័ត៌មានដែលអាចយល់បាន**

ការរចនាដែលទំនាក់ទំនងព័ត៌មានចាំបាច់ប្រកបដោយប្រសិទ្ធភាពសម្រាប់អ្នកប្រើប្រាស់ ដោយមិនប្រកាន់ចំពោះលក្ខខណ្ឌជុំវិញខ្លួន ឬ សមត្ថភាពអង្គវិញ្ញាណរបស់អ្នកប្រើប្រាស់។

**គោលការណ៍ទី៥៖ ធន់នឹងកំហុស**

ការរចនាដែលកាត់បន្ថយគ្រោះថ្នាក់ និង ផលវិបាកអវិជ្ជមានបណ្តាលមកពីសកម្មភាពដោយចៃដន្យ ឬ អចេតនាឲ្យនៅកម្រិតអប្បបរមា

**គោលការណ៍ទី៦៖ ប្រើកម្លាំងកាយតិចតួច**

ការរចនាដែលអាចប្រើប្រាស់បានដោយប្រសិទ្ធភាព និងយ៉ាងងាយស្រួលដោយប្រើកម្លាំងតិចបំផុត។

**គោលការណ៍ទី៧៖ ទំហំ និងទីកន្លែងសម្រាប់ចូលទៅជិត និងប្រើប្រាស់**

ការរចនាដែលផ្តល់ទំហំ និងទីកន្លែងសមស្រប ដើម្បីចូលទៅជិត ចូលទៅដល់ អាចគ្រប់គ្រង និងប្រើប្រាស់បាន ដោយមិនប្រកាន់ទំហំខ្លួន ឥរិយាបថ ឬការបម្លាស់ទីរបស់អ្នកប្រើប្រាស់។

[14] ភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍអន្តរជាតិ (២០១៣)។ *មគ្គុទេសន៍ការរចនាសម្រាប់លទ្ធភាពទទួលយកបាន៖ គោលការណ៍ប្លង់រចនាជាសកលសម្រាប់កម្មវិធីជំនួយរបស់អូស្ត្រាលី។* ទីក្រុងកងបេរ៉ា ភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍអន្តរជាតិ។

## ប្រអប់ទី ៣៖ ការវិភាគរបាំងដោយមានការចូលរួម

សកម្មភាពអនុវត្ត៖ ការវិភាគរបាំងដោយមានការចូលរួម

ជម្រើសមួយដើម្បីវាយតម្លៃ និងយល់ដឹងអំពីរបាំងដែលបានបកស្រាយខាងលើ គឺត្រូវអនុវត្តការវិភាគរបាំងដោយមានការចូលរួមពីក្រុមសមាជិកសហគមន៍។ ការវិភាគប្រភេទនេះ អាចធ្វើឡើងបានជាផ្នែកមួយនៃកម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យ និង ទំនាក់ទំនងដើម្បីការផ្លាស់ប្តូរការព្រឹត្ត ឬ សកម្មភាពកម្មវិធីផ្គត់ផ្គង់ទឹកស្អាត។ សកម្មភាពនេះមិនត្រឹមតែអាចជួយដល់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យក្នុងការប្រមូលព័ត៌មានអំពីរបាំង និងដំណោះស្រាយតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចរួមចំណែកក្នុងការបង្កើតផែនការ សកម្មភាពការបង្កលក្ខណៈងាយស្រួល និងការលើកកម្ពស់ចំណេះដឹងនៅក្នុងសហគមន៍ផងដែរ។

ការវិភាគរបាំងដោយមានការចូលរួមគឺជាចំណុចដែលសមាជិកសហគមន៍មកវាយតម្លៃលើសេវាទឹកស្អាត និងអនាម័យក្នុងក្រុមដែលមានសមាជិកចម្រុះគ្នាទាំងស្ត្រី ទាំងបុរសទាំងជនពិការ និងមិនពិការ និងមានអាយុខុសៗគ្នា។ អ្នកចូលរួមពិភាក្សាអំពីរបាំងក្នុងការទទួលបានទឹកស្អាត និងអនាម័យ និងបែងចែករបាំងទាំងនោះទៅតាមប្រភេទរបាំងទាំង៤ (រៀបរាប់ខាងលើ)៖

- អាកប្បកិរិយា និងការប្រព្រឹត្តរបស់គ្រួសារ ឬសង្គម ការអនុវត្តក្នុងសង្គម ជំនឿបែបប្រពៃណី។
- បរិស្ថាន៖ របាំងរូបវន្តនៅក្នុងបរិស្ថានធម្មជាតិ និងបរិស្ថានដែលមនុស្សបង្កើតឡើង
- ទំនាក់ទំនង៖ របាំងក្នុងការទទួលបានព័ត៌មាន ការអប់រំ និង ទំនាក់ទំនង
- ស្ថាប័ន ឬអង្គភាព៖ ឧ. ច្បាប់ជាតិ គោលនយោបាយ យុទ្ធសាស្ត្រ ការអនុវត្តជាក់ស្តែងរបស់អង្គភាព សមត្ថភាពបុគ្គលិក កង្វះព័ត៌មានជាដើម។

បន្ទាប់មក ក្រុមនាំគ្នាពិភាក្សា និងស្នើឡើងនូវដោះស្រាយចំពោះរបាំងទាំងនេះ។

ខាងក្រោមនេះគឺជាឧទាហរណ៍មួយ ដែលបង្ហាញអំពីរូបរាងនៃវិភាគរបាំងដោយមានការចូលរួម៖

| | **របាំងក្នុងការទទួលបានសេវាទឹកស្អាតនិងការលើកកម្ពស់អនាម័យ** | **ដំណោះស្រាយដើម្បីទទួលបានសេវាទឹកស្អាត និងការលើកកម្ពស់អនាម័យ** |
|---|---|---|
| អាកប្បកិរិយា | • បន្ទុចបង្អាក់មិនឲ្យប្រើប្រាស់បង្គន់រួម<br>• បង្អាប់លេងសើច ឬ សម្លុត<br>• មិនមានការយកចិត្តទុកដាក់ពីក្រុមគ្រួសារ<br>• មិនអនុញ្ញាតឲ្យទៅដងទឹក | • រៀបចំយុទ្ធនាការផ្សព្វផ្សាយ ឬបើកវគ្គបណ្តុះបណ្តាលដល់សហគមន៍<br>• ផ្តោតគោលដៅលើអ្នកដឹកនាំសហគមន៍ផ្សេងៗគ្នាដើម្បីជម្រុញឲ្យមានការផ្លាស់ប្តូរសង្គម (មេដឹកនាំសាសនា) |
| រូបវន្ត | • បង្គន់នៅឆ្ងាយ<br>• ខ្វះភាពឯកជន<br>• គ្មានអ្វីសម្រាប់តោង<br>• កាំជណ្តើរខ្ពស់<br>• ទ្វារតូចចង្អៀត | • សង់បង្គន់ឲ្យនៅជិតបំផុត<br>• បង្គន់អង្គុយ<br>• បង្កាន់ដៃ<br>• បង្គន់មានភាពឯកជន (ចាក់សោបាន) |
| ទំនាក់ទំនង | • រូបភាព និងសម្ភារៈមានទំហំតូចពេក<br>• អ្នកសម្របសម្រួលនិយាយស្តាប់មិនលឺ | • រចនាសម្ភារៈឲ្យមានទម្រង់ច្រើនប្រភេទ រួមមានពុម្ពអក្សរធំៗ និងមានរូបភាព<br>• វគ្គបណ្តុះបណ្តាលសម្រាប់អ្នកសម្របសម្រួលសហគមន៍អំពីទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព |

| | | |
|---|---|---|
| ស្ថាប័ន | • ខ្វះខាតព័ត៌មានអំពីជម្រើសដែលមានការបង្កលក្ខណៈងាយស្រួល<br>• ខ្វះការប្រឹក្សាយោបល់ជាមួយជនពិការ | • បង្កើតគោលការណ៍ណែនាំអំពីការបង្កលក្ខណៈងាយស្រួល និងវគ្គបណ្តុះបណ្តាលដល់អ្នកម៉ៅការសំណង់នៅមូលដ្ឋាន<br>• ផ្តល់ឲ្យមានយុទ្ធនាការបង្ហាញអំពីបង្គន់ដែលបង្កលក្ខណៈងាយស្រួល |

## ៣. សហគមន៍ដឹកនាំអនុវត្តអនាម័យ (CLTS)៖ វិធីសាស្រ្តដែលមានការដាក់បញ្ចូល

**បទដ្ឋានអប្បបរមា៖ អនាម័យដែលបង្កឲ្យមានលក្ខណៈងាយស្រួល**

១. គួរមានប្រភេទបង្គន់រចនាឲ្យមានការបង្កលក្ខណៈងាយស្រួល ដោយប្រើប្រាស់គោលការណ៍ប្លង់រចនាជាសកលសម្រាប់ឲ្យក្រុមគ្រួសារជ្រើសរើស ហើយគួរតែចែករំលែកឲ្យដឹងអំពីម៉ូតថ្មីៗដែលមាននៅក្នុងវិស័យទាំងមូល។

២. ជនពិការ មនុស្សចាស់ និងក្រុមគ្រួសាររបស់ពួកគេ គួរបានចូលរួមនៅក្នុងការរចនា និងកំណត់ទីតាំងសម្រាប់សង់បង្គន់។

៣. គួរសង់បង្គន់នៅកន្លែងងាយស្រួលចេញចូល ដោយគិតគូអំពីលក្ខខណ្ឌភូមិសាស្រ្ត ផ្លូវដើរទៅបង្គន់ និងចម្ងាយរបស់បង្គន់ពីផ្ទះរបស់មនុស្សចាស់ និងជនពិការ។

៤. ជនពិការ មនុស្សចាស់ និងក្រុមគ្រួសាររបស់ពួកគេគួរបានចូលរួមចំណែកក្នុងការសាងសង់បង្គន់ ព្រមជាមួយ មិត្តភក្តិរបស់ពួកគេទៅតាមមធ្យោបាយដែលអាចធ្វើទៅបាន (ឧទាហរណ៍ ជនពិការកាយសម្បទាអាចចូលរួមចំណែកគ្រប់គ្រងសម្ភារៈ រីឯមនុស្សចាស់ដែលមានកម្សោយគំហើញ អាចចូលរួមការងារផែនការជាដើម)។

៥. អាស្រ័យដោយភាពក្រីក្រ និងពិការភាពមានចំណងទាក់ទងគ្នា ហើយជាលទ្ធផលអាចធ្វើឱ្យមានកម្លាំងពលកម្មកាន់តែតិចក្នុងគ្រួសារ ហេតុនេះគួរមានយន្តការសហគមន៍ដែលមានការបត់បែនបាន ដើម្បីឲ្យមានការគាំទ្របន្ថែមជាជំនួយផ្នែកហិរញ្ញវត្ថុ និងកម្លាំងពលកម្ម ក្នុងការរួមចំណែកសាងសង់បង្គន់សម្រាប់គ្រួសាររបស់ជនពិការ និងមនុស្សចាស់។

៦. គួរមានការដាក់បង្ហាញរូបភាពជនពិការ និង មនុស្សចាស់ ក្នុងលក្ខណៈជាវិជ្ជមានទៅក្នុងសម្ភារៈអប់រំផ្សព្វផ្សាយអំពីអនាម័យ។

"សហគមន៍ដឹកនាំអនុវត្តអនាម័យជួយបំផុសសហគមន៍ឲ្យប្រាថ្នាចង់បានការផ្លាស់ប្តូរជាសមូហភាព ជួយជម្រុញមនុស្សឲ្យធ្វើសកម្មភាព និងលើកទឹកចិត្តចំពោះការច្នៃប្រឌិត ការជួយគ្នាទៅវិញទៅមក និងដំណោះស្រាយសមស្របក្នុងមូលដ្ឋាន ដែលនាំឲ្យសហគមន៍មានភាពជាម្ចាស់ និងនិរន្តរភាពកាន់តែប្រសើរឡើង។"[15] ទិដ្ឋភាពចម្បងរបស់កម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យគឺត្រូវធានាថា "***មានការផ្សព្វផ្សាយឲ្យប្រជាជនជ្រាបថា ដរាបណាការបន្ទោរបង់ពាសវាលពាសកាលនៅតែមាន ទោះបីតិចតួចក្តី គ្រប់គ្នានឹងប្រឈមនឹងជម្ងឺ***"។ ការដាក់បញ្ចូលមនុស្សគ្រប់គ្នា ក៏ជាការសំខាន់ខ្លាំងផងដែរ ដើម្បីឲ្យគោលដៅរបស់សហគមន៍ដឹកនាំអនុវត្តអនាម័យអាចសម្រេចបានជោគជ័យ។

បុគ្គលិកកម្មវិធី គួរពិចារណាលើបញ្ហាអន្តរវិស័យរួមមានដូចជា ពិការភាព យេនឌ័រ និង ចាស់ជរា នៅពេលបង្កើតកម្មវិធីពាក់ព័ន្ធជាមួយការផ្លាស់ប្តូរការប្រព្រឹត្ត ដូចជាសហគមន៍ដឹកនាំអនុវត្តអនាម័យជាដើម។

ខាងក្រោមនេះគឺជាចំណុចចាប់ផ្តើមក្នុងការដាក់បញ្ចូលជនពិការ និង មនុស្សចាស់នៅក្នុងសហគមន៍ដឹកនាំអនុវត្តអនាម័យ ដោយយោងទៅតាមជំហាន និងឧបករណ៍នៃដំណើរការដែលមានចែងនៅក្នុងគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យ (ឆ្នាំ២០១៥) របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

[15] គោលការណ៍ណែនាំ CLTS ជាតិឆ្នាំ២០១៥

សូមមើលសកម្មភាពទី ៣ ដើម្បីបានដឹងអំពីវិធីសាស្ត្រអនុវត្តជាក់ស្តែងក្នុងការកំណត់រករបាំងរបស់សហគមន៍ដឹកនាំអនុវត្តអនាម័យសម្រាប់ជនពិការ និងមនុស្សចាស់។ សកម្មភាពទី ៣ អាចអនុវត្តបាននៅវគ្គមុនពេលបំផុស និងក្រោយពេលបំផុសរបស់ជំហានសហគមន៍ដឹកនាំអនុវត្តអនាម័យ។

## ៣.១ មុនពេលបំផុស

សូមមើលសកម្មភាពទី ២ ដើម្បីបានដឹងអំពីការអនុវត្តន៍ជាក់ស្តែងក្នុងការកំណត់រកជនពិការ និងមនុស្សចាស់នៅដំណាក់កាលដំបូងរបស់ជំហានកម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យ។ ជាការសំខាន់ណាស់ដែលអ្នកសម្របសម្រួលសហគមន៍ ដែលជាអ្នកដឹកនាំកម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យ បានទទួលការបណ្តុះបណ្តាល និងបានចូលរួមក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹងអំពីការរួមបញ្ចូលជនពិការ និងការចូលទៅរកមនុស្សចាស់។

**ការតម្រង់ទិសអំពីវិធីសាស្ត្រសហគមន៍ដឹកនាំអនុវត្តអនាម័យដល់ជនបង្គោលឃុំ និងប្រធានភូមិ**

- គួរណែនាំ និងពន្យល់អំពីវិធីសាស្ត្រដែលមានការដាក់បញ្ចូល នៅក្នុងអំឡុងពេលការប្រជុំតម្រង់ទិសជាមួយជនបង្គោលឃុំ (CFPs) និងប្រធានភូមិ ដោយលើកឡើងអំពីចំណុចមួយចំនួន ឧទាហរណ៍ដូចជា ដើម្បីឲ្យកម្មវិធីជោគជ័យបាន ទាមទារឲ្យមានការចូលរួមពីមនុស្សគ្រប់រូបនៅក្នុងសហគមន៍ រួមទាំងស្ត្រី បុរស ស្ត្រី និងបុរសពិការ ព្រមទាំងកុមារពិការ និងមិនពិការផងដែរ។
- កិច្ចប្រជុំនេះ ក៏រួមមានការពិភាក្សាពីការរៀបចំផងដែរ ដូចជាគិតអំពីទីកន្លែង និងពេលវេលាដែលសមស្របបំផុតសម្រាប់រៀបចំការប្រជុំពិភាក្សាជាមួយមេដឹកនាំ ដើម្បីឲ្យដឹងថា តើទីតាំងរូបវន្តនោះបង្កលក្ខណៈងាយស្រួលសម្រាប់មនុស្សគ្រប់គ្នា ដែរឬទេ។ ប្រសិនបើទីតាំងរូបវន្តមិនបានបង្ក លក្ខណៈងាយស្រួលទេនោះ ត្រូវពិចារណាលើចំណុចដូចខាងក្រោម៖
    - តើអាចកែសម្រួលទីកន្លែងនោះយ៉ាងណាដើម្បីអាចឲ្យមានលក្ខណៈរួមបញ្ចូលកាន់តែខ្លាំង?
    - ស្នើសុំជួបជាមួយអ្នកដែលមិនអាចទៅកាន់កន្លែងប្រជុំនោះដោយផ្ទាល់ ឬ
    - រៀបចំឲ្យមានតំណាងមកចូលរួមប្រជុំ ហើយឲ្យតំណាងនោះចែករំលែកព័ត៌មានទៅដល់អ្នកដែលមិនអាចមកចូលរួមបាន។
- របៀបធ្វើការពិភាក្សាអំពីមនុស្សម្នាក់ៗ មានសារៈសំខាន់ណាស់។ នៅក្នុងសហគមន៍ គេអាចមិនយល់ពាក្យ "ជនពិការ" ឬ ពាក្យនេះអាចមានការមាក់ងាយមកជាមួយផងដែរ។ ពេលខ្លះ ជាការល្អគួរនិយាយថា៖ *"ដើម្បីជួយពួកយើងរៀបចំផែនការប្រជុំរបស់ឲ្យបានល្អប្រសើរ យើងចង់ដឹងថាតើនៅក្នុងភូមិរបស់យើងមាននរណាម្នាក់ដែលមានការលំបាកក្នុងការមើលឃើញដែរ ឬទេ? តើមាននរណាមានការលំបាកក្នុងការស្តាប់ការសន្ទនាដែរ ឬទេ? តើមាននរណាមានការលំបាកក្នុងការដើរ ជាពិសេស នៅពេលឡើងជណ្តើរ ដែរឬទេ? តើមាននរណាម្នាក់មានការលំបាកក្នុងការប្រាស្រ័យទាក់ទង ឬទទួលព័ត៌មានដែរ ឬទេ?"*

- ជាការសំខាន់ណាស់ក្នុងការផ្តល់វាក្យស័ព្ទគំរូជាវិជ្ជមានទាក់ទងនឹងកម្សោយអវៈយវៈ ពិការភាព និងមនុស្សចាស់។ ប្រសិនបើសហគមន៍ប្រើពាក្យអវិជ្ជមានដើម្បីហៅជនពិការនៅក្នុងសហគមន៍ សូមផ្តល់ជម្រើសដោយឡែកយ៉ាងទន់ភ្លន់ដល់ពួកគេ ដើម្បីហៅអ្នកទាំងនោះ ឧទាហរណ៍ *"បងប្រុស/បងស្រី តើអាចឲ្យខ្ញុំសុំស្គាល់ឈ្មោះបានដែរ ឬទេ? ខ្ញុំចង់ស្គាល់ឈ្មោះរបស់បង ជាជាងប្រើ*

*ប្រាស់ពិការភាពរបស់បង ដើម្បីហៅបង។" "តើអ្នកដឹងទេថា អង្គការជនពិការកម្ពុជា (អង្គការតំណាងឲ្យជនពិការ) ជ្រើសរើសពាក្យ "ពិការភាព" នៅពេលដែលពណ៌នាអំពីពិការភាព? ពួកយើងក៏សូមជ្រើសរើសប្រើប្រាស់ពាក្យនេះនៅក្នុងការងាររបស់យើងផងដែរ"។*

## ៣.២ នៅពេលបំផុស

សម្រាប់វិធីបែបការអនុវត្តន៍ជាក់ស្តែងដើម្បីធ្វើឲ្យការចូលរួមរបស់មនុស្សចាស់ និងជនពិការមានភាពប្រសើរឡើង សូមមើលជំហានបែបអនុវត្តជាក់ស្តែងក្នុងសកម្មភាពទី១។

ដំណើរការនៅពេលធ្វើការបំផុសគឺជាសកម្មភាពដែលបង្ហាញនូវអារម្មណ៍ខ្ចីមរអើមរបស់សហគមន៍នៅពេលដែលពួកគេបានយល់ដឹងអំពីផលប៉ះពាល់ជាអវិជ្ជមាននៃការបន្ទោរពាសវាលពាសកាល។ គួរប្រាស្រ័យទាក់ទងព័ត៌មាននេះតាមមធ្យោបាយយ៉ាងណាដែលបង្កឲ្យមានលក្ខណៈងាយស្រួលទទួលបានសម្រាប់មនុស្សគ្រប់គ្នា រួមទាំងជនពិការ និងមនុស្សចាស់។ ការមិនដាក់បញ្ចូលពួកគេ អាចនាំឲ្យមានការផាត់ពួកគេចេញកាន់តែខ្លាំងថែមទៀត។

- ប្រសិនបើមានជនពិការ និង មនុស្សចាស់មិនបានចូលរួមនៅក្នុងការប្រជុំ អ្នកសម្របសម្រួលគួររៀបចំរកសមាជិកសហគមន៍ណាដែលអាចផ្តល់ព័ត៌មានបន្តទៅដល់ជនពិការ និង/ឬ រៀបចំទៅជួបពួកគេនៅតាមផ្ទះដើម្បីផ្តល់ព័ត៌មាន។
- នៅក្នុងពេលចាប់ផ្តើម ឬ ក្នុងដំណាក់កាលបំផុស ត្រូវធានាយ៉ាងណាសង្កេតអំពីរបៀបដែលសហគមន៍ធ្វើការប្រាស្រ័យទាក់ទងគ្នា។ តើនរណាកំពុងនិយាយ នរណាអង្គុយនៅកន្លែងណា តើមានចរន្ត ឬ ទំនាក់ទំនងអ្វីខ្លះដែលអាចជួយជម្រុញ/បន្ទុចបង្អាក់មិនឱ្យមនុស្សមួយចំនួនត្រូវបានដាក់បញ្ចូលទៅក្នុងការសម្រេចចិត្តនៅពេលក្រោយ។
- នៅពេលដែលសមាជិករបស់ក្រុមអ្នកសម្របសម្រួលអង្គុយ ឬ ឈរនៅកន្លែងផ្សេងៗគ្នា និងនៅលាយឡំជាមួយអ្នកភូមិ ត្រូវព្យាយាមផ្សាភ្ជាប់អ្នកចូលរួមជាមួយប្រធានក្រុមសម្របសម្រួល ហើយធានាថាអ្នកសម្របសម្រួលធ្វើការសង្កេត និងគាំទ្រការចូលរួមរបស់ស្ត្រី និងបុរសពិការ និងមនុស្សចាស់ (ដូចជា ចង្អុលបង្ហាញថាអ្នកចូលរួមម្នាក់នេះមានពាក្យចង់និយាយ *"សូមស្តាប់គាត់សិន"*)។

### ការប្រើប្រាស់ឧបករណ៍បំផុស

- ***សហគមន៍ធ្វើស្វ័យវិភាគអំពីការអនុវត្តក្នុងការបន្ទោរបង់របស់ពួកគាត់ និងផលប៉ះពាល់***

  មានឧបករណ៍បំផុសចំនួន៧ដែលអាចជួយសហគមន៍ក្នុងការធ្វើស្វ័យវិភាគ ហើយដែលមនុស្សគ្រប់គ្នានៅក្នុងសហគមន៍ គួរតែអាចប្រើប្រាស់បាន។ មានវិធីសម្របសម្រួលសម្រួលផ្សេងៗមួយចំនួនដែលអាចយកមកប្រើបានដែរ ដើម្បីកែលម្អលទ្ធភាពទទួលបានរបស់មនុស្សមានកម្សោយអវៈយវៈផ្សេងៗគ្នា ឧទាហរណ៍ ដូចជា រូបភាពសញ្ញា និងសម្ភារៈជាសម្លេងជាដើម។ កត្តានានាដែលត្រូវយកមកពិចារណានៅពេលធ្វើឲ្យព័ត៌មានមានលក្ខណៈងាយស្រួលអាចទទួលបាន៖

  - អ្នកសម្របសម្រួលគួរនិយាយចេញមកនូវរាល់ព័ត៌មាន ដែលបានផ្តល់ឲ្យនៅក្នុងអំឡុងពេលដំណើរការបំផុសរួមទាំងពេលដែលឧបករណ៍នោះត្រូវការការបង្ហាញដោយរូបភាព (ឧទាហរណ៍និយាយថា *"ឥឡូវនេះខ្ញុំដាក់សក់មួយសសៃនៅក្នុងលាមក ហើយឥលូវនេះខ្ញុំដាក់វា ទៅក្នុងដបទឹក...* ស្របពេលដែលសកម្មភាពបានកើតឡើង)។ ការធ្វើបែបនេះអាចជួយធានាបានថា អ្នកមានកម្សោយគំហើញ ក៏អាចទទួលបានព័ត៌មានផងដែរ។

- នៅទីណាដែលមានសមាជិកសហគមន៍ដែលមានការលំបាកក្នុងការស្ដាប់ (មនុស្សមានកម្សោយផ្នែកការស្ដាប់ រួមទាំងមនុស្សចាស់ផងដែរ) ត្រូវធានាថាពួកគេអង្គុយនៅខាងមុខដើម្បីឲ្យពួកគេអាចស្ដាប់ឮ និងមើលឃើញបានច្បាស់រាល់សកម្មភាពដែលបានកើតឡើង។ ម្យ៉ាងវិញទៀត សូមទុកពេលឲ្យអ្នកបកប្រែ និង/ឬ សមាជិកក្រុមគ្រួសារអាចជួយប្រាស្រ័យទាក់ទងសារទៅដល់អ្នកដែលមានការលំបាកក្នុងការស្ដាប់ ដើម្បីធានាថាពួកគាត់អាចចូលរួមបានដោយស្មើភាព។
- ជួយសម្រួល និង ធ្វើជាគំរូឲ្យឃើញថាមនុស្សគ្រប់រូបគួរតែចូលរួមយោបល់ស្ដីពីការផ្ដល់ព័ត៌មានអំពីគ្រួសាររបស់ពួកគេសម្រាប់ធ្វើការវិភាគ។ ឧទាហរណ៍ អ្នកសម្របសម្រួលអាចដាក់បញ្ចូលអ្នកដែលមានពិការភាពក្នុងការបម្លាស់ទី ឬ មានកម្សោយផ្នែកគំហើញតាមរយៈការសុំឲ្យពួករៀបរាប់ជាពាក្យសម្ដីដើម្បីឲ្យបុគ្គលិកគូររូបគ្រួសារ ឬសហគមន៍របស់ពួកគេ។
- ត្រូវធានាថាជនពិការ និងមនុស្សចាស់ចូលរួមនៅក្នុងសកម្មភាពដើរកំណត់ភូមិសាស្ត្រដោយត្រូវផ្ដល់ជម្រើសដល់មនុស្សទាំងអស់ថាតើគាត់ចង់ចូលរួម ឬអត់ និង ពិភាក្សាអំពីទីកន្លែងដែលនឹងត្រូវដើរ។ មិនត្រូវមានការសន្មតជាមុនអំពីសមត្ថភាពរបស់ជនពិការ និងមនុស្សចាស់ក្នុងការចូលរួមដើរកំណត់ភូមិសាស្ត្រឡើយ ដោយឡែកត្រូវសួរពួកគេសិន ថាតើពួកគេត្រូវការជំនួយដើម្បីអាចចូលរួម ឬទេ។
- ស្ត្រី និងកុមារីពិការគួរតែត្រូវបានដាក់បញ្ចូលនៅក្នុងការដើរកំណត់ភូមិសាស្ត្រជាមួយស្ត្រី ដើម្បីស្វែងយល់អំពីការអនុវត្ត និងការយល់ដឹងទាក់ទងនឹងអនាម័យនៅពេលមានរដូវ ហើយពួកគេប្រហែលជាត្រូវការ ឬមិនត្រូវការការជួយគាំទ្រជាលក្ខណៈបុគ្គល។
- នៅពេលពិភាក្សាដើម្បីដឹងថាតើគ្រួសារណាមានបង្គន់អនាម័យ ឬ មិនមាន អ្នកសម្របសម្រួលត្រូវប្រាកដថាបានសួរ ថាតើមនុស្សគ្រប់គ្នានៅក្នុងគ្រួសារអាចប្រើប្រាស់បង្គន់នោះបានឬទេ ដោយមិនត្រូវសន្មតថា ដោយសារតែមានបង្គន់ ដូច្នេះអ្នកគ្រប់គ្នានៅក្នុងគ្រួសារសុទ្ធតែអាចប្រើប្រាស់បានទាំងអស់គ្នានោះឡើយ។
- សូមពិនិត្យអង្កេតមើលក្រែងមានវត្តមានការចូលរួមរបស់ជនពិការ មនុស្សចាស់ ក៏ដូចជាស្ត្រី និងកុមារពិការដោយត្រូវចងចាំថាសហគមន៍ណាក៏ដោយអាចមានសមាជិកចំនួនចាប់ពី១០% ទៅ១៥% ជាជនពិការ។

➢ ***កំណត់សម្គាល់ទី១ ការបំផុសជាមួយកុមារនៅតាមសាលារៀន***[16]

កុមារពិការប្រហែលជាមិនបានចូលរៀននៅសាលា ដោយសារតែហេដ្ឋារចនាសម្ព័ន្ធមិនបានបង្កលក្ខណៈងាយស្រួល ឬគ្រូបង្រៀនខ្វះការយល់ដឹងអំពីរបៀបសម្របវិធីសាស្ត្របង្រៀនឲ្យមានការដាក់បញ្ចូល។ ជាការសំខាន់ណាស់ក្នុងការកំណត់រកកុមារពិការដែលមិនបានចូលរៀន និង ធានាឲ្យបានថាពួកគេបានទទួលព័ត៌មានដូចក្មេងដែលមកសាលារៀនផងដែរ។

## ៣.៣ ក្រោយពេលបំផុស

សូមមើលសកម្មភាពទី១ និង២ អំពីវិធីសាស្ត្រក្នុងការកំណត់រកជនពិការ និងមនុស្សចាស់ និងធ្វើឲ្យពួកគេមានការចូលរួមកាន់តែប្រសើរឡើងនៅក្នុងសកម្មភាពធ្វើផែនការរបស់សហគមន៍។

សកម្មភាពធ្វើផែនការរបស់សហគមន៍គួររួមបញ្ចូលមនុស្សគ្រប់រូបនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។ អ្នកសម្របសម្រួលគួរពិនិត្យតាមដាន និងសួរខ្លួនឯងថា៖

[16] គោលការណ៍ណែនាំថ្នាក់ជាតិ អំពីសហគមន៍ដឹកនាំអនុវត្តអនាម័យនៅកម្ពុជា ឆ្នាំ២០១៣

- តើជនពិការ និង មនុស្សចាស់ត្រូវបានដាក់បញ្ចូលនៅក្នុងការបង្កើតផែនការអនាម័យសហគមន៍ដែរឬទេ?
- តើសហគមន៍បានពិនិត្យរកមើលថាមាននរណាខ្លះដែលត្រូវការជំនួយក្នុងការសាងសង់បង្គន់អនាម័យ (ឧ. ជនមានកម្សោយផ្នែកកាយសម្បទា ការរៀនសូត្រ/សតិបញ្ញា ឬការមើលឃើញមនុស្សចាស់ ស្ត្រី ឬគ្រួសារមានយុវជនជាមេគ្រួសារ) ឬទេ? ហើយតើពួកគេបានប្រឹក្សាយោបល់ជាមួយមនុស្សទាំងនោះទាក់ទងនឹងជំនួយដែលពួកគេចង់បាន ឬទេ?

## ៣.៤ ការពិនិត្យតាមដានសកម្មភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល

សូមមើលសកម្មភាពទី១ស្តីពីគន្លឹះបែបអនុវត្តជាក់ស្តែង ដើម្បីធ្វើឲ្យប្រសើរឡើងនូវការចូលរួមរបស់ជនពិការ និងមនុស្សចាស់នៅក្នុងសកម្មភាពសហគមន៍។

គេអាចពង្រឹងសកម្មភាពពិនិត្យតាមដានតាមរយៈសកម្មភាពរបស់សហគមន៍ ដូចជាផែនការសកម្មភាព ការផ្តល់ដំបូន្មានបច្ចេកទេសអំពីការសាងសង់បង្គន់ និងការផ្សាភ្ជាប់ទៅនិងការគាំទ្រហិរញ្ញវត្ថុជាដើម។[17]សកម្មភាពទាំងនេះរួមមាន៖

- នៅពេលណាមានការធ្វើផែនការ ឬ វគ្គបណ្តុះបណ្តាលសម្រាប់សហគមន៍ ដែលពិនិត្យតាមដានដោយប្រធានភូមិ ជនបង្គោលភូមិ ជនបង្គោលឃុំ និងអ្នកសម្របសម្រួលសហគមន៍ដឹកនាំអនុវត្តអនាម័យ នោះអាចដាក់បញ្ចូលនូវការពិភាក្សា ថាតើអ្នកសម្របសម្រួលអាចនឹងមានសំណួរអំពីលទ្ធភាពទទួលបានសកម្មភាពអនាម័យរបស់គ្រួសារទាំងមូលរួមទាំងជនពិការ និង មនុស្សចាស់ផងដែរដោយរបៀបណា។
- បុគ្គលិកអាចនឹងត្រូវផ្តល់ការគាំទ្រអន្តរបុគ្គលដល់គ្រួសាដើម្បីធានាថាស្ត្រី បុរស កុមារា និងកុមារីពិការអាចចូលរួមយោបល់ទាក់ទងនឹងទីតាំង និងការរចនារបស់បង្គន់ (ឧ. ការដោះស្រាយ ឬការចរចារអំពីទំនាក់ទំនងអំណាចនៅក្នុងគ្រួសារ ដែលអាចនឹងមានគុណវិបត្តិចំពោះអ្នកប្រើប្រាស់ម្នាក់ទៀត)។
- ផ្តល់ព័ត៌មានអំពីប្រភេទបង្គន់ដែលអាចប្រើបាននៅក្នុងបរិបទមូលដ្ឋានដើម្បីធានាថាមនុស្សគ្រប់រូបអាចប្រើប្រាស់បង្គន់បានដោយត្រូវជម្រុញឲ្យជ្រើសយកជម្រើសដែលអាចផ្តល់លទ្ធភាពប្រើប្រាស់បានពេញមួយវដ្តជីវិតរបស់មនុស្ស ឧទាហរណ៍ ជម្រើសដែលបង្កឲ្យមានលក្ខណៈងាយស្រួលបំផុតសម្រាប់កុមារ មនុស្សចាស់ ជនពិការ និងស្ត្រីមានផ្ទៃពោះ។
- សម្ភារៈផ្តល់ព័ត៌មាន ការអប់រំ និង ការប្រាស្រ័យទាក់ទងដែលឆ្លើយតបនឹងបញ្ហាជាក់លាក់ ដែលជនពិការ និងមនុស្សចាស់ច្រើនជួបប្រទះនៅក្នុងបរិបទជាក់លាក់ណាមួយ មានសារៈប្រយោជន៍ណាស់ក្នុងការគាំទ្រដល់តម្រូវការជាក់ស្តែង។

### លទ្ធភាពទទួលបានជម្រើសផ្នែកបច្ចេកវិទ្យា និងសម្ភារៈអនាម័យ

- ដាក់បញ្ចូលអាជីវកម្មអនាម័យនៅក្នុងកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីពិការភាព និងលើកទឹកចិត្តដល់គោលការណ៍ប្លង់ការរចនាជាសកល ដែលសង្កត់ធ្ងន់លើអត្ថប្រយោជន៍និងការអាចប្រើប្រាស់បានសម្រាប់សហគមន៍ពេញមួយវដ្តជីវិតរបស់មនុស្ស។ ធានាថាកន្លែងផ្តល់សេវាទឹកស្អាត និងលើកកម្ពស់អនាម័យត្រូវបានសរសេរបញ្ចូលទៅក្នុងកិច្ចសន្យា និងអនុស្សារណៈយោគយល់គ្នាជាមួយដៃគូរចនា និងសាងសង់។

[17] Kar and Pasteur 2012

- បំផុសសកម្មភាពសហគមន៍តាមរយៈការផ្សព្វផ្សាយឲ្យមានការផ្តល់ជ័យលាភី និងការប្រកួតប្រជែង ដូចជារង្វាន់សម្រាប់គោលការណ៍ប្លង់រចនាជាសកល គឺមានន័យថាការរចនាបង្គន់ដែលផ្តល់លទ្ធភាពប្រើប្រាស់បានល្អបំផុត។
- ដាក់បញ្ចូលឧទាហរណ៍អំពីជនពិការ និងមនុស្សចាស់ទៅក្នុងប្រព័ន្ធផ្សព្វផ្សាយទាំងអស់សម្រាប់ការអនុវត្តអនាម័យ និង ការអនុវត្តសហគមន៍ដឹកនាំដែលមានភាពប្រសើរឡើងដើម្បីបង្ហាញនូវការរំពឹងទុកដែលមនុស្សគ្រប់រូបគួរតែចូលរួមនៅក្នុងដំណើរការនេះ។
- ធានាឲ្យមានការផ្សាភ្ជាប់ទៅនឹងសេវាផ្តោតលើពិការភាពជាក់លាក់ដែលអាចផ្តល់នូវការគាំទ្រ ឬ ព័ត៌មានវិទ្យាផ្តោតជាក់លាក់សម្រាប់ជនពិការ ឧ. ព័ត៌មានអំពីការចែកឧបករណ៍ជំនួយអនាម័យពេលមានរដូវ សម្រាប់ស្ត្រីដែលមានកម្សោយអវៈរយៈផ្នែករាងកាយ។

| |
|---|
| ការរចនាបច្ចេកទេសសម្រាប់បង្គន់អនាម័យ រួមទាំងការបញ្ជាក់មុខងារលម្អិត និងរូបគំនូរបង្គន់ទាំងនោះ មាននៅក្នុងសៀវភៅណែនាំរបស់អង្គការជនពិការអន្តរជាតិ ដែលបានសាកល្បងនៅក្នុងប្រទេសកម្ពុជា (អង្គការជនពិការអន្តរជាតិ ឆ្នាំ២០០៨)។ *របៀបបង្កើតឲ្យមានបរិស្ថានដែលបង្កលក្ខណៈងាយស្រួលនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ សៀវភៅណែនាំទី ២៖ ផ្នែកទី១ និងទី២។* |

## ៣.៥ ដំណើរការផ្ទៀងផ្ទាត់បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល

សូមមើលសកម្មភាពទី១ ស្តីពីវិធីសាស្ត្រអនុវត្តជាក់ស្តែងក្នុងការធ្វើឲ្យប្រសើរឡើងនូវការចូលរួមរបស់ជនពិការ និងមនុស្សចាស់ និងសកម្មភាពទី២ ប្រសិនបើអ្នកត្រូវការគំនិតបែបអនុវត្តជាក់ស្តែង អំពីរបៀបដើម្បីកំណត់រកពួកគេ។

នៅពេលវាយតម្លៃអំពីស្ថានភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ត្រូវពិនិត្យមើលថាតើជនពិការ និងមនុស្សចាស់មានលទ្ធភាពទទួលបានសេវាទឹកស្អាត និងអនាម័យគ្រប់គ្រាន់ឬទេ។ ធ្វើការសម្ភាសន៍ជាមួយមនុស្សចាស់ ស្ត្រី គ្រួសារក្រីក្របំផុត និងជនពិការអំពីបទពិសោធន៍របស់ពួកគេ ក្នុងការទទួលបានអនាម័យដែលជាការកំណត់រកវិធីល្អដើម្បីធ្វើឲ្យកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យកាន់តែមានលក្ខណៈរួមបញ្ចូល។

ធានាថាជនពិការ និងមនុស្សចាស់ត្រូវបានដាក់បញ្ចូលនៅក្នុងសកម្មភាពអបអរសាទរការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលដូចជាកម្មវិធីចែករំលែកនូវបទពិសោធន៍ និងសកម្មភាពសប្បាយៗផ្សេងៗ។ ការធ្វើបែបនេះគឺមានន័យថាជាទទួលស្គាល់ធាតុចូលពីមនុស្សគ្រប់រូបនៅក្នុងសហគមន៍ និង មធ្យោបាយផ្សេងៗដែលធ្វើឲ្យការងារនេះសម្រេចទៅបាន។

# ៤. ការធ្វើទីផ្សារអនាម័យ៖ វិធីសាស្ត្រដែលមានការដាក់បញ្ចូល

**បទដ្ឋានអប្បបរមា៖ការធ្វើទីផ្សារអនាម័យដែលបង្កលក្ខណៈងាយស្រួល**

១. ជនពិការនិងមនុស្សចាស់គួរត្រូវបានដាក់បញ្ចូលជាអ្នកចូលរួមនៅក្នុងកម្មវិធីលក់។

២. បុរសនិងស្ត្រីពិការព្រមទាំងមនុស្សចាស់ (និងស្ត្រីមានផ្ទៃពោះ) គួរត្រូវបានដាក់បង្ហាញនៅក្នុងសម្ភារៈផ្សព្វផ្សាយទាក់ទងនឹងអនាម័យដើម្បីតំណាងឱ្យភាពចម្រុះគ្នានៃមនុស្សនៅក្នុងសហគមន៍។

៣. គួរមានផលិតផលសម្ភារៈនិងសេវានានាទាក់ទងនឹងអនាម័យក្នុងតម្លៃសមរម្យសម្រាប់ជនពិការមនុស្សចាស់ និងស្ត្រីមានផ្ទៃពោះ។

៤. គួរមានបញ្ចូលការរចនាគំរូនៃផលិតផលអនាម័យ ដែលបង្កលក្ខណៈងាយស្រួលនៅក្នុងកម្មវិធីលក់ និង ធ្វើឱ្យមានលក់សម្រាប់អ្នកប្រើប្រាស់/សមាជិកសហគមន៍។

*"ការធ្វើទីផ្សារអនាម័យគឺជាការយកការអនុវត្តន៍ល្អបំផុតផ្នែកទីផ្សារសង្គម និងពាណិជ្ជកម្មទៅអនុវត្តដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត និងដើម្បីពង្រីកតម្រូវការ និងការផ្គត់ផ្គង់ផ្នែកអនាម័យដែលកាន់តែប្រសើរឡើង ជាពិសេសគឺនៅក្នុងគ្រួសារក្រីក្រ"*[18]។

នៅក្នុងប្រទេសកម្ពុជានៅមិនទាន់មានគោលការណ៍ណែនាំថ្នាក់ជាតិ ទាក់ទងនឹងទីផ្សារអនាម័យនៅឡើយទេ ហេតុដូច្នេះ ផ្នែកនេះនឹងណែនាំនៅក្នុងលក្ខខណ្ឌទូទៅ ច្រើនជាងវត្តស្តីពីសហគមន៍ដឹកនាំអនុវត្តអនាម័យ។ ជាងនេះទៀត មានឯកសារតិចតួចណាស់ដែលបានចងក្រងឡើងទៅលើបទពិសោធន៍នៅបណ្តាប្រទេសដទៃទៀត អំពីថាតើវិធីសាស្ត្របែបទីផ្សារអាចដំណើរការបានដោយរបៀបណាជាមួយជនពិការ និងមនុស្សចាស់។ ដោយហេតុនេះគួរចាត់ទុកផ្នែកនេះថាជាចំណុចចាប់ផ្តើមសម្រាប់ការបណ្តុះគំនិតនិងអនុវត្តសាកល្បងនៅក្នុងវិស័យនេះ ហើយគួរតែពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ខណៈដែលបានទទួលបទពិសោធន៍ថ្មីៗពីការអនុវត្ត។

## ៤.១ ការធ្វើការជាមួយអាជីវកម្មអនាម័យ និងភ្នាក់ងារលក់

ដើម្បីឲ្យអាជីវកម្មអនាម័យ និងភ្នាក់ងារលក់មានការចាប់អារម្មណ៍នៅក្នុងផ្នែកនេះ ពួកគេចាំបាច់ត្រូវជឿជាក់ថាពួកគេអាចលក់ទំនិញទៅឲ្យក្រុមគ្រួសារដែលមានសមាជិកជាជនពិការ និងមនុស្សចាស់។ ការងារនេះអាចធ្វើបានតាមរយៈ៖

- ជួយអាជីវកម្មឲ្យបានដឹងអំពីទំហំទីផ្សារក្នុងផ្នែកនេះ។ អង្គការជនពិការ និងអង្គការមនុស្សចាស់អាចពន្យល់ដល់អាជីវកម្មឲ្យដឹងអំពីចំនួនអតិថិជនជាសក្តានុពលដែលកំពុងរស់នៅក្នុងតំបន់ដែលពួកគេកំពុងធ្វើការ។ ព្រមជាមួយគ្នានេះសូមពន្យល់ផងដែរថានៅស្ទើរគ្រប់គ្រួសារទាំងអស់សុទ្ធតែមានមនុស្សចាស់ មានជនពិការ ឬស្ត្រីមានផ្ទៃពោះ។
- កំណត់រកអាជីវកម្មអនាម័យដែលអាចមានជនពិការនៅក្នុងក្រុមគ្រួសាររបស់ពួកគេ ឬដែលកំពុងថែទាំមនុស្សចាស់ រួចធ្វើការជាមួយពួកគេដើម្បីកំណត់រកដំណោះស្រាយ។

[18] WSP (2011) មគ្គុទេសន៍ណែនាំអំពីទីផ្សារអនាម័យ។ អាចរកមើលបាននៅ៖ http://www.wsp.org/sites/wsp.org/files/publications/WSP-Introductory-Guide-Sanitation-Marketing.pdf

## ៤.២ ការរៀបចំផែនការ និងយុទ្ធសាស្ត្រទីផ្សារ

**ការស្រាវជ្រាវស្ថានភាពមុនការអនុវត្តន៍គម្រោង**

ការសិក្សាស្រាវជ្រាវស្ថានភាពទីផ្សារមុនការអនុវត្តន៍គម្រោងអាចនឹងត្រូវបានរៀបចំឡើង ដើម្បីផ្តល់ព័ត៌មានសម្រាប់ការរៀបចំកម្មវិធីទីផ្សារអនាម័យ។ ត្រូវដាក់បញ្ចូលជនពិការ និងមនុស្សចាស់នៅក្នុងការសិក្សាស្រាវជ្រាវនេះ ហើយការដាក់បញ្ចូលនេះអាចធ្វើទៅបានតាមមធ្យោបាយដូចខាងក្រោម៖

- លើកឡើងអំពីជនពិការ និងមនុស្សចាស់នៅក្នុងសំណួរស្រាវជ្រាវ គោលបំណង និងក្របខណ្ឌការងាររបស់ការសិក្សាស្រាវជ្រាវ។
- ធានាថាក្រុមសិក្សាស្រាវជ្រាវយល់អំពីវិធីសាស្ត្រសិទ្ធិមនុស្សចំពោះពិការភាពនិងមនុស្សចាស់នៅក្នុងបរិបទការសិក្សាស្រាវជ្រាវ។ ពួកគេអាចនឹងត្រូវការការបណ្តុះបណ្តាលមួយចំនួន។
- គិតគូឲ្យមានជនពិការ និងមនុស្សចាស់នៅក្នុងក្រុមការងារសិក្សាស្រាវជ្រាវ ការធ្វើបែបនេះអាច ជួយបង្កើតភាពជាដៃគូល្អ និងអាចធ្វើឲ្យប្រសើរឡើងនូវការចូលរួមរបស់ជនពិការផងដែរ [19] សមាគមមនុស្សចាស់ក៏បានប្រមូលទិន្នន័យ និងព័ត៌មានអំពីមនុស្សចាស់នៅក្នុងភូមិរបស់ពួកគាត់ដែលអាចយកមកប្រើប្រាស់បានផងដែរ។
- ធានាថាការប្រើប្រាស់វិធីសាស្ត្រប្រតិបត្តិល្អក្នុងការកំណត់រក និងការដាក់បញ្ចូលជនពិការ និងមនុស្សចាស់នៅក្នុងការស្ទាបស្ទង់មតិក្រុមពិភាក្សា និងជាអ្នកផ្តល់ព័ត៌មានសំខាន់ជាដើម ត្រូវបានដាក់បញ្ចូលក្នុងការរៀបចំការសិក្សាស្រាវជ្រាវ។ សូមមើលសកម្មភាពទី២ ស្តីពីអនុសាសន៍មួយចំនួនអំពីរបៀបធ្វើសកម្មភាពនេះ។
- ជជីកសួរដោយសំណួរជាក់លាក់អំពីការអនុវត្តន៍ផ្នែកអនាម័យរបស់ជនពិការ និងមនុស្សចាស់។
- ស្វែងយល់ឲ្យដឹងថាតើជនពិការ និង មនុស្សចាស់ត្រូវបានគិតគូដោយអាជីវកម្មអនាម័យ និង អ្នកម៉ៅការសំណង់ ដែរឬទេ។
- កំណត់មើលថាតើស្តុកទំនិញរបស់អាជីវកម្មក្នុងមូលដ្ឋានមានប្រភេទបង្គន់ខុសៗគ្នា ឬ ក៏ម៉ូតកែច្នៃដែលអាចបង្កលក្ខណៈងាយស្រួលចំពោះជនពិការ មនុស្សចាស់ទន់ខ្សោយ ស្ត្រីមានផ្ទៃពោះជិតគ្រប់ខែ និងអ្នកជំងឺ/អ្នករបួសឬទេ។

សូមមើលសកម្មភាពទី១ សម្រាប់វិធីសាស្ត្រអនុវត្តជាក់ស្តែងក្នុងការដាក់បញ្ចូលអង្គការជនពិការ (DPOs) និងសមាគមមនុស្សចាស់ (OPAs) ជាអ្នកពាក់ព័ន្ធនៅពេលកំពុងរៀបចំការសិក្សាស្រាវជ្រាវ។

សូមមើលសកម្មភាពទី២ សម្រាប់គន្លឹះអនុវត្តជាក់ស្តែងអំពីរបៀបក្នុងការកំណត់រកជនពិការ និងមនុស្សចាស់ដើម្បីដាក់បញ្ចូលពួកគាត់ក្នុងការសិក្សាស្រាវជ្រាវស្ថានភាពគម្រោងមុនពេលអនុវត្តគម្រោង។

**ទីផ្សារចម្រុះ៖ ផលិតផល**

នៅក្នុងអំឡុងពេលដំណាក់កាលអភិវឌ្ឍន៍ផលិតផល៖

- ចូរចងចាំនូវគោលការណ៍រចនាជាសកល និងសូមចងចាំថា ការរចនាជាសាកលនេះមិនធ្វើឱ្យថ្លៃចំណាយកើនឡើងច្រើននោះឡើយ។ (សូមមើលទំព័រ២៣ ឬ ប្រអប់ទី២)

---

[19] ការសិក្សាស្រាវជ្រាវដទៃទៀតនៅក្នុងប្រទេសកម្ពុជាបានបង្ហាញថាជនពិការមានភាពកក់ក្តៅជាមួយអ្នកប្រមូលទិន្នន័យដែលជាជនពិការដែរ ហើយបានផ្តល់ព័ត៌មានយ៉ាងលម្អិត។ មានការរាយការណ៍ផងដែរថា ការមានជនពិការជាអ្នកប្រមូលទិន្នន័យ ក៏ធ្វើឲ្យមានលទ្ធផលជាវិជ្ជមានចំពោះឥរិយាបទរបស់សហគមន៍ចំពោះជនពិការផងដែរ។

- ពិចារណាជ្រើសយកការរចនាណាដែលមានភាពងាយស្រួលក្នុងការប្រើប្រាស់សម្រាប់មនុស្សច្រើនប្រភេទជាងគេបំផុត? តើអាចមានចន្លោះណាមួយដែលគេអាចសង់បង្គន់ដែលបង្កលក្ខណៈងាយស្រួល ហើយត្រូវចំណាយអស់ថ្លៃតិច ឬទេ?[20]
- ពិចារណាថាតើមានផ្នែកណាខ្លះដែលត្រូវបានកែតម្រូវដើម្បីបង្កឲ្យមានលក្ខណៈងាយស្រួល និងបានបន្ថែមទៅក្នុងបទដ្ឋានបង្គន់ដែរឬទេ។ ឧទាហរណ៍ ផ្នែកដែលត្រូវបានបន្ថែមមានដូចជា កម្រាលសញ្ញាជនពិការភ្នែក ឬខ្សែសម្រាប់នាំផ្លូវ បង្កាន់ដៃ តុល្យភាពនៃរបារ និងកន្លែងអង្គុយរបស់បង្គន់សង់ឡើងខ្ពស់ជាដើម។

សូមមើលសកម្មភាពទី១ សម្រាប់វិធីសាស្ត្រអនុវត្តជាក់ស្តែងក្នុងការធ្វើការជាមួយអង្គការជនពិការ (DPOs) និងសមាគមមនុស្សចាស់ (OPAs)ដើម្បីប្រមូលបទពិសោធន៍ក្នុងការកែសម្រួល ដែលធ្វើដោយជនពិការ និង មនុស្សចាស់ និង ពិចារណានូវរាល់ដំណើរការនៃការរចនាទាំងនេះ។

**ទីផ្សារចម្រុះ៖ តម្លៃ**

ត្រូវចាំថាពិការភាពមានទំនាក់ទំនងជាមួយនឹងភាពក្រីក្រ ដែលចំណុចនេះសំខាន់ណាស់ចំពោះការធ្វើឲ្យការបង្កលក្ខណៈងាយស្រួល ត្រូវតែមានតម្លៃសមរម្យ៖

- ធ្វើការជាមួយអង្គការជនពិការដើម្បីផ្សាភ្ជាប់ជនពិការជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ។ មានករណីជាច្រើនដែលជនពិការមិនអាចទទួលបានសេវាមីក្រូហិរញ្ញវត្ថុ បើធៀបនឹងជនមិនពិការ។
- លើកទឹកចិត្តស្ថាប័នមីក្រូហិរញ្ញវត្ថុឲ្យផ្តល់ឥណទានមានការប្រាក់ទាបដល់ជនពិការ និងមនុស្សចាស់
- ប្រឹក្សាយោបល់ជាមួយសមាគមមនុស្សចាស់ (OPAs) អំពីជម្រើសនានាសម្រាប់មនុស្សចាស់នៅក្នុងភូមិរបស់ពួកគាត់ ដើម្បីផ្តល់ហិរញ្ញវត្ថុសម្រាប់ទិញផលិតផលទឹកស្អាត និងលើកកម្ពស់អនាម័យ។
- ប្រសិនបើចាំបាច់ សូមពិចារណាលើវិធីការឧបត្ថម្ភទុនសម្រាបង្គន់មានតម្លៃថ្លៃ ឬ ឧករណ៍ជំនួយដូចជា បង្គន់អង្គុយសង់ខ្ពស់ឡើង តាមមធ្យោបាយទាំងឡាយណាដែលអាចជួយពង្រឹងទីផ្សារអនាម័យនៅមូលដ្ឋាន ឧទាហរណ៍ តាមរយៈការប្រើប្រាស់កម្មវិធីប័ណ្ណទឹកប្រាក់ជាដើម។

**ទីផ្សារចម្រុះ៖ ទីកន្លែង**

- ព្រឹត្តិការណ៍លក់គួរតែរៀបចំនៅកន្លែងដែលមានភាពងាយស្រួលសម្រាប់មនុស្សគ្រប់រូបអាចចូលរួមបាន
- អង្គការជនពិការនិងសមាគមមនុស្សចាស់ អាចសម្របសម្រួលជាមួយភ្នាក់ងារលក់ទំនិញផ្នែកអនាម័យដើម្បីធានាថាពួកគេអាចចុះដល់លំនៅដ្ឋានរបស់គ្រួសារជនពិការ និងមនុស្សចាស់ និង ចែករំលែកព័ត៌មានអំពីការរចនាដែលមានលក្ខណៈដាក់បញ្ចូល។
- អង្គការជនពិការអាចរៀបចំកុម្មង់ទិញទំនិញជាក្រុម ពីអាជីវកម្មអនាម័យសម្រាប់ជនពិការ និង មនុស្សចាស់នៅក្នុងតំបន់គោលដៅរបស់ពួកគេ។
- អង្គការជនពិការក៏អាចស្តុកទុកឧបករណ៍ជំនួយ ដើម្បីលក់ឲ្យសមាជិករបស់ពួកគេផងដែរ។

**ទីផ្សារចម្រុះ៖ ការផ្សព្វផ្សាយ**

- គួរមានការតំណាងឲ្យជនពិការ និងមនុស្សចាស់យ៉ាងសកម្មក្នុងនាមជាផ្នែកមួយនៃយុទ្ធនាការផ្សព្វផ្សាយ។ ការងារនេះអាចធ្វើឡើងបានតាមរយៈការបង្ហាញជនពិការ និងមនុស្សចាស់ និងមនុស្សជាច្រើនទៀតដែលប្រើ

[20] គេបានរកឃើញថាការបង្កឲ្យមានលក្ខណៈងាយស្រួលគឺមិនអស់ថ្លៃច្រើនឡើយ នៅពេលដែលការងារនេះ ត្រូវបានដាក់បញ្ចូល តាំងពីដំណាក់ដំបូង ដោយប្រើគោលការណ៍រចនាល្អ

ប្រាស់បង្គន់ដែលមានការបង្កលក្ខណៈងាយស្រួលក្នុងលក្ខណៈជាវិជ្ជមាននៅក្នុងយុទ្ធនាការផ្សព្វផ្សាយ និងការផ្តល់សារ។

- ដើម្បីជួយលើការងារនេះ ការផ្សព្វផ្សាយដែលមានការដាក់បញ្ចូលគួរតែរំលេចឡើងនៅក្នុងឧបករណ៍ទំនាក់ទំនងនៅពេលបង្កើតសម្ភារៈ។
- ការផ្សព្វផ្សាយគួរតែរៀបចំនៅក្នុងមធ្យោបាយផ្សេងៗគ្នាជាច្រើនដើម្បីកុំឲ្យជនពិការ មនុស្សចាស់ "ខកខានមិនបានទទួលសារ"។ គំរូពហុទំនាក់ទំនងក៏ជួយពង្រឹងលទ្ធភាពនៃការផ្តល់សារសម្រាប់មនុស្សគ្រប់រូបផងដែរ ព្រោះថាមនុស្សងាយទទួលយកសារទំនាក់ទំនងក្នុងទម្រង់នៃការទំនាក់ទំនងផ្សេងៗពីគ្នា។
- គេអាចបង្កើតភាពជាដៃគូសម្រាប់ការផ្សព្វផ្សាយផងដែរ ឧទាហរណ៍ អង្គការជនពិការ សមាគមមនុស្សចាស់ និងបណ្តាញកម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍ដែលបានដឹង និង មានទំនាក់ទំនងជាមួយជនពិការគ្រប់ប្រភេទ និងមនុស្សចាស់នៅកម្រិតសហគមន៍អាចជួយចែករំលែកសារអនាម័យ និងភ្ជាប់ទំនាក់ទំនងជនពិការ និងមនុស្សចាស់ជាមួយអ្នកផ្គត់ផ្គង់ផ្នែកអនាម័យ។
- សូមរំលេចនូវសារៈប្រយោជន៍នៃការរចនាដែលមានការដាក់បញ្ចូលភាពមិនទើសទែង មានភាពងាយស្រួលក្នុងការប្រើប្រាស់ និងគុណភាពរបស់បង្គន់ និង ពន្យល់ប្រាប់ឲ្យដឹងថាបង្គន់នេះអាចប្រើបានដោយមនុស្សគ្រប់រូបពេញមួយវដ្តជីវិត (ការប្រើប្រាស់បានកាន់តែច្រើនដោយជនពិការ មនុស្សចាស់ទន់ខ្សោយ ស្ត្រីមានផ្ទៃពោះជិតគ្រប់ខែ កុមារ និងអ្នកដែលមានជំងឺ ឬ របួសជាបណ្តោះអាសន្ន)។

## ៥. ទីកន្លែងលាងសម្អាតដៃដែលមានការបង្កលក្ខណៈងាយស្រួល

**បទដ្ឋានអប្បបរមា៖ គំនិតផ្តួចផ្តើមអំពីកន្លែងលាងសម្អាតដៃដែលមានបង្កលក្ខណៈងាយស្រួល**

១. ជនពិការ និងមនុស្សចាស់គួរតែចូលរួមនៅក្នុងការធ្វើផែនការ ការរចនា និងទីតាំងសម្រាប់សង់ហេដ្ឋារចនាសម្ព័ន្ធទីកន្លែងលាងសម្អាតដៃ រួមមានកន្លែងដាក់សាប៊ូលាងដៃផងដែរ។
២. ហេដ្ឋារចនាសម្ព័ន្ធលាងសម្អាតដៃគួរតែមានការបង្កលក្ខណៈងាយស្រួល និងត្រូវបានរចនាឡើងដោយផ្អែកលើគោលការណ៍រចនាជាសកល (សូមមើលទំព័រ២៣ឬប្រអប់ទី២) ដោយក្នុងនោះត្រូវ កែសម្រួលការរចនាម៉ូតដើម្បីអាចឲ្យជនពិការប្រើប្រាស់បាន។
៣. ដំណើរការការពិនិត្យតាមដានរួមបញ្ចូលនូវការត្រួតពិនិត្យ ថាតើមនុស្សចាស់ ឬជនពិការបានប្រើប្រាស់សេវាលាងសម្អាតដៃ និងទទួលបានព័ត៌មានអំពីការលាងសម្អាតដៃ ឬអត់។
៤. គួរចែករំលែកគំនិតបង្កើតថ្មីល្អៗស្តីពីទីកន្លែងលាងសម្អាតដៃដែលមានការបង្កលក្ខណៈងាយស្រួល នៅក្នុងគ្រប់វិស័យ។

វាជាការសំខាន់ណាស់ដែលការប្រឹងប្រែងធ្វើឲ្យមានការប្រសើរឡើងនូវការលាងសម្អាតដៃ បានទៅដល់សម្រាប់មនុស្សគ្រប់រូបនៅក្នុងគ្រួសារ និងសហគមន៍ រួមទាំងជនពិការ និង មនុស្សចាស់ផងដែរ។ វាជាការសំខាន់ផងដែរ ដែលសមាជិកគ្រួសារ និងអ្នកថែទាំជនពិការ និងមនុស្សចាស់ដែលជួយមើលថែទាំខ្លួននិងជួយអនុវត្តការងារប្រចាំថ្ងៃដទៃទៀតដល់ពួកគាត់ត្រូវអនុវត្តការលាងសម្អាតដៃនៅក្នុងពេលសំខាន់ៗ។

### ការរចនា និងទីតាំងសម្ភារៈលាងសម្អាតដៃដែលមានការបង្កលក្ខណៈងាយស្រួល

ផ្នែកនេះផ្តល់ជូននូវគន្លឹះអនុវត្តជាក់ស្តែងសម្រាប់ការរចនានិងទីតាំងរបស់កន្លែងសម្រាប់លាងសម្អាតដៃដែលបង្កឲ្យមានលក្ខណៈងាយស្រួល។

សូមមើលសកម្មភាពទី១ សម្រាប់ជំហានអនុវត្តជាក់ស្តែងក្នុងការធ្វើឲ្យប្រសើរឡើងនូវការចូលរួមរបស់ជនពិការ និងមនុស្សចាស់ក្នុងការរចនា និងទីតាំងរបស់កន្លែងសម្រាប់លាងសម្អាតដៃ។

នៅពេលដែលយើងធានាយ៉ាងណាឲ្យគ្រួសារមានទីកន្លែងប្រកបដោយភាពងាយស្រួល និង ទីតាំងសមស្របសម្រាប់ដាក់សម្ភារៈលាងសម្អាតដៃ ជាការសំខាន់ផងដែរដែលត្រូវគិតគូអំពីតម្រូវការរបស់សមាជិកគ្រួសារទាំងអស់គ្នារួមទាំងជនពិការ និងមនុស្សចាស់ផងដែរ។ ឧទាហរណ៍ មនុស្សចាស់ដែលមានសភាពទន់ខ្សោយ និងមានការលំបាកក្នុងការដើរ ច្រើនតែមិនសូវប្រើសាប៊ូ ប្រសិនបើដាក់សាប៊ូនោះនៅឆ្ងាយពីប្រភពទឹក។ មនុស្សចាស់ម្នាក់ដែលមានកម្សោយផ្នែកគំហើញត្រូវដឹងឲ្យច្បាស់អំពីទីតាំងដាក់សាប៊ូដើម្បីឲ្យគាត់អាចយកមកប្រើបាន។ គួរពិចារណាលើគ្រប់ទិដ្ឋភាពទាំងអស់នៃការរចនាចាប់តាំងពីទីតាំងនៃកន្លែងលាងសម្អាតដៃ ផ្លូវដើរទៅកាន់កន្លែងលាងសម្អាតដៃ និងទីកន្លែងរក្សាទុកសម្ភារៈប្រើប្រាស់។

តារាងនេះរៀបរាប់បង្ហាញអំពីរបាំងនានាដែលអាចកើតមាន និងដំណោះស្រាយសម្រាប់លទ្ធភាពចូលទៅកាន់ទីកន្លែងលាងសម្អាតដៃ។ កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យគួរប្រើប្រាស់ឧបករណ៍ការវិភាគរបាំងដោយបែបការចូលរួមដើម្បីរៀបចំកម្មវិធីលាងសម្អាតដៃ។ សូមមើលសកម្មភាពទី៣ សម្រាប់ជំហានអនុវត្តជាក់ស្តែងអំពីរបៀបវិភាគរបាំង។ ម្យ៉ាងវិញទៀត ការត្រួតពិនិត្យអំពីសុវត្ថិភាព និងការបង្កលក្ខណៈងាយស្រួលតាមបែបការចូលរួមគឺជាមធ្យោបាយដ៏ល្អមួយក្នុងការកំណត់របាំងផងដែរ។

## តារាងទី 2៖របាំង និងដំណោះស្រាយសម្រាប់ការលាងសម្អាតដៃ

| | របាំង | ដំណោះស្រាយ |
|---|---|---|
| **ទីតាំងកន្លែងលាងសម្អាតដៃ** *(តើអ្នកគ្រប់គ្នានៅក្នុងគ្រួសារអាចចូលទៅកន្លែងលាងសម្អាតដៃបានដែរឬទេ?)* | កន្លែងលាងសម្អាតដៃនៅឆ្ងាយពីបង្គន់ឬឆ្ងាយពីផ្ទះ<br><br>ផ្លូវទៅកាន់កន្លែងលាងសម្អាតដៃពិបាកដើរចូលទៅរក | ត្រូវដាក់កន្លែងលាងដៃនៅជិតបង្គន់ឬផ្ទះ<br><br>បំពាក់ជម្រាល និងផ្លូវបេតុងតាមផ្លូវដើម្បីងាយស្រួលដើរទៅកន្លែងលាងសម្អាតដៃ<br><br>បំពាក់ខ្សែនាំផ្លូវ បង្កាន់ដៃ ឬក្រម្រាលសញ្ញានាំផ្លូវដើម្បីងាយស្រួលដើរ។ |
| **ការរចនារបស់កន្លែងលាងសម្អាតដៃ** *(តើអ្នកគ្រប់គ្នានៅក្នុងគ្រួសារអាចប្រើប្រាស់សម្ភារៈលាងសម្អាតដៃដែរឬទេ?)* | បំពង់បង្ហូរទឹកបញ្ឈរខ្ពស់ពេក<br><br>មានការលំបាកឈោងដៃដល់ពាងទឹកដើម្បីដងទឹកយកមក | រចនាជំហរបំពង់បង្ហូរទឹកឲ្យនៅទាប<br><br>ពិចារណាឲ្យមានជម្រើសរចនាដូចជាបោយដែលមានដងវែង |
| **កន្លែងដាក់សាប៊ូដុំ** *(តើអ្នកគ្រប់គ្នានៅក្នុងគ្រួសារដឹងអំពីទីកន្លែងទុកសាប៊ូដុំ និងអាចប្រើវាបានដែរឬទេ?)* | ពិបាកឈោងយកសាប៊ូដុំនៅកន្លែងលាងសម្អាតដៃ<br><br>មិនដឹងទៅរកកសាប៊ូដុំនៅន្លែងណា (ហាង) ឬមិនអាចយកសាប៊ូដុំដោយខ្លួនឯងបាន | ធានាថាសាប៊ូដុំដាក់កន្លែងងាយស្រួលរកដាក់នៅកម្ពស់ដែលទាប និងដាក់នៅកន្លែងដដែលដូចរាល់ថ្ងៃ<br><br>ផ្សព្វផ្សាយចំណេះដឹងនៅពេលនិយាយជាមួយគ្រួសារឲ្យដឹងថាគ្រប់គ្នានៅក្នុងគ្រួសារចាំបាច់ត្រូវអាចយកសាប៊ូដុំមកប្រើ។ សមាជិក គ្រួសារមួយចំនួនអាចនឹងត្រូវទិញសាប៊ូឲ្យអ្នកផ្សេងទៀតប្រើ។ |

នៅក្នុងកម្រិតសហគមន៍ ហេដ្ឋារចនាសម្ព័ន្ធសម្រាប់លាងសម្អាតដៃមានដូចជា រ៉ូប៊ីណេបញ្ឈរ ខ្សែបាញ់ទឹក ពាងទឹកជាដើម គប្បីរចនាដើម្បីបង្កលក្ខណៈងាយស្រួលដល់មនុស្សមានកម្សោយអវៈយវៈគ្រប់ប្រភេទ ឬ អ្នកដែលអាចប្រើប្រាស់ដៃបានក្នុងកម្រិតកំណត់។ អ្នកសម្របសម្រួលសហគមន៍គួរលើកទឹកចិត្តសមាជិកសហគមន៍ឲ្យគិតគូរអំពីរូបរាងដែលបង្កឲ្យមានលក្ខណៈងាយស្រួល។ ពួកគេគួរទទួលបានវគ្គបណ្តុះបណ្តាលក្នុងការកែសម្រួលការរចនាបែបសាមញ្ញៗ ដើម្បីបង្កើតសម្ភារៈលាងសម្អាតដៃឲ្យកាន់តែមានលក្ខណៈងាយស្រួលដូចជា បន្ទាបកម្ពស់កន្លែងរ៉ូប៊ីណេលាងដៃបញ្ឈរ ដើម្បីងាយស្រួលដល់ជនពិការប្រើរទេះ បន្ថែមប្រវែងដងបោយដួសទឹកដើម្បីងាយស្រួលដងទឹកពីពាង។

**ការផ្សព្វផ្សាយអំពីការលាងសម្អាតដៃដែលមានការបង្កលក្ខណៈងាយស្រួល**

ទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្តចំពោះការលាងសម្អាតដៃនឹងសាប៊ូនៅក្នុងពេលវេលាសំខាន់ៗ ជារឿយៗត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ភាពយន្ត ក្រដាសផ្ទាំងធំ ផ្ទាំងរូបភាព និងសម្ភារៈដទៃទៀតក្នុងការផ្សព្វផ្សាយអំពីការលាងសម្អាតដៃ។ ឧបករណ៍ទាំងនេះអាចមានការលំបាកសម្រាប់មនុស្សចាស់ ឬ ជនពិការ ក្នុងការមើល អាន និងយល់។ ជាការសំខាន់ណាស់ក្នុងការផលិតសម្ភារៈក្នុងទម្រង់ផ្សេងៗគ្នា។ ឧទាហរណ៍ងាយៗមួយចំនួនមានដូចជា៖

- ប្រើពុម្ពអក្សរធំ និងរូបភាពធំៗនៅក្នុងយុទ្ធនាការ
- បង្កើតរូបភាពសញ្ញាដែលមនុស្សអាចស្ទាបអានដឹង ពុំត្រឹមតែមើលឃើញដោយភ្នែកទេ
- ប្រើប្រាស់មធ្យោបាយបែបមើលឃើញផង និងជាសម្លេងផង

ចំណុចទាំងនេះនឹងមានលម្អិតបន្ថែមទៀតនៅក្នុងវគ្គទំនាក់ទំនងដើម្បីការផ្លាស់ប្តូរនៅខាងក្រោម។

នេះគឺចាំបាច់ត្រូវដែលព្រឹត្តិការណ៍របស់សហគមន៍ត្រូវមានការដាក់បញ្ចូលជនពិការ និងមនុស្សចាស់។ សូមមើលសកម្មភាពទី២ សម្រាប់ព័ត៌មានគន្លឹះក្នុងការកំណត់រកជនពិការ ដើម្បីបង្កើនការចូលរួមនៅក្នុងព្រឹត្តិការណ៍របស់សហគមន៍។ កិច្ចសហប្រតិបត្តិការជាមួយអង្គការជនពិការ ឬកម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍ និងសមាគមមនុស្សចាស់ក្នុងការចូលរួមរៀបចំព្រឹត្តិការណ៍ដូចជា ទិវាលាងសម្អាតដៃសកលជាដើម គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការភ្ជាប់ទំនាក់ទំនងជាមួយជនពិការ និង មនុស្សចាស់ ហើយអាចទៅដល់ក្រុមដែលត្រូវគេមើលរំលងដទៃទៀត។

ប្រធានអង្គការជនពិការនិងសហព័ន្ធសមាគមមនុស្សចាស់ ក៏ជួយអប់រំផ្សព្វផ្សាយដល់សមាជិករបស់ខ្លួន និងសហគមន៍ទាំងមូលអំពីការអនុវត្តទឹកស្អាត និងលើកកម្ពស់អនាម័យ ជួយផ្សព្វផ្សាយចំណេះដឹង និងការផ្លាស់ប្តូរការប្រព្រឹត្តនៅក្នុងភូមិរបស់ពួកគាត់ផងដែរ។

នៅពេលប្រើប្រាស់វិធីសាស្ត្រផ្តោតការយកចិត្តទុកដាក់លើកុមារ មានដូចជាយុទ្ធនានៅការសាលារៀនជាដើម សូមចងចាំថាកុមារពិការប្រហែលជាមិនបានចូលរៀន និងមិនបានទទួលសារអំពីការលាងសម្អាតដៃដូចមិត្តភក្តិរបស់ពួកគេដែលបានចូលរៀនឡើយ។ សូមពិនិត្យមើលថាតើមានកន្លែងផ្តល់ការអប់រំបែបរួមបញ្ចូល ឬ សាលារៀនពិសេសដែលនៅជិតនោះឬទេ ហើយត្រូវអនុវត្តកម្មវិធីលាងសម្អាតដៃនៅទីនោះផងដែរ។

អ្នកផ្សព្វផ្សាយអំពីសុខភាពសហគមន៍ ដែលធ្វើការពិនិត្យតាមដានបន្តគួរធានាឲ្យបានថាពួកគេបាននិយាយជាមួយមនុស្សចាស់ និងជនពិការដើម្បីពិនិត្យមើលឲ្យដឹងថាតើពួកគេត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីលាងសម្អាតដៃឬទេ ហើយតើមានរបាំងអ្វីខ្លះដែលរារាំងពួកគេ ដែរឬទេ។

## ៦. ទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត (BCC)៖ វិធីសាស្រ្តដែលមានការដាក់បញ្ចូល

**បទដ្ឋានអប្បបរមា៖ លទ្ធភាពទទួលបានទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត**

១.សកម្មភាពផ្លាស់ប្តូរការប្រព្រឹត្តត្រូវរាប់បញ្ចូលជនគ្រប់រូប និងបង្កលក្ខណៈឱ្យមនុស្សគ្រប់រូបមានលទ្ធភាពទទួលបាននិងគប្បីប្រើប្រាស់គំរូនៃការប្រាស្រ័យទាក់ទងលើសពីមួយ (ឧទាហរណ៍ដូចជា រូបភាព និងការពណ៌នាផ្ទាល់មាត់ )

២. ជនពិការ និងមនុស្សចាស់គប្បីត្រូវបានបង្ហាញនៅក្នុងសម្ភារៈផ្សព្វផ្សាយទាក់ទងនឹងការអនុវត្តន៍អនាម័យប្រកបដោយភាពវិជ្ជមាន ដើម្បីបង្ហាញអំពីតម្លៃនៃការដាក់បញ្ចូល។

៣. វិធីសាស្រ្តទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្តដែលបង្កលក្ខណៈឱ្យគេអាចមានលទ្ធភាពទទួលបាន និងរាប់បញ្ចូលជនគ្រប់រូប គប្បីត្រូវបានចែករំលែកនៅក្នុងវិស័យការអនុវត្តន៍ទឹកស្អាត និងលើកកម្ពស់អនាម័យ (WASH) ទាំងមូល។

៤. ជនពិការនិងមនុស្សចាស់គប្បីត្រូវបានដាក់បញ្ចូលទៅក្នុងការកំណត់វិសាលភាពនៃការអនុវត្តន៍អនាម័យនិងការប៉ាន់ប្រមាណ។ សកម្មភាពនេះរាប់បញ្ចូលអនាម័យរបស់ស្រ្តី និងកុមារីពិការនៅពេលមានរដូវផងដែរ។

គោលការណ៍ណែនាំថ្នាក់ជាតិរបស់ប្រទេសកម្ពុជាស្តីពីទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្តសំរាប់អនាម័យនៅជនបទក្នុងប្រទេសកម្ពុជា (ក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ២០១៥) បានផ្តោតលើការប្រព្រឹត្តសំខាន់ៗចំនួន៣ ជាអាទិ៍៖

១. គ្រួសារនៅជនបទ**ទទួលយកបង្គន់សម្រាប់គ្រួសារ**
២. **ការលាងសម្អាតដៃនឹងសាប៊ូនៅពេលសំខាន់ៗ** (មុនរៀបចំអាហារ មុនពេលចម្អិនអាហារ មុនទទួលទានក្រោយបន្ទោរបង់ និងក្រោយលាងគូថឲ្យទារក) ដោយគ្រួសារនៅជនបទ ជាពិសេសអ្នកថែទាំកុមារក្រោមអាយុ៥ឆ្នាំ និង
៣. **ការប្រើប្រាស់ទឹកនៅតាមគ្រួសារ**ដោយគ្រួសារនៅជនបទ**ប្រកបដោយសុវត្ថិភាព និងជាប់លាប់**

ផ្នែកនេះផ្តល់ព័ត៌មានគន្លឹះសម្រាប់ការដាក់បញ្ចូលជនពិការ និងមនុស្សចាស់ទៅក្នុងទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្តដែលអាចប្រើប្រាស់បាននៅក្នុងផ្នែកទាំងបីនេះនៃការផ្លាស់ប្តូរការប្រព្រឹត្ត។

កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ គប្បីពិចារណាអំពីសេចក្តីត្រូវការទំនាក់ទំនងរបស់មនុស្សចាស់ និងជនពិការ។ ឧទាហរណ៍ មនុស្សចាស់ម្នាក់អាចទទួលព័ត៌មានក្នុងល្បឿនមួយដ៏យឺត មានការចងចាំខ្សោយ (សមត្ថភាពក្នុងការទទួលព័ត៌មានជាច្រើន ផ្សេងៗគ្នាក្នុងរយៈពេលណាមួយ) និង មានការលំបាកក្នុងការយល់អំពីសារមួយចំនួន។

កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ គប្បីចាត់វិធានការដើម្បីធានាថា៖

- កិច្ចប្រជុំអំពីទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត គប្បីធ្វើឡើងនៅក្បែរកន្លែងដែលជនពិការ ឬ មនុស្សចាស់រស់នៅ។
- ជនពិការ និងមនុស្សចាស់ទទួលបានទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្តព្រមជាមួយនឹងសមាជិកសហគមន៍ទាំងអស់។
- ជនពិការ និង មនុស្សចាស់ ត្រូវបានយកមកបង្ហាញជារូបភាពវិជ្ជមាននៅក្នុងសម្ភារៈផ្សព្វផ្សាយទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត។
- ក្នុងករណីដែលអាចធ្វើទៅបាន គប្បីប្រើប្រាស់ភាពជាតំណាងរបស់មនុស្សចាស់ និងជនពិការឱ្យបានសមស្រប ដើម្បីជួយដល់ការប្រាស្រ័យទាក់ទងសារឱ្យមានភាពសមស្រប និង គួរឱ្យជឿទុកចិត្តបានសម្រាប់ក្រុម

គោលដៅ។ ឧទាហរណ៍ ប្រធានសមាគមមនុស្សចាស់ និងសហព័ន្ធសមាគមមនុស្សចាស់ អប់រំផ្សព្វផ្សាយសមាជិក និងសហគមន៍របស់ពួកគាត់អំពីការអនុវត្តទឹកស្អាត និងលើកកម្ពស់អនាម័យ និង ជួយផ្សព្វផ្សាយចំណេះដឹង និងផ្លាស់ប្តូរការប្រព្រឹត្តនៅក្នុងភូមិរបស់ពួកគាត់។

សូមមើលសកម្មភាពទី១ សម្រាប់វិធីសាស្រ្តអនុវត្តជាក់ស្តែងក្នុងការធ្វើឲ្យប្រសើរឡើងនូវការចូលរួមរបស់ជនពិការ និងមនុស្សចាស់។ បន្ថែមពីនេះទៀត សូមមើលសកម្មភាពទី២ផងដែរ សម្រាប់ជំហានអនុវត្តជាក់ស្តែងក្នុងការកំណត់រកជនពិការ និងមនុស្សចាស់ នៅពេលចាប់ផ្តើមដំបូងនៃការធ្វើយុទ្ធនាការការផ្លាស់ប្តូរការប្រព្រឹត្តរបស់អ្នក។

## ៦.១ ព័ត៌មានដែលអាចទទួលបាន

មនុស្សចាស់អាចរៀនសូត្រព័ត៌មានថ្មីៗក្នុងល្បឿនមួយដ៏យឺត។ បន្ថែមពីនេះទៀត ប្រតិកម្ម និងពេលវេលាឆ្លើយតបរបស់ពួកគេមានការកើនឡើងគួរឱ្យកត់សម្គាល់នៅពេលពួកគេមានអាយុលើសពី៦៥ឆ្នាំ។ ការបង្ខំមនុស្សចាស់ឲ្យរៀនសូត្រ ឬ បង្ហាញជំនាញថ្មីអាចធ្វើឲ្យពួកគេមានការថប់បារម្ភ និងបដិសេធចំពោះការសាកល្បងដោយសារតែខ្លាចបរាជ័យ និងខ្មាសអៀន។ ការបង្រៀន/ការប្រាស្រ័យទាក់ទងគប្បីធ្វើដោយសន្សឹមៗ និងដោយប្រុងប្រយ័ត្នច្បាស់លាស់។ ជនដែលមានបញ្ហាកម្សោយអវៈយវៈខុសៗគ្នា អាចត្រូវការទទួលព័ត៌មាននៅក្នុងទម្រង់ផ្សេងៗគ្នា។

### ការសម្របសម្រួលសហគមន៍ និងវគ្គបង្រៀនអំពីការផ្លាស់ប្តូរការប្រព្រឹត្តមួយទល់នឹងមួយ

អ្នកសម្របសម្រួលគួរពិចារណារកថ្ងៃដែលមានពេលវេលាសមរម្យបំផុតសម្រាប់ការប្រាស្រ័យទាក់ទងគ្នា៖

- ពេលពាក់កណ្តាលព្រឹករមែងតែងត្រូវបានចាត់ទុកថាជាពេលវេលាល្អបំផុតសម្រាប់មនុស្សចាស់រៀនសូត្រ ដោយសារតែថាមពលរបស់ពួកគាត់នៅមានកម្រិតខ្ពស់នៅឡើយ
- សូមណែនាំឱ្យចែកឯកសារជូនពួកគាត់ អាស្រ័យដោយឯកសារទាំងនេះអាចពង្រឹងបន្ថែមទៅលើសារដែលបានផ្តល់ជូន និង ជួយឱ្យពួកគាត់ចងចាំឡើងវិញនៅពេលដែលមានការភ្លេចភ្លាំងរយៈពេលខ្លី។ឯកសារទាំងនេះគប្បីមានលក្ខណៈដូចខាងក្រោម៖
  - ងាយអាន
  - អក្សរធំៗ
  - មានភាពជិតច្បាស់រវាងក្រដាស និងអត្ថបទ
  - បោះពុម្ពនៅលើក្រដាសដែលមិនភ្លឺចាំង/រលោង

ប្រសិនបើសារមួយត្រូវបានផ្តល់ជូនលឿនពេក វាអាចមានការលំបាកសម្រាប់អ្នកដែលមានការលំបាកក្នុងការស្តាប់ ឬ មើល ឬលំបាកក្នុងការរៀនសូត្រ។ វិធីសាស្រ្តមួយចំនួនរួមមាន៖

- និយាយយឺតៗដើម្បីឲ្យអ្នកស្តាប់អាចចាប់បាននូវសារដែលកំពុងផ្តល់ឲ្យ ដកឃ្លានៅចន្លោះពេលកំពុងផ្តល់សេចក្តីណែនាំ ទុកពេលដើម្បីឱ្យស្វែងយល់ និងឆ្លើយតបចំពោះព័ត៌មានដែលបានផ្តល់ជូន។
- អ្នកដែលស្តាប់មិនសូវឮមានការប្រឈម ឬ បាត់បង់ប្រយោជន៍កាន់តែខ្លាំងប្រសិនបើសេចក្តីប្រកាសមិនសូវឮ ឬប្រសិនបើសម្លេងខ្ពស់ ឬទាបពេក។
- ជៀសវាងប្រើប្រាស់គោលគំនិតមិនច្បាស់លាស់ (ដូចជា គ្រប់គ្រាន់ ច្រើន ជាញឹកញាប់ ជារឿយៗ)។ ដោយឡែក នៅពេលប្រាស្រ័យទាក់ទងជាមួយមនុស្សចាស់ទាំងស្ត្រី និងបុរស ត្រូវបញ្ជាក់ឱ្យបានជាក់លាក់អំពីលំដាប់លំដោយ ពេលវេលា រយៈពេល និងភាពញឹកញាប់។

មនុស្សចាស់អាចមានការលំបាកក្នុងការធ្វើការងារច្រើនយ៉ាងក្នុងពេលតែមួយ។ ការផ្តល់ព័ត៌មានថ្មីៗជាច្រើនក្នុងពេលតែមួយ អាចនាំឱ្យបាត់បង់ប្រយោជន៍ទៅវិញ៖

- បរិមាណនៃព័ត៌មានថ្មីៗ គប្បីកម្រិតត្រឹម៣ទៅ៥ចំណុច និងផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់ដើម្បីឱ្យព័ត៌មានទាំងនោះ "ជ្រាបចូល" ទៅក្នុងខ្លួនពួកគាត់។
- ការផ្តល់ព័ត៌មានឡើងវិញដដែលៗ អាចជួយបំពេញការភ្លេចភ្លាំងរយៈពេលខ្លីមួយចំនួនបាន។

<u>ការមើល</u>

- ពន្លឺគឺចាំបាច់ណាស់សម្រាប់ការមើល ប៉ុន្តែត្រូវចៀសវាងកុំប្រើពន្លឺខ្លាំងពេក ពន្លឺព្រះអាទិត្យដោយផ្ទាល់ និងក្រដាសដែលមានចំណាំង ព្រោះភ្នែកមនុស្សចាស់គឺងាយរំញោចជាមួយចំណាំងពន្លឺ។
- មនុស្សចាស់មានការលំបាកក្នុងការសម្គាល់ភាពខុសគ្នារវាងពណ៌បៃតង ពណ៌ខៀវ និង ពណ៌ស្វាយចាស់ ហេតុនេះ គួរចៀសវាងកុំប្រើពណ៌ទាំងនេះ។

<u>ការស្តាប់</u>

- សម្លេងមនុស្សប្រុស ឬ សម្លេងធំគ្រលរ គឺងាយស្រួលស្តាប់សម្រាប់មនុស្សចាស់ជាង បើប្រៀបធៀបជាមួយសម្លេងស្រួយ (ជាញឹកញាប់គឺសម្លេងរបស់មនុស្សស្រី)[21]។
- ត្រូវចៀសវាងកុំឲ្យមានសម្លេងរំខានក្នុងបរិយាកាសជុំវិញ
- អ្នកនិយាយគួរតែនិយាយនៅខាងមុខអ្នកចូលរួម និង និយាយឲ្យបានច្បាស់ៗ ហើយកុំយកដៃខ្ទប់មាត់ ពេលអ្នកកំពុងនិយាយ។

**ការប្រើប្រាស់រូបភាព**

- អ្នកអាចគូសសម្គាល់រូបភាព ឬលើករូបភាពឡើងដោយប្រើប្រាស់ខ្សែបិទការភ្ជាប់ទៅនឹងគ្រោងមេរៀន ដើម្បីឲ្យអ្នកមានកម្សោយគំហើញ អាចកំណត់រូបភាពដោយខ្លួនឯងបាន។
- គួរនិយាយជាពាក្យសាមញ្ញដើម្បីអធិប្បាយអំពីរូបភាព។ បានន័យថាពេលលើករូបភាពបង្ហាញទៅក្រុម អ្នកសម្របសម្រួលត្រូវនិយាយឈ្មោះរូបភាពទាំងនោះចេញមកជាពាក្យសម្តីៗ ដើម្បីឲ្យអ្នកដែលមានកម្សោយគំហើញបានដឹងអំពីរូបភាពនីមួយៗ ព្រមពេលជាមួយអ្នកដទៃទៀតដែរ។ ត្រូវធ្វើយ៉ាងណាត្រូវលើកទឹកចិត្តឲ្យអ្នកចូលរួមដទៃធ្វើដូច្នេះដែរ រួមទាំងនៅពេលពួកគេធ្វើសកម្មភាពជាក្រុមតូចៗផងដែរ។ ឧទាហរណ៍ ពេលអ្នកធ្វើអ្វីមួយត្រូវរៀបរាប់អំពីអ្វីដែលអ្នកកំពុងធ្វើដោយការនិយាយចេញមក... *"ខ្ញុំកំពុងរើសរូបភាពបង្គន់"*។

**ទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្តដោយប្រើប្រាស់រូបភាពតំណាងឲ្យមនុស្សចាស់ និងជនពិការក្នុងលក្ខណៈវិជ្ជមាន**

ត្រូវប្រើប្រាស់រូបភាពតំណាងឲ្យមនុស្សចាស់ក្នុងលក្ខណៈវិជ្ជមាន ហើយត្រូវចៀសវាងកុំប្រើរូបភាពត្លុកមានផ្នត់គំនិតអវិជ្ជមាន។នៅកន្លែងណាដែលមានរូបភាពបង្ហាញអំពីជីវិត និងសកម្មភាពរបស់ក្រុមគ្រួសារ ត្រូវធានាថាមានរូបភាពតំណាងឲ្យជនពិការ (បុរស ស្ត្រី កុមារា និងកុមារី) និងមនុស្សចាស់ត្រូវបានបង្ហាញនៅក្នុងរូបភាពផងដែរ។

ការធ្វើបែបនេះ មានន័យថាជាការប្រើប្រាស់រូបភាពជនពិការដែលប្រើរទេះរុញ ឬជនពិការដែលប្រើប្រាស់ដំបងវាវផ្លូវ ជនពិការដែលប្រើឈើច្រត់ ជនពិការដែលមានជើងម្ខាង ជនពិការដែលប្រើភាសាសញ្ញា ជនពិការដែលត្រូវការ

---

[21] ចំណុចនេះមិនពាក់ព័ន្ធជាមួយការនិយាយខ្លាំងៗនោះទេ ប៉ុន្តែ គឺពាក់ព័ន្ធជាមួយប្រភេទសម្លេង។ ដូច្នេះ គួរជៀសវាងកុំស្រែកខ្លាំងៗដាក់ពួកគាត់ ព្រោះអាចធ្វើឲ្យមានការបកស្រាយថាជាការប្រមាថ។

ជំនួយក្នុងការរៀន។ល។ ឧទាហរណ៍ ដាក់បញ្ចូលជនពិការ ឬមនុស្សចាស់ដែលត្រូវពឹងផ្អែកលើអ្នកជួយពេលទៅបង្គន់ និងដាក់បញ្ចូលជនពិការ និងមនុស្សចាស់ជាផ្នែកមួយនៃរូបភាពបង្ហាញអំពីគ្រួសារ និងសហគមន៍។

## ៧. ការផ្គត់ផ្គង់ទឹកស្អាត៖ វិធីសាស្ត្រដែលមានការដាក់បញ្ចូល

**បទដ្ឋានអប្បបរមា៖ ការផ្គត់ផ្គង់ទឹកស្អាតដែលមានការបង្កលក្ខណៈងាយស្រួល**

១. គួរស្វែងយល់អំពីតម្រូវការទឹកស្អាតរបស់ជនពិការ មនុស្សចាស់ និងអ្នកថែទាំរបស់ពួកគេ នៅក្នុងដំណាក់កាលនៃការធ្វើផែនការ ព្រោះថាតម្រូវការរបស់ពួកគេអាចមានភាពខុសប្លែកគ្នាពីសមាជិកដទៃទៀតក្នុងសហគមន៍។

២. ជនពិការ មនុស្សចាស់ និងអ្នកថែទាំពួកគេ គួរមានឱកាសជាផ្លូវការដើម្បីចូលរួមគំនិតយោបល់របស់ខ្លួន នៅក្នុងការធ្វើផែនការ និងអភិបាលកិច្ចប្រព័ន្ធទឹកស្អាត ព្រមទាំងត្រូវធ្វើឡើងស្របពេលជាមួយមនុស្សដទៃទៀតនៅក្នុងសហគមន៍របស់ពួកគេ ដោយត្រូវទទួលស្គាល់ថាជនពិការ មនុស្សចាស់ និងអ្នកថែទាំភាគច្រើនត្រូវការទឹកស្អាតច្រើនជាងមនុស្សទូទៅ ប៉ុន្តែពួកគាត់ច្រើនតែទទួលសេវាទឹកស្អាតតិចជាងគេ។

៣. ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតគួរតែបង្កឲ្យមានលក្ខណៈងាយស្រួល និងប្រើប្រាស់គោលការណ៍រចនាជាសកល (សូមមើលប្រអប់ខាងលើក្នុងផ្នែកទី២)។ គួរកែសម្រួលការរចនាឲ្យបានសមស្របតាមការចាំបាច់ ដើម្បីឲ្យមានការបង្កលក្ខណៈងាយស្រួល និងលទ្ធភាពទទួលទឹកស្អាតប្រើប្រាស់។ ត្រូវមានការពិនិត្យតាមដានលើចំណុចផ្គត់ផ្គង់ទឹកស្អាតសហគមន៍ ដើម្បីធានាបានថាហេដ្ឋារចនាសម្ព័ន្ធទាំងនោះឆ្លើយតបតាមបទដ្ឋានប្លង់រចនាជាសាកល។ ដើម្បីអាចធ្វើការងារនេះ ប្រហែលជាចាំបាច់ត្រូវការឲ្យមានការបណ្តុះបណ្តាលដល់អ្នកម៉ៅការសំណង់ ឬ អ្នកទទួលខុសត្រូវក្នុងការសាងសង់។

ផ្នែកនេះនឹងបង្ហាញជូនអំពីរបៀបធ្វើយ៉ាងណាឲ្យកម្មវិធីផ្គត់ផ្គង់ទឹកស្អាតអាចដាក់បញ្ចូលជនពិការ និងមនុស្សចាស់ ដើម្បីធ្វើឲ្យពួកគាត់មានលទ្ធភាពទទួលបានទឹកស្អាតកាន់តែច្រើន ដូចមនុស្សដទៃទៀតនៅក្នុងសហគមន៍របស់ខ្លួនដែរ។ ផ្នែកនេះនឹងពិនិត្យលើទិដ្ឋភាពសំខាន់ៗបីនៃការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត៖

- ការវាយតម្លៃលើរបាំងនានាសម្រាប់ការទទួលបានការផ្គត់ផ្គង់ទឹកស្អាត
- ការចូលរួមរបស់ជនពិការ និងមនុស្សចាស់នៅក្នុងដំណើរការរចនា
- ការរចនាហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតដែលបង្កឲ្យមានលក្ខណៈងាយស្រួល

### វិសាលភាព និងការវិភាគរបាំងនានាសម្រាប់ការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត

ជំហានដំបូងដ៏សំខាន់ (ដូចបានបង្ហាញនៅក្នុងសកម្មភាពទី៣) គឺត្រូវប្រមូលព័ត៌មានអំពីរបាំងនានាក្នុងការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតដែលស្ត្រី និងបុរសពិការ ព្រមទាំងមនុស្សចាស់ត្រូវជួបប្រទះ។

ប្រភពផ្គត់ផ្គង់ទឹកស្អាត អាចបង្កការលំបាកសម្រាប់ជនពិការ និងមនុស្សចាស់ក្នុងការទទួលបានទឹកស្អាត។ ហេតុដូច្នេះ ជាការសំខាន់ណាស់ដែលត្រូវរចនា ការអនុវត្តន៍ និងពិនិត្យតាមដានសេវាផ្គត់ផ្គង់ទឹកស្អាត ដើម្បីដោះស្រាយរបាំងនានាដែលរារាំងនូវការទទួលបានសេវានេះ។ ឧទាហរណ៍មួយចំនួនអំពីរបាំងមានដូចជា៖

- ប្រភពផ្គត់ផ្គង់ទឹកនៅឆ្ងាយ ធ្វើឲ្យមនុស្សចាស់ដែលមានភាពទន់ខ្សោយមិនអាចដើរទៅដល់កន្លែងនោះបាន ហេតុនេះ ពួកគាត់ត្រូវពឹងផ្អែកលើសមាជិកគ្រួសារដើម្បីដងទឹកឲ្យពួកគាត់។
- ពួកគាត់អាចមានការលំបាកក្នុងការប្រើអណ្តូងស្នប់ដោយសារពួកគាត់ពិបាកប្រើដៃ ឬមានកម្លាំងដៃខ្សោយ។
- ការឱនដងទឹកនៅឯប្រភពទឹកអាចជាការលំបាកសម្រាប់អ្នកដែលមានការលំបាកក្នុងការបម្លាស់ទី (និងស្ត្រីមានផ្ទៃពោះ)។
- ការដឹកជញ្ជូនទឹកយកមកផ្ទះវិញអាចជាការលំបាកសម្រាប់មនុស្សចាស់ដែលមានភាពទន់ខ្សោយ។
- ជនពិការមិនត្រូវបានអនុញ្ញាតិឲ្យទៅដងទឹកអាស្រ័យដោយមានការរើសអើង។
- ខ្វះការប្រឹក្សាយោបល់ជាមួយជនពិការនៅក្នុងដំណើរការរចនា។

វិធីសាស្ត្រមួយដើម្បីលប់បំបាត់របាំងទាំងនេះ គឺការប្រើប្រាស់ឧបករណ៍វិភាគរបាំងបែបការចូលរួម (សូមមើលនៅក្នុងសកម្មភាពទី៣) ដើម្បីប្រមូលព័ត៌មានអំពីរបាំង និង ដំណោះស្រាយចំពោះការទទួលបានទឹកស្អាតជាមួយសមាជិកសហគមន៍។

នៅពេលកម្មវិធីបានប្រមូលព័ត៌មានទាំងនេះរួចហើយ កម្មវិធីអាចប្រើប្រាស់ព័ត៌មាននេះដើម្បីរចនាកម្មវិធី និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឲ្យកាន់តែមានលក្ខណៈងាយស្រួល។

**ការចូលរួមនៅក្នុងដំណើរការរចនា**

ដូចបានបញ្ជាក់នៅក្នុងសកម្មភាពទី១ រួចហើយថា ចាំបាច់ត្រូវមានជំហានបន្ថែមដើម្បីធានាឲ្យបានថាជនពិការ និងមនុស្សចាស់ត្រូវបានដាក់បញ្ចូលនៅក្នុងដំណើរការនៃការសម្រេចចិត្ត ជាពិសេសគឺនៅក្នុងការប្រជុំសហគមន៍។ ឧទាហរណ៍ សមាជិកសហគមន៍ម្នាក់ដែលមានពិការភាពផ្នែកកាយសម្បទា ប្រហែលជាមិនអាចមកចូលរួមកម្មវិធីប្រជុំធ្វើផែនការសហគមន៍បានទេ ដោយសារតែទីកន្លែងប្រជុំនៅឆ្ងាយ ឬ កន្លែងនោះមិនបានបង្កលក្ខណៈងាយស្រួលសម្រាប់គាត់អាចទៅចូលរួមបាន។

ចាប់តាំងពីពេលដំបូងនៃការរៀបចំផែនការដើម្បីប្រជុំ និងប្រឹក្សាយោបល់ជាមួយសហគមន៍ត្រូវ៖

- កំណត់រកជនពិការតាមរយៈការសាកសួរទៅអង្គការជនពិការនៅមូលដ្ឋាន និងអ្នកដឹកនាំសហគមន៍ (សូមមើលសកម្មភាពទី ១ និងទី ២) និង កំណត់រកមនុស្សចាស់តាមរយៈការសាកសួរទៅសមាគមមនុស្សចាស់នៅមូលដ្ឋាន។
- អញ្ជើញមនុស្សចាស់ និងជនពិការមកចូលរួមកិច្ចប្រជុំសហគមន៍។ ដើម្បីអាចអញ្ជើញពួកគាត់បាន ប្រហែលជាត្រូវឲ្យមានការជួយជ្រោមជ្រែងពីបណ្តាញអង្គការជនពិការ និងសមាគមមនុស្សចាស់ ព្រមទាំងអ្នកដឹកនាំសហគមន៍ ដើម្បីអាចធានាបានថាពួកគេទទួលបានព័ត៌មានអំពីការប្រជុំ។
- ក្នុងពេលប្រជុំធ្វើផែនការ ត្រូវធានាយ៉ាងណាឲ្យមនុស្សមកពីក្រុមផ្សេងៗគ្នាអាចបញ្ចេញយោបល់ និង ទទួលបានការស្តាប់យោបល់ (ឧ. ស្ត្រី និងបុរសគ្រប់វ័យ ស្ត្រីពិការ)។
- ព្រះសង្ឃ និងអ្នកដឹកនាំសាសនាដទៃទៀត អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការរចនាដំណើរការ និងផ្សព្វផ្សាយការយល់ដឹងស្តីពីពិការភាព។

**ការរចនាដែលបង្កលក្ខណៈងាយស្រួល**

ជនពិការនិងមនុស្សចាស់ផ្ទាល់ គឺជាបុគ្គលសក្តិសមបំផុតក្នុងការផ្តល់ដំបូន្មានលើការរចនាដែលបង្កលក្ខណៈងាយស្រួល។ ខាងក្រោមនេះគឺជាការណែនាំមួយចំនួនទាក់ទងនឹងចំណុចនេះ ប៉ុន្តែ សូមមើលនៅក្នុងសកម្មភាពទី៣ បន្ថែមទៀតទាក់ទងនឹងវិធីសាស្ត្របែបអនុវត្តជាក់ស្តែងក្នុងការវិភាគរករបាំង។ រាល់កម្មវិធីផ្គត់ផ្គង់ទឹកស្អាតគួររៀបចំការប្រឹក្សាយោបល់មុននឹងធ្វើការរចនា ដើម្បីធានាឲ្យការរចនាដែលធ្វើឡើងមកនោះមានលក្ខណៈបង្កភាពងាយស្រួល (សូមមើលសកម្មភាពទី១ ទី២ និងទី៣)។

**បែបផែននៃការដាក់ និងទីតាំង៖** របាំងជារួមមួយសម្រាប់ជនពិការ និងមនុស្សចាស់គឺប្រភពទឹកនៅឆ្ងាយពេក ឬ ប្រភពទឹកនៅកន្លែងពិបាកចូលទៅដល់ (ឧ. ផ្លូវរអិល)។ បែបផែននៃការដាក់តាំង និងទីតាំងរបស់ប្រភពទឹកថ្មីត្រូវតែគិតគូអំពីលទ្ធភាពងាយស្រួលចេញចូលសម្រាប់ជនពិការ និងមនុស្សចាស់ដូចជាចម្ងាយពីផ្ទះ ផ្លូវចេញចូលទំហំ និងសុវត្ថិភាព និងមានខ្សែនាំផ្លូវជាដើម។

**ការរចនាផ្នែកបច្ចេកទេសរបស់ប្រភពទឹក៖** ការផ្លាស់ប្តូរសាមញ្ញៗទៅលើការរចនារបស់ប្រភពទឹក (ដៃស្ទប់ ខឿនជុំវិញ និងជម្រាល) អាចធ្វើឲ្យមនុស្សចាស់ និងជនពិការកាន់តែមានលទ្ធភាពងាយស្រួលទទួលបានទឹកស្អាត។ មានកម្រង

សៀវភៅណែនាំមួយ បង្កើតឡើងដោយអង្គការជនពិការអន្តរជាតិដើម្បីផ្តល់នូវរូបគំនូរបច្ចេកទេស និងចំនួនទឹកប្រាក់ត្រូវចំណាយដែលបានសាកល្បងនៅក្នុងប្រទេសកម្ពុជារួចហើយ។

ខាងក្រោមនេះគឺជាទិដ្ឋភាពទូទៅដែលគួរយកមកពិចារណា៖

**លទ្ធភាពចេញចូលទៅកាន់ផ្ទៃក្រាលជុំវិញផ្នែកខាងក្នុងនិងទ្រង់ទ្រាយ៖** ជម្រាលស៊ីម៉ង់ត៍មានទំហំធំទូលាយដើម្បីចូលទៅដល់ផ្ទៃក្រាលជុំវិញផ្នែកខាងក្នុង នឹងជួយបង្កលក្ខណៈងាយស្រួលច្រើន (ចៀសវាងកុំធ្វើឲ្យមានកាំជណ្តើរ)។ ផ្ទៃក្រាលជុំវិញផ្នែកខាងក្នុងនោះផ្ទាល់ត្រូវតែធំទូលាយ។ សូមមើលគំនូរបច្ចេកទេសនៅក្នុងឧបសម្ព័ន្ធក្នុងសៀវភៅរបស់អង្គការជនពិការអន្តរជាតិ។

**ដៃស្ទប់៖** អ្នកមានការលំបាកក្នុងការបម្លាស់ទី ឬ មានកម្លាំងខ្សោយអាចទទួលប្រយោជន៍ពីដៃស្ទប់ដែលមានការរចនាខុសប្លែកពីគេ (សូមមើលគំនូរបច្ចេកទេសនៅក្នុងឧបសម្ព័ន្ធក្នុងសៀវភៅរបស់អង្គការជនពិការអន្តរជាតិ)។

**ការលើកធុងទឹក៖** ទម្រតម្កល់ធុងទឹកនៅជិតកន្លែងដងទឹកអាចជួយឲ្យអាចលើកធុងទឹកពីដីមកបានកាន់តែងាយស្រួល (ការត្រួតពិនិត្យលើការបង្កលក្ខណៈងាយស្រួល និងសុវត្ថិភាព អាចជួយកំណត់កម្ពស់សមរម្យសម្រាប់ទម្រនេះ)។

**ការដឹកជញ្ជូនទឹក៖** ធុងទឹកទំហំតូចអាចមានភាពងាយស្រួលសម្រាប់អ្នកដែលមានការលំបាកក្នុងការបម្លាស់ទី ដើម្បីទៅដងទឹក។

**ការទៅដងទឹកពីកន្លែងស្តុកទឹក៖** ត្រូវគិតគូរអំពីកម្ពស់ពាង អាងទឹក ឬ ធុងទឹក ថាតើវាមានភាពងាយស្រួលកម្រិតណាសម្រាប់អ្នកដែលមានការលំបាកក្នុងការបម្លាស់ទី ឬកម្លាំងខ្សោយក្នុងការដួសយកទឹក។ ម្យ៉ាងទៀត ត្រូវគិតផងដែរថាតើកន្លែងស្តុកទឹកត្រូវដាក់នៅក្នុងផ្ទះ ឬ ក្រៅផ្ទះ ហើយមួយណាដែលធ្វើឲ្យងាយស្រួល ឬ ពិបាកក្នុងការទៅដួសយកប្រើជាង។

## ប្រអប់ទី 4៖ ការស្ថាបនាបរិស្ថានដែលមានការបង្កលក្ខណៈងាយស្រួលនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍

**របៀបស្ថាបនាបរិស្ថានដែលមានការបង្កលក្ខណៈងាយស្រួលនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ៖ សៀវភៅណែនាំលេខ២ អំពីការទទួលបានសេវាទឹកស្អាត និងអនាម័យ (ផ្នែកទី២ កន្លែងលាងសម្អាតបើកចំហរ និងចំណុចដងទឹក) ដោយអង្គការជនពិការអន្តរជាតិ ឆ្នាំ២០០៨។**

ឯកសារនេះផ្តល់គំនូរបច្ចេកទេស និងចំនួនទឹកប្រាក់ត្រូវចំណាយលើការរចនាជាសកលសម្រាប់**កន្លែងលាងសម្អាតមានទីធ្លាទូលាយ និងចំណុចដងទឹកនៅក្នុងប្រទេសកម្ពុជា**ដូចខាងក្រោម៖

ទីកន្លែងលាងសម្អាតដែលមានអណ្តូងស្នប់ ឬអណ្តូងលូ

- ទីកន្លែងលាងសម្អាតបំពាក់ដោយអណ្តូងស្នប់
- ទីកន្លែងលាងសម្អាតមានផ្ទៃខឿនទាប
- ទីកន្លែងលាងសម្អាតមានអណ្តូងលូ និងប្រដាប់រវៃដៃ

ទីកន្លែងលាងសម្អាតមានទីធ្លាទូលាយដែលមានពាង ឬធុងទឹក

- កន្លែងលាងសម្អាតមានពាងទឹក
- កន្លែងលាងសម្អាតមានបំពង់ទឹកធ្វើពីស៊ីម៉ង់ត៍
- កន្លែងលាងសម្អាតមានប្រព័ន្ធបង្ហូរទឹកឲ្យធ្លាក់ពីលើចុះក្រោម

កន្លែងចូលទៅរកប្រភពទឹកដូចជា ទឹកស្ទឹង បឹង និងអាងទឹក

- ស្ពានឈើសម្រាប់ដើរចុះទៅដងទឹក
- ស្ពានសម្រាប់ដើរចុះទៅដងទឹកចាក់ប្លង់សេស៊ីម៉ងត៍

## ៨. ការពិនិត្យតាមដាន និងការវាយតម្លៃកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យសម្រាប់ការដាក់បញ្ចូលជនពិការ និងមនុស្សចាស់

ផ្នែកនេះផ្តល់នូវមគ្គុទ្ទេសក៍សំណួរចំនួនពីរដែលត្រូវដាក់បញ្ចូលទៅក្នុងដំណើរការពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំដែលអាចនឹងមានប្រយោជន៍ក្នុងការៈ

- ពិនិត្យតាមដាន ថាតើកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ មានលក្ខណៈរួមបញ្ចូលសម្រាប់ជនពិការ និងមនុស្សចាស់ ឬទេ?
- វាយតម្លៃថាតើកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យមួយមានប្រសិទ្ធភាពកម្រិតណា ក្នុងការដាក់បញ្ចូលជនពិការ និងមនុស្សចាស់

ជាការសំខាន់ណាស់ដែលត្រូវឲ្យមានការបែងចែកទិន្នន័យទៅតាមពិការភាព យេនឌ័រ និងអាយុ ព្រមទាំងយកទិន្នន័យទាំងនោះមកប្រើប្រាស់។ ការងារនេះ មិនមែនមានត្រឹមតែការវាស់វែងនូវលទ្ធភាពចូលទៅរកសេវាផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យតែប៉ុណ្ណោះទេ ប៉ុន្តែ ក៏ជាការវាស់វែងអំពីការប្រើប្រាស់សេវា ការប្រព្រឹត្តផ្នែកអនាម័យ និងលទ្ធផលដែលកើតចេញពីផលប៉ះពាល់របស់សកម្មភាពកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យទៅលើស្ត្រី និងបុរសពិការ ព្រមទាំងមនុស្សចាស់ផងដែរ។

**ការកំណត់គោលដៅសម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូល**

នៅពេលដំបូងរបស់កម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យ ក្រោយពេលបានប្រមូលទិន្នន័យបឋម និងវិភាគអំពីរបាំងរួចរាល់ហើយ កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យអាចកំណត់គោលដៅដើម្បីលើកកម្ពស់លទ្ធភាពទទួលបានសេវាពីកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យសម្រាប់ជនពិការនិងមនុស្សចាស់។ បន្ទាប់មក កម្មវិធីអាចពិនិត្យតាមដានលើគោលដៅទាំងនេះ នៅក្នុងអំឡុងពេលអនុវត្តកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យទាំងមូល និងបន្ទាប់មកទៀតអាចធ្វើការវាយតម្លៃលើកម្មវិធីបាន។ ឧទាហរណ៍មួយចំនួន អំពីគោលដៅរបស់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលពិការភាព និងមនុស្សចាស់ មានដូចជាៈ

- បង្កើនការបង្កលក្ខណៈងាយស្រួលនៃទីតាំងបង្គន់អនាម័យ
- បង្កើនការបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានសម្ភារៈផ្សព្វផ្សាយអំពីការលាងសម្អាតដៃ
- កាត់បន្ថយចំនួនមនុស្សដែលមិនមានលទ្ធភាពទទួលបាន និងមិនអាចប្រើប្រាស់នូវបរិក្ខាទាំងនោះ
- បង្កើនការចូលរួមពីមនុស្សចាស់ និងជនពិការក្នុងការប្រជុំក្នុងសហគមន៍
- បង្កើនតួនាទីសកម្មរបស់មនុស្សចាស់និងជនពិការ
- បង្កើនចំណេះដឹងរបស់បុគ្គលិកទាក់ទងនឹងការដាក់បញ្ចូលពិការភាព

**ការចែករំលែកព័ត៌មានជាមួយវិស័យពិការភាព និងមនុស្សចាស់**

បច្ចុប្បន្នមានភស្តុតាងតិចតួចណាស់ដែលបង្ហាញអំពីរបាំង និងកត្តាជម្រុញលទ្ធភាពទទួលបានសេវាពីកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យសម្រាប់ជនពិការ និងមនុស្សចាស់នៅក្នុងប្រទេសកម្ពុជា។ ដើម្បីដោះស្រាយភាពខ្វះចន្លោះនេះ ភ្នាក់ងារកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យអាចចែករំលែកព័ត៌មានដែលបានប្រមូលនៅក្នុងអំឡុងពេលពិនិត្យតាមដាន និងវាយតម្លៃទាក់ទងនឹងរបាំង និងកត្តាជម្រុញលទ្ធភាពទទួលបានសេវាការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យសម្រាប់ជនពិការ និង មនុស្សចាស់ ជាមួយវិស័យនេះទាំងមូល ព្រមទាំងអាចផ្សព្វផ្សាយអំពីការអនុវត្តន៍ល្អតាមរយៈបណ្តាញកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានស្រាប់។

## ៨.១ របៀបពិនិត្យតាមដានការដាក់បញ្ចូល និងការបង្កលក្ខណៈងាយស្រួល

**ការត្រួតពិនិត្យលើការបង្កលក្ខណៈងាយស្រួល និងសុវត្ថិភាពដោយមានការចូលរួម** គឺជាឧបករណ៍ពិនិត្យតាមដានបែបអនុវត្តជាក់ស្តែង (សូមមើលខាងក្រោម)។ ការត្រួតពិនិត្យលើការបង្កលក្ខណៈងាយស្រួល និងសុវត្ថិភាពគឺជាការពិភាក្សាបែបអនុវត្តជាក់ស្តែងរវាងអង្គការបំពាក់បរិក្ខារទឹកស្អាត និងការលើកកម្ពស់អនាម័យជាមួយអ្នកប្រើប្រាស់ ដែលរួមមានទាំងបុរសនិងស្ត្រី អ្នកមានបញ្ហាកម្សោយអវៈយវៈប្រភេទផ្សេងៗគ្នា និងមនុស្សចាស់។ លទ្ធផលដែលបានពីការពិភាក្សាទាំងនេះ អាចយកមកប្រើប្រាស់ ដើម្បីបង្កើនការយល់ដឹងអំពីរបាំង និងដំណោះស្រាយដើម្បីធ្វើឲ្យបង្គន់អនាម័យ ទីតាំងដងយកទឹក មូលដ្ឋានទីតាំងសម្រាប់លាងដៃ កាន់តែមានលក្ខណៈបង្កភាពងាយស្រួល។

## ប្រអប់ទី 5៖ ការត្រួតពិនិត្យលើការបង្កលក្ខណៈងាយស្រួលនិងសុវត្ថិភាព

**ឧបករណ៍ពិនិត្យតាមដាន ៖ ការត្រួតពិនិត្យលើការបង្កលក្ខណៈងាយស្រួល និងសុវត្ថិភាព**

ការត្រួតពិនិត្យលើការបង្កលក្ខណៈងាយស្រួល និងសុវត្ថិភាពគឺជាវិធីសាស្រ្តដែលមានការចូលរួម ដើម្បីពិនិត្យតាមដានឬវាយតម្លៃទៅលើកម្រិតនៃការបង្កលក្ខណៈ ងាយស្រួលនិងសុវត្ថិភាពនៃ**មូលដ្ឋានទឹកស្អាត និង/ឬ បរិស្ថានជុំវិញដែលមានស្រាប់**

សម្ភារៈ៖ ប៊ិច ក្រដាស ម៉ែត្រ សំពត់ និង ម៉ាស៊ីនថត (ជាជម្រើស)។

ការត្រួតពិនិត្យកំណត់រកចំណុចងាយៗដែលត្រូវផ្លាស់ប្តូរទៅលើមូលដ្ឋានទឹកស្អាត និងអនាម័យ និងអ្វីៗដែលនៅជុំវិញទីនោះ ដើម្បីធ្វើឲ្យជនពិការ និងមនុស្សចាស់អាចប្រើប្រាស់ទីតាំងទាំងនោះបានកាន់តែប្រសើរថែមទៀត។ ខាងក្រោមនេះ គឺជាជំហានសំខាន់ៗក្នុងការត្រួតពិនិត្យការបង្កលក្ខណៈងាយស្រួល និងសុវត្ថិភាព។

ជំហានទី១៖ ធ្វើការជាដៃគូជាមួយអង្គការជនពិការ និងសមាគមមនុស្សចាស់ក្នុងមូលដ្ឋាន។ កំណត់រក និងធ្វើការជាមួយអង្គការជនពិការ និងសមាគមមនុស្សចាស់។

ជំហានទី២៖ ជ្រើសរើសទីតាំងសម្រាប់ធ្វើការវាយតម្លៃ និងចងក្រងក្រុមការងារត្រួតពិនិត្យ ដោយក្នុងនោះមានសមាជិកសហគមន៍ រួមទាំងអ្នកដែលមានពិការភាព និងអ្នកមិនមានពិការភាព។

ជំហានទី៣៖ បណ្តុះបណ្តាលក្រុមការងារត្រួតពិនិត្យអំពីរបៀបធ្វើការត្រួតពិនិត្យ។ សមាជិកអង្គការជនពិការ និងសមាគមមនុស្សចាស់ ប្រហែលជាត្រូវការវគ្គបណ្តុះបណ្តាលសាមញ្ញៗ ស្តីពីរបៀបធ្វើការត្រួតពិនិត្យ។ បំបែកជាក្រុមតូច

និងចាត់តាំងតួនាទីសម្រាប់សមាជិកក្រុមថាតើនរណានឹងត្រូវធ្វើការវាស់វែង នរណាជាអ្នកកត់ត្រាការបង្កលក្ខណៈងាយស្រួលហើយនរណាជាអ្នកគូរផ្ទាក្រាម។

ជំហានទី៤៖ វាយតម្លៃអំពីការធ្វើដំណើរទៅកាន់មូលដ្ឋានទឹកស្អាត និងអនាម័យ។ ក្រុមការងារការវាយតម្លៃអំពីការធ្វើដំណើរឆ្ពោះទៅទីកន្លែងនោះ (ដូចជា តើផ្លូវធ្វើដំណើរធំទូលាយគ្រប់គ្រាន់ឬទេ ជាដើម)។ កត់ត្រាការរកឃើញរបស់អ្នក និងពិភាក្សារកដំណោះស្រាយដូចដែលអ្នកបានទៅឃើញ។

ជំហានទី៥៖ ការវាយតម្លៃមូលដ្ឋានទឹកស្អាត និងអនាម័យ។ ក្រុមការងារវាយតម្លៃទីកន្លែង និងកត់ត្រាការរកឃើញ និងធ្វើការពិភាក្សា។ សូមដាក់បញ្ចូលធាតុផ្សំផ្នែកសុវត្ថិភាពផងដែរ (តើមានពន្លឺនៅខាងក្នុង ឬទេ? តើទ្វារមានគន្លឹះ ឬ សោរសម្រាប់បិទ ដែរឬទេ?)

ជំហានទី៦៖ បង្កើតដំណោះស្រាយ។ ជំហានបញ្ចប់គឺបង្កើតដំណោះស្រាយ។ ក្រុមការងារត្រូវបង្កើតបញ្ជីដំណោះស្រាយដែលអាចមានលទ្ធភាពធ្វើបាន។ បន្ទាប់មក ក្នុងនាមជាស្ថាប័ន សូមបែងចែកដំណោះស្រាយទាំងនេះទៅតាមប្រភេទជាដំណោះស្រាយរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង និងចាត់អាទិភាពដំណោះស្រាយទាំងនោះ។

**សំណួរគន្លឹះ៖** អាចដាក់បញ្ចូលក្នុងប្រព័ន្ធពិនិត្យតាមដានដែលមានស្រាប់ដើម្បីតាមដានអំពីវឌ្ឍនភាពនៃការដាក់បញ្ចូលជនពិការនិងមនុស្សចាស់ទៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យ។ ខាងក្រោមជាមគ្គុទ្ទេសក៍សំណួរចំនួនពីរ ដោយមគ្គុទ្ទេសក៍សំណួរមួយសម្រាប់ការពិនិត្យតាមដានជាប្រចាំ និងមួយទៀតសម្រាប់វាយតម្លៃកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ។

**ការពិនិត្យតាមដាន៖ មគ្គុទ្ទេសក៍សំណួរសម្រាប់ការពិនិត្យតាមដានជាប្រចាំលើទិដ្ឋភាពនៃការដាក់បញ្ចូលរបស់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ**

**ដំណាក់កាលធ្វើផែនការនិងរចនាការពិនិត្យតាមដាន**

- តើបុគ្គលិកបានទទួលការបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលជនពិការ និងមនុស្សចាស់ទៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យ ឬទេ?
- តើសេចក្តីត្រូវការរបស់ជនពិការនិងមនុស្សចាស់ទាក់ទងនឹងទឹកស្អាត និងការលើកកម្ពស់អនាម័យ មានភាពច្បាស់លាស់ ឬទេ?
- តើអ្នកបានសង្កេតលើបញ្ហាទាក់ទងនឹងការដាក់បញ្ចូលជនពិការ និងបញ្ហារបស់មនុស្សចាស់ ពាក់ព័ន្ធនឹងទឹកស្អាត ការផ្តល់សេវាអនាម័យ និងការប្រើប្រាស់នៅក្នុងទីតាំងរបស់គម្រោង ឬទេ? តើជនពិការ និងមនុស្សចាស់មានទីតាំងនៅឯណា នៅក្នុងទីតាំងរបស់គម្រោងទឹកស្អាត និងការលើកកម្ពស់អនាម័យ?
- តើអ្នកបានប្រើទស្សនវិស័យដែលមានការដាក់បញ្ចូលពិការភាពនៅក្នុងការប្រមូលព័ត៌មាន ដែរឬទេ? តើអ្នកបានពិគ្រោះយោបល់ជាមួយអង្គការជនពិការ ឬសមាគមន៍មនុស្សចាស់នៅមូលដ្ឋាន ដែរឬទេ?

**ការពិនិត្យតាមដានក្នុងអំឡុងពេលអនុវត្ត**

*ទីតាំង ប្លង់ការរចនា និងការបង្កលក្ខណៈងាយស្រួល*

- តើមានខ្ទង់ថវិកាសម្រាប់សកម្មភាពការដាក់បញ្ចូលពិការភាព និងមនុស្សចាស់ ដែរឬទេ?

- តើប្លង់ការរចនា និង ទីតាំងរបស់មូលដ្ឋានផ្តល់សេវាទឹកស្អាតនិងការលើកកម្ពស់អនាម័យឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ស្ត្រី និងបុរសកុមារានិងកុមារីពិការ និងមនុស្សចាស់ ដែរឬទេ?
- តើបង្គន់អនាម័យនិងចំណុចសម្រាប់ដងទឹក មានទីតាំងដែលអាចធានាសន្តិសុខផ្លូវកាយដល់ស្ត្រី និងកុមារីពិការគ្រប់វ័យ ដែរឬទេ?
- តើទីតាំងស្ថិតនៅជិតផ្ទះ ឬទេ ហើយតើមានផ្លូវដែលបង្កលក្ខណៈងាយស្រួល និងមានពន្លឺគ្រប់គ្រាន់ ឬទេ?
- តើជនពិការ និងមនុស្សចាស់ប្រើប្រាស់សេវាទឹកស្អាត និងការលើកកម្ពស់អនាម័យញឹកញាប់ ឬទេ?
- តើមានការសង់បង្គន់អនាម័យដាច់ដោយឡែកពីគ្នាសម្រាប់ស្ត្រី និងបុរស កុមារា និងកុមារី ឬទេ? តើមានការថែទាំអនាម័យបង្គន់ទាំងនេះ ឬទេ? តើបង្គន់ទាំងនេះមានការបង្កលក្ខណៈងាយស្រួលសម្រាប់ស្ត្រី និងបុរស កុមារា និងកុមារីពិការ និងមនុស្សចាស់ (ឧ. នៅសាលារៀន កន្លែងធ្វើការ កន្លែងសាធារណៈ) ឬទេ?

**ការចូលរួមការផ្តល់សិទ្ធិអំណាច និងការសម្រេចចិត្ត**

- តើកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យមានឥទ្ធិពលអ្វីខ្លះលើជនពិការ និងមនុស្សចាស់ (សូមមើលឧបករណ៍ពិនិត្យតាមដានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ជាងគេបំផុតខាងក្រោម)
- តើស្ត្រីពិការទាំងក្មេង និងចាស់ បានចូលរួមក្នុងការធ្វើផែនការ (រួមទាំងការធ្វើផែនការអំពីទីតាំង ប្លង់ការរចនា និងគុណភាព) និងការគ្រប់គ្រងសេវាទឹកស្អាត និងអនាម័យ ដែរឬទេ?
- តើស្ត្រី និងបុរសពិការ និង មនុស្សចាស់បានចូលរួមធ្វើសេចក្តីសម្រេចចិត្តជាមួយសមាជិកដៃទៃទៀតក្នុងសហគមន៍ ឬទេ? (សូមមើលឧបករណ៍ពិនិត្យតាមដានជណ្តើរនៃការចូលរួមខាងក្រោម)
- តើកន្លែងប្រជុំសម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និង លើកកម្ពស់អនាម័យបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ មនុស្សចាស់ និងស្ត្រីមានផ្ទៃពោះ ឬទេ?

*ទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត ៖*

- តើទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត បានឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ជនពិការនិងមនុស្សចាស់ ដែរឬទេ?
- តើមានការផ្សព្វផ្សាយសារទៅដល់ក្រុម/អង្គការជនពិការ ស្ថាប័នពាក់ព័ន្ធជនពិការ និងមនុស្សចាស់ (សាលារៀន ពិសេសកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ។ល។) និង សេវាពិការភាព និងស្តារទ្ធភាពពលកម្ម ឬទេ?

## ប្រអប់ទី 6៖ ជណ្តើរនៃការចូលរួម

**ឧបករណ៍ពិនិត្យតាមដានតាមបែបអនុវត្តជាក់ស្តែង ដែលផ្តោតលើការផ្តល់សិទ្ធិអំណាច និងការធ្វើសេចក្តីសម្រេចចិត្ត៖ ជណ្តើរនៃការចូលរួម**

ឧបករណ៍នេះមានបំណងពិនិត្យតាមដានពីប្រសិទ្ធភាពនៃការចង់ចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រី និងបុរសពិការ និងមនុស្សចាស់។ ដ្យាក្រាមខាងក្រោមបង្ហាញកម្រិតផ្សេងៗគ្នានៃការចូលរួម។ ដ្យាក្រាមនេះក៏ជួយដល់អ្នកសម្ភាសន៍ក្នុងការវាយតម្លៃ ថាតើមនុស្សណាម្នាក់ស្ថិតនៅចំណុចត្រង់ណារបស់ជណ្តើរនៃការចូលរួមផងដែរ។ គេអាចយកឧបករណ៍នេះមកប្រើជាញឹកញាប់ដូចជារៀងរាល់ត្រីមាសជាដើម។




## <u>កម្រិត</u>

កម្រិត ០៖ ការចូលរួមឲ្យតែរួចៗ

កម្រិតទី១៖ ចូលរួមសកម្ម

កម្រិតទី២៖ ធ្វើការសម្រេចចិត្ត

កម្រិតទី៣៖ ភាពជាម្ចាស់ និងការគ្រប់គ្រង

## និយមន័យ៖

- **អនុញ្ញាតឲ្យចូលរួម៖** អ្នកឆ្លើយតប បានទទួលការអញ្ជើញទៅប្រជុំសហគមន៍
- **ចូលរួមការប្រជុំ៖** រូបអ្នកឆ្លើយតប បានទៅចូលរួមប្រជុំ វគ្គបណ្តុះបណ្តាល ឬការប្រឹក្សាយោបល់
- **បញ្ចេញយោបល់៖** អ្នកឆ្លើយតប បានលើកបញ្ហា ក្តីបារម្ភ សំណួរដែលគាត់មាន
- **យោបល់ត្រូវបានគេស្តាប់៖** អ្នកឆ្លើយតប មានអារម្មណ៍ថាអ្នកចូលរួមដទៃទៀតស្តាប់ការនិយាយរបស់ខ្លួនដោយយកចិត្តទុកដាក់ ហើយបានយល់ពីបញ្ហា ការបារម្ភ សំណួរដែលគាត់បានលើកឡើង
- **ជះឥទ្ធិពលលើការសម្រេចចិត្ត៖** ការសម្រេចចិត្តត្រូវបានធ្វើឡើងក្នុងលក្ខណៈឆ្លើយតបចំពោះបញ្ហា ការបារម្ភ សំណួរ ដែលអ្នកឆ្លើយតបបានលើកឡើង
- **ធ្វើការសម្រេចចិត្ត៖** អ្នកឆ្លើយតបអាចធ្វើការសម្រេចចិត្តដោយខ្លួនឯង ឬ បោះឆ្នោតគាំទ្រ ឬ បោះឆ្នោតបដិសេធការសម្រេចរបស់ក្រុម។

## ប្រអប់ទី 7៖ រឿងរ៉ាវនៃការផ្លាស់ប្តូរដ៏គួរឱ្យកត់សម្គាល់បំផុត

**ឧបករណ៍ពិនិត្យតាមដានផ្តោតការយកចិត្តទុកដាក់លើឥទ្ធិពលនៃកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យសម្រាប់ជនពិការ និងមនុស្សចាស់៖ រឿងរ៉ាវនៃការផ្លាស់ប្តូរដ៏គួរឱ្យកត់សម្គាល់បំផុត**

រង្វាស់ការពិនិត្យតាមដានដ៏មានប្រសិទ្ធភាពមួយដើម្បីវាយតម្លៃ ថាតើលទ្ធភាពទទួលបានសេវាពីកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យមានភាពប្រសើរឡើងដែរឬទេ សម្រាប់ស្ត្រីនិងបុរសពិការ ឬ ស្ត្រី និងបុរសវ័យចំណាស់ គឺការកំណត់រករឿងរ៉ាវនៃការផ្លាស់ប្តូរដ៏គួរឱ្យកត់សម្គាល់បំផុត។

រឿងរ៉ាវអំពីការផ្លាស់ប្តូរដ៏គួរឱ្យកត់សម្គាល់បំផុត ត្រូវបានរៀបរាប់ប្រាប់ដោយប្រជាជនក្នុងសហគមន៍។ ពេលបានធ្វើសម្រង់រឿងរួចរាល់ហើយ ក្រុមដែលត្រូវបានជ្រើសរើសនឹងអានរឿងទាំងនោះនឹងពិភាក្សាស៊ីជម្រៅអំពីគុណតម្លៃនៃការផ្លាស់ប្តូរទាំងនេះ។ បន្ទាប់មកពួកគេត្រូវជ្រើសរើសថាតើរឿងមួយណាដែលគួរឲ្យកត់សម្គាល់ជាងគេបំផុត។ ការពិភាក្សាដោយមានការសម្របសម្រួល អាចធ្វើឡើងនៅតាមសហគមន៍ ដោយមានវត្តមានអ្នកនិទានរឿង (ប្រសិនបើមានការឯកភាព) ដែលមកពីក្រុមការងារគម្រោង ឬ អ្នកជាប់ពាក់ព័ន្ធសំខាន់ក្នុងកម្មវិធី។ ដំណើរការនេះ ជួយលើកទឹកចិត្តឲ្យមានការវិភាគលើលទ្ធផលដែលសម្រេចបាន និងផលប៉ះពាល់ទៅលើអ្នកប្រើប្រាស់ ជាជាងគ្រាន់តែពិនិត្យទៅលើតែទិន្នផល។

## ៨.២ របៀបធ្វើការវាយតម្លៃ៖ សំណួរមគ្គុទ្ទេសក៍សម្រាប់ការវាយតម្លៃអំពីទិដ្ឋភាពក្នុងការដាក់បញ្ចូលរបស់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ

**ទិដ្ឋភាពផ្នែកស្ថាប័ន៖**

- តើមានអ្នកជំនាញផ្នែកការអភិវឌ្ឍន៍ដែលមានការដាក់បញ្ចូលការអប់រំផ្នែកទឹកស្អាត និងការលើកកម្ពស់អនាម័យនៅក្នុងអង្គការក្រុមការងារគម្រោង ឬ កម្មវិធី ដែរឬទេ?
- តើស្ត្រីនិងបុរសពិការ និងមនុស្សចាស់បានចូលរួមយ៉ាងពេញលេញនៅក្នុងអង្គការ (ពិចារណាលើភាពជាដៃគូជាមួយអង្គការដទៃនិងក្នុងរង្វង់អ្នកធ្វើការក្នុងអង្គការរបស់ខ្លួន) ហើយកត្តារើសអើងផ្ទៃក្នុង (ឧ. ឥរិយាបទរបស់បុគ្គលិក) ត្រូវបានដោះស្រាយដោយជោគជ័យ ឬទេ?
- តើមានឧបសគ្គសម្រាប់ស្ត្រីនិង/ឬបុរសពិការ និង មនុស្សចាស់ក្នុងការទទួលបាននិងអភិបាលលើធនធានឬទេ?
- តើមានគោលនយោបាយពាក់ព័ន្ធនឹងជនពិការនៅក្នុងអង្គការ ឬទេ?

**ការវាយតម្លៃផលប៉ះពាល់លើពិការភាព៖**

- តើគោលបំណងនិងសកម្មភាពរបស់កម្មវិធីមានផលប៉ះពាល់ទៅលើវិសមភាពដែលកំពុងកើតមានរវាងស្ត្រី និងបុរសពិការកុមារា និងកុមារីពិការ និងមនុស្សចាស់ ដែរឬទេ?
- តើកម្មវិធីនឹងមានឥទ្ធិពលលើស្ត្រីនិងបុរសពិការ និងមនុស្សចាស់យ៉ាងណាខ្លះ? ឧ. តើបន្ទុកការងាររបស់ពួកគាត់នឹងកើនឡើង ឬថយចុះ? តើសុខភាពរបស់ពួកគាត់នឹងរងត្រូវប៉ះពាល់ ឬទេ? តើអាចឈានទៅសម្រេចបានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ឬទេ? តើមានសមភាពយេនឌ័រនៅក្នុងបន្ទុកការងារ និងអ្នកទទួលផលឬទេ?
- ការពិនិត្យតាមដាននិងវាយតម្លៃដែលផ្តោតជាក់លាក់លើពិការភាព និងមនុស្សចាស់៖ តើអ្នកវាស់វែង និងត្រួតពិនិត្យដោយមានបែងចែកពីគ្នានូវឥទ្ធិពលដែលមានលើស្ត្រី បុរស កុមារី កុមារាដែលមានពិការភាព និងមនុស្សចាស់ធៀបនឹងមនុស្សដទៃទៀតដែលគ្មានពិការភាព និងមនុស្សវ័យក្មេង ឬទេ? តើអ្នកធ្វើដូចម្តេច?

**បច្ចេកវិទ្យា និងធនធាន៖**

- តើបច្ចេកវិទ្យាដែលបានប្រើ ឆ្លើយតបចំពោះអាទិភាព និងសេចក្តីត្រូវការរបស់ស្ត្រីនិងបុរសពិការ និង មនុស្សចាស់ដែរ ឬទេ?
- តើមានផែនការបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ប្រតិបត្តិការនិងការថែទាំបរិក្ខារ ដែរឬទេ? តើស្ត្រី និងបុរសពិការ និងមនុស្សចាស់ អាចចូលរួមដោយរបៀបណា?

**ការផ្តល់សិទ្ធិអំណាច និងការសម្រេចចិត្ត៖**

- តើសមត្ថភាពរបស់ស្ត្រីពិការ និងស្ត្រីវ័យចំណាស់ត្រូវបានអភិវឌ្ឍន៍ ឬទេ? តើមានការលើកទឹកចិត្តឲ្យពួកគេចូលរួមប្រជុំ ដែរឬទេ?
- តើស្ត្រី និងបុរសកុមារា និងកុមារីពិការ និងមនុស្សចាស់ មានលទ្ធភាពទទួលបានព័ត៌មានវគ្គបណ្តុះបណ្តាលនិងធនធានដែលពាក់ព័ន្ធ ដែរឬទេ?
- នៅក្នុងក្រុមជនពិការ និងមនុស្សចាស់ តើមានសមភាពយេនឌ័រនៅក្នុងការសម្រេចចិត្ត ដែរឬទេ?